រៀបរៀងដោយ លឹម ផល្គុន
បរិញ្ញាប័ត្រផ្នែកគណិតវិទ្យា

# ដេរីវេនៃអនុគមន៍

# Derivative of function

$$f'(c) = \frac{f(b) - f(a)}{b - a}$$

រួមមាន ៖

មេរៀនសង្ខេប

លំហាត់គំរូ

លំហាត់អនុវត្តន៍

រក្សាសិទ្ធិ

## គណៈកម្មការនិពន្ធ និង រៀបរៀង

**លឹម ផល្គុន និង អ៊ុំង សំណាង**

## គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

**លោក យ៉ង់ ឆារី**
**លោក លឹម ឆុន**
**លោក សែន ពិសិដ្ឋ**

## គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

**លោក លឹម មិត្តសិរ**

## ការិយកុំព្យូទ័រ

**លោក អ៊ុំង សំណាង និង លឹម ផល្គុន**

# អារម្ភកថា

សួស្តីមិត្តអ្នកសិក្សាជាទីស្រឡាញ់រាប់អាន !

សៀវភៅ **ដេរីវេនៃអនុគមន៍ថ្នាក់ទី១២**ដែលលោកអ្នកកំពុងតែកាន់អាននេះ ខ្ញុំបាទបានរៀបចំឡើងសម្រាប់ទុកជាឯកសារសម្រាប់អ្នកសិក្សាដែលមាន បំណងចង់យល់ដឹងអំពីមេរៀននេះឲ្យកាន់តែច្បាស់លាស់។

នៅក្នុងសៀវភៅនេះ យើងខ្ញុំបានសង្ខេបមេរៀន អមជាមួយឧទាហរណ៍គំរូ ដែលអាចឲ្យអ្នកសិក្សាងាយយល់ និង ឆាប់ចងចាំ ហើយព្រមទាំងមានលំហាត់ អនុវត្តន៍សម្រាប់អ្នកសិក្សាហ្វឹកហាត់ដោះស្រាយដោយខ្លួនឯង។

យើងខ្ញុំសង្ឃឹមថា សៀវភៅមួយក្បាលនេះ នឹងអាចចូលរួមផ្តល់នូវ គំនិត និង វិធីសាស្ត្រថ្មីៗក្នុងការដោះស្រាយលំហាត់លើផ្នែកដេរីវេនៃអនុគមន៍ ចំពោះលោកអ្នកសិក្សាជាពុំខានឡើយ ។

ជាទីបញ្ចប់ខ្ញុំបាទសូមជូនពរចំពោះលោកអ្នក សូមមានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។

បាត់ដំបងថ្ងៃទី០៥ កក្កដា ឆ្នាំ២០១២

អ្នកនិពន្ធ និង ស្រាវជ្រាវ

**លឹម ផល្គុន**

Tel :017 768 246

Email: lim_phalkun@ymail.com

Website: www.mathtoday.wordpress.com

# មាតិការឿង

ទំព័រ

**ជំពូកទី១**

*ដេរីវេនៃអនុគមន៍* 001

១-ដេរីវេនៃអនុគមន៍ត្រង់ចំណុចមួយ 001
២-ដេរីវេនៃអនុគមន៍បណ្ដាក់ 005
៣-ដេរីវេនៃអនុគមន៍ត្រីកោណមាត្រ 006
៤-ដេរីវេនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល 011
៥-ដេរីវេនៃអនុគមន៍លោការីតនេពែ 013
៦-ដេរីវេលំដាប់ខ្ពស់ 016
៧-ដេរីវេនៃអនុគមន៍អាំព្លីស៊ីត 019

**ជំពូកទី២**

*ការអនុវត្តន៍ដេរីវេនៃអនុគមន៍* 021

១-ការអនុវត្តន៍ក្នុងការគណនាតម្លៃបរមា 021

២-ល្បឿន និង សំទុះនៃចលនា 022
៣-ឌីផេរ៉ង់ស្យែល 024
៤-វិសមភាពកំណើនមានកំណត់ 025
៥-ទ្រឹស្តីបទរ៉ូល 030
៦-ទ្រឹស្តីបទតម្លៃមធ្យម 033
៧-អនុវត្តន៍ក្នុងសេដ្ឋកិច្ច 035

## ជំពូកទី៣

*អថេរភាព និង ក្រាបនៃអនុគមន៍* 037

១-សិក្សាអនុគមន៍សនិទាន 037
ក/សិក្សាអនុគមន៍ $y=\dfrac{ax^2+bx+c}{px+q}$ 037
ខ/សិក្សាអនុគមន៍ $y=\dfrac{ax^2+bx+c}{px^2+qx+r}$ 056
២-សិក្សាអនុគមន៍អសនិទាន 081
ក/សិក្សាអនុគមន៍ $y=\sqrt{ax+b}$ 081
ខ/សិក្សាអនុគមន៍ $y=\sqrt{ax^2+bx+c}$ 086
៣-សិក្សាអនុគមន៍អិចស្ប៉ូណង់ស្យែល 096
៤-សិក្សាអនុគមន៍លោការីតនេពែ 107

ជំពូកទី៤

លំហាត់មានដំណោះស្រាយ 112

ជំពូកទី៥

លំហាត់អនុវត្តន៍ 164

ឯកសារយោង 195

ជំពូកទី១

# ដេរីវេនៃអនុគមន៍

## ១-ដេរីវេនៃអនុគមន៍ត្រង់ចំណុចមួយ

*ក/និយមន័យ* ៖

ដេរីវេត្រង់ចំណុច $x_0$ នៃអនុគមន៍ $y=f(x)$ (បើមាន) ជាលីមីតនៃផលធៀបកំណើន $\frac{\Delta y}{\Delta x}$ កាលណា $\Delta x$ ខិតទៅជិត $0$ ។

គេកំណត់សរសេរ ៖

$$f'(x_0)=\lim_{\Delta x\to 0}\frac{\Delta y}{\Delta x}=\lim_{x\to x_0}\frac{f(x)-f(x_0)}{x-x_0}=\lim_{h\to 0}\frac{f(x_0+h)-f(x_0)}{h}$$

*ឧទាហរណ៍* រកដេរីវេត្រង់ $x_0=2$ នៃអនុគមន៍ $y=x^3$

គេបាន $f'(2)=\lim_{h\to 0}\frac{f(2+h)-f(2)}{h}=\lim_{h\to 0}\frac{(2+h)^3-8}{h}$

$$=\lim_{h\to 0}\frac{(2+h-2)[(2+h)^2+2(2+h)+4]}{h}$$

$$=\lim_{h\to 0}(h^2+6h+12)=12$$

## ខ/ភាពមានដេរីវេ ៖

អនុគមន៍ $f$ មានដេរីវេត្រង់ចំណុច $x = x_0$ លុះត្រាតែ ៖

-អនុគមន៍ $f$ ជាប់ត្រង់ចំណុច $x = x_0$

-ដេរីវេខាងឆ្វេង និង ដេរីវេខាងស្តាំស្មើគ្នាគឺ $f'_-(x_0) = f'_+(x_0)$

ដែល $f'_-(x_0) = \lim\limits_{h \to 0^-} \dfrac{f(x_0 + h) - f(x_0)}{h}$

និង $f'_+(x_0) = \lim\limits_{h \to 0^+} \dfrac{f(x_0 + h) - f(x_0)}{h}$ ។

ឧទាហរណ៍ គេមានអនុគមន៍ $f(x) = \begin{cases} x^2 + px + q & \text{បើ} \quad x \le 1 \\ 3x + 4 & \text{បើ} \quad x > 1 \end{cases}$

កំណត់ពីរចំនួនពិត $p$ និង $q$ ដើម្បីឲ្យ $f$ មានដេរីវេត្រង់ $x = 1$ ។

គេត្រូវឲ្យ $f$ ជាប់ត្រង់ $x = 1$ គឺ $\lim\limits_{x \to 1^-} f(x) = \lim\limits_{x \to 1^+} f(x)$

គេបាន $\lim\limits_{x \to 1^-} (x^2 + px + q) = \lim\limits_{x \to 1^+} (3x + 4)$

$$1 + p + q = 7 \text{ ឬ } q = 6 - p \quad (1)$$

និងគេត្រូវឲ្យ $f'_-(1) = f'_+(1)$ ។

គេមាន $f'_{-}(1)=\lim\limits_{h\to 0^-}\dfrac{f(1+h)-f(1)}{h}$

$$=\lim_{h\to 0^-}\frac{(1+h)^2+p(1+h)+q-(1+p+q)}{h}$$

$$=\lim_{h\to 0^-}\frac{1+2h+h^2+p+ph+q-1-p-q}{h}$$

$$=\lim_{h\to 0^-}\frac{h^2+(2+p)h}{h}$$

$$=\lim_{h\to 0^-}(h+2+p)=2+p$$

ហើយ $f'_{+}(1)=\lim\limits_{h\to 0^+}\dfrac{f(1+h)-f(1)}{h}$

$$=\lim_{h\to 0^+}\frac{3(h+1)+4-(3+4)}{h}$$

$$=\lim_{h\to 0^+}\frac{3h}{h}=3$$

ហេតុនេះ $2+p=3$ នោះ $p=1$

ហើយតាម(1) គេបាន $q=6-1=5$ ។

ដូចនេះ $p=1$ , $q=5$ ។

# លំហាត់អនុវត្តន៍

១-គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=x^3-x^2+1$

ដោយប្រើនិយមន័យចូរគណនា $f'(0)$ , $f'(-1)$ និង $f'(1)$ ។

២-គេមានអនុគមន៍ $f$ កំណត់ដោយ ៖

$$f(x)=\begin{cases} x^2+ax+2 & \text{បើ } x\le 1 \\ bx^2+4x+1 & \text{បើ } x>1 \end{cases}$$

កំណត់ចំនួនពិត $a$ និង $b$ ដើម្បីឲ្យអនុគមន៍ $f$ មានដេរីវេត្រង់ $x=1$ ។

៣-គេមានអនុគមន៍ $f$ កំណត់ដោយ ៖

$$f(x)=\begin{cases} a\sin x+b\cos x+1 & \text{បើ } x\le \frac{\pi}{2} \\ b\sin x-a\cos x+3 & \text{បើ } x>\frac{\pi}{2} \end{cases}$$

កំណត់ចំនួនពិត $a$ និង $b$ ដើម្បីឲ្យអនុគមន៍ $f$ មានដេរីវេត្រង់ $x=\frac{\pi}{2}$ ។

៤-គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\sin x-\cos x+1$ ។

ដោយប្រើនិយមន័យគណនា $f'(-\frac{\pi}{4})$ និង $f'(\frac{\pi}{4})$ ។

## ២-ដេរីវេនៃអនុគមន៍បណ្តាក់

បើ $y = f(u)$ និង $u = g(x)$ នោះគេបាន ៖

$y' = \frac{dy}{dx} = \frac{dy}{du} \times \frac{du}{dx}$ ឬ $\frac{d}{dx} f[u(x)] = f'(u) \times u'(x)$ ។

*សម្រាយបញ្ជាក់* ៖

តាង $F(x) = f[g(x)]$ ដោយប្រើភាពមានដេរីវេត្រង់ $x = x_0$

គេត្រូវបង្ហាញថា $F'(x_0) = f'[g(x_0)] \times g'(x_0)$ ។

តាមនិយមន័យគេបាន ៖

$$F'(x_0) = \lim_{x \to x_0} \frac{F(x) - F(x_0)}{x - x_0}$$

$$= \lim_{x \to x_0} \frac{f[g(x)] - f[g(x_0)]}{x - x_0}$$

$$= \lim_{x \to x_0} \frac{f[g(x)] - f[g(x_0)]}{g(x) - g(x_0)} \times \frac{g(x) - g(x_0)}{x - x_0}$$

$$= \lim_{x \to x_0} \frac{f[g(x) - g(x_0)]}{g(x) - g(x_0)} \times \lim_{x \to x_0} \frac{g(x) - g(x_0)}{x - x_0}$$

$$= f'[g(x_0)] \times g'(x_0)$$

ដូចនេះ $F'(x_0) = f'[g(x_0)] \times g'(x_0)$ ។

ឧទាហរណ៍ គណនាដេរីវេនៃអនុគមន៍ $y=\left(\frac{x-1}{x+1}\right)^3$

តាង $u=\frac{x-1}{x+1}$ នោះ $y=u^3$

គេបាន $\frac{du}{dx}=\frac{(x-1)'(x+1)-(x+1)'(x-1)}{(x+1)^2}=\frac{2}{(x+1)^2}$

ហើយ $\frac{dy}{du}=3u^2$ ។ តាមរូបមន្ត $y'=\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$

គេបាន $y'=\frac{dy}{dx}=3u^2.\frac{2}{(x+1)^2}=\frac{6(x-1)^2}{(x+1)^4}$ ។

# ៣-ដេរីវេនៃអនុគមន៍ត្រីកោណមាត្រ

## ក/ដេរីវេនៃអនុគមន៍ស៊ីនុស និង កូស៊ីនុស

បើ $y=\sin x$ នោះ $y'=\cos x$

បើ $y=\cos x$ នោះ $y'=-\sin x$

បើ $y=\sin u$ នោះ $y'=u'\cos u$

បើ $y=\cos u$ នោះ $y'=-u'\sin u$

ដែល $u=u(x)$ ។

*សម្រាយបញ្ជាក់* ៖

តាង $f(x)=\sin x$

គេបាន $f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$

$$=\lim_{h\to 0}\frac{\sin(x+h)-\sin x}{h}$$

$$=\lim_{h\to 0}\frac{2\sin\frac{h}{2}\cos(x+\frac{h}{2})}{h}$$

$$=\lim_{h\to 0}\frac{\sin\frac{h}{2}}{\frac{h}{2}}\times\lim_{h\to 0}\cos(x+\frac{h}{2})$$

$$=1\times\cos x=\cos x$$

ដូចនេះ $f(x)=\sin x$ នោះ $f'(x)=\cos x$ ។

ម្យ៉ាងទៀត $y=\sin u=\sin u(x)$

គេបាន $y'=\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}=\cos u\times u'=u'\cos u$ ។

ដូចនេះ $y=\sin u$ នោះ $y'=u'\cos u$ ។

( ចំពោះដេរីវេអនុគមន៍កូស៊ីនូស គេស្រាយដូចខាងលើដែរ ) ។

# ខ/ដេរីវេនៃអនុគមន៍តង់សង់ និង កូតង់សង់

បើ $y=\tan x$ នោះ $y'=\frac{1}{\cos^2 x}=1+\tan^2 x$

បើ $y=\cot x$ នោះ $y'=-\frac{1}{\sin^2 x}=-(1+\cot^2 x)$

បើ $y=\tan u$ នោះ $y'=\frac{u'}{\cos^2 u}=u'(1+\tan^2 u)$

បើ $y=\cot u$ នោះ $y'=-\frac{u'}{\sin^2 u}=-u'(1+\cot^2 u)$

*សម្រាយបញ្ជាក់* ៖

គេមាន $y=\tan x=\frac{\sin x}{\cos x}$ នោះគេបាន ៖

$$y'=\frac{(\sin x)'\cos x-(\cos x)'\sin x}{\cos^2 x}$$

$$=\frac{\cos^2 x+\sin^2 x}{\cos^2 x}$$

$$=\frac{1}{\cos^2 x}=1+\tan^2 x$$

ដូចនេះបើ $y=\tan x$ នោះ $y'=\frac{1}{\cos^2 x}=1+\tan^2 x$ ។

គេមាន $y=\cot x=\dfrac{\cos x}{\sin x}$ នោះគេបាន ៖

$$y'=\frac{(\cos x)'\sin x-(\sin x)'\cos x}{\sin^2 x}$$

$$=\frac{-\sin^2 x-\cos^2 x}{\sin^2 x}$$

$$=-\frac{1}{\sin^2 x}=-(1+\cot^2 x)$$

ឧទាហរណ៍ រកដេរីវេនៃអនុគមន៍ $y=\dfrac{\sin x}{1+\cos x}$

គេបាន $y'=\dfrac{(\sin x)'(1+\cos x)-(1+\cos x)'\sin x}{(1+\cos x)^2}$

$$=\frac{\cos x(1+\cos x)+\sin^2 x}{(1+\cos x)^2}$$

$$=\frac{\cos x+\cos^2 x+\sin^2 x}{(1+\cos x)^2}$$

$$=\frac{\cos x+1}{(1+\cos x)^2}=\frac{1}{1+\cos x}$$

ដូចនេះ $y'=\dfrac{1}{1+\cos x}$ ។

# លំហាត់អនុវត្តន៍

ចូរគណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

1/ $y = 3\cos x - \cos^3 x$

2/ $y = \sin^3 x \cos 3x$

3/ $y = \sin 4x \cos^4 x$

4/ $y = \dfrac{\sin x}{1 + \sin x}$

5/ $y = \dfrac{\cos x}{1 - \cos x}$

6/ $y = \dfrac{\sin x - \cos x}{\sin x + \cos x}$

7/ $y = \dfrac{1 - \tan x}{1 + \tan x}$

8/ $y = \dfrac{1}{2}\tan^2 x + \dfrac{1}{3}\tan^3 x$

9/ $y = x - \cot x$

10/ $y = \cot^4 x$

# ៤-ដេរីវេនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

បើ $y = e^x$ នោះ $y' = e^x$

បើ $y = a^x$ នោះ $y' = a^x \ln a \quad , \ a > 0 \ , a \neq 1$

បើ $y = e^u$ នោះ $y' = u'e^u$

បើ $y = a^u$ នោះ $y' = u'.a^u \ \ln a$

*សម្រាយបញ្ជាក់* ៖

តាង $f(x) = e^x$ នោះតាមនិយមន័យគេបាន ៖

$$f'(x) = \lim_{h \to 0} \frac{f(x+h) - f(x)}{h} = \lim_{h \to 0} \frac{e^{x+h} - e^x}{h}$$

$$= \lim_{h \to 0} \frac{e^h - 1}{h} . e^x = e^x \quad \text{ព្រោះ} \quad \lim_{h \to 0} \frac{e^h - 1}{h} = 1$$ ។

ដូចនេះ បើ $y = e^x$ នោះ $y' = e^x$ ។

ម្យ៉ាងទៀតយើងតាង $g(x) = a^x = e^{\ln a^x} = e^{x \ln a}$

គេបាន $g'(x) = (x \ln a)' . e^{x \ln a} = \ln a . e^{x \ln a} = a^x \ln a$

ដូចនេះ បើ $y = a^x$ នោះ $y' = a^x \ln a \quad , \ a > 0 \ , a \neq 1$ ។

ឧទាហរណ៍១ គណនាដេរីវេនៃអនុគមន៍ $y=\dfrac{e^x-e^{-x}}{e^x+e^{-x}}$

គេបាន $y'=\dfrac{(e^x-e^{-x})'(e^x+e^{-x})-(e^x+e^{-x})'(e^x-e^{-x})}{(e^x+e^{-x})^2}$

$$=\frac{(e^x+e^{-x})^2-(e^x-e^{-x})^2}{(e^x+e^{-x})^2}$$

$$=\frac{e^{2x}+2+e^{-2x}-e^{2x}+2-e^{-2x}}{(e^x+e^{-x})^2}$$

$$=\frac{4}{(e^x+e^{-x})^2}$$

ដូចនេះ $y'=\dfrac{4}{(e^x+e^{-x})^2}$ ។

ឧទាហរណ៍២ គណនាដេរីវេនៃអនុគមន៍ $y=e^{3\sin x-\sin^3 x}$

គេបាន $y'=(3\sin x-\sin^3 x)'e^{3\sin x-\sin^3 x}$

$$=(3\cos x-3\cos x\sin^2 x)e^{3\sin x-\sin^3 x}$$

$$=3\cos x(1-\sin^2 x)e^{3\sin x-\sin^3 x}$$

$$=3\cos^3 x\,e^{3\sin x-\sin^3 x}$$

## ៥-ដេរីវេនៃអនុគមន៍លោការីតនេពែ

បើ $y=\ln x$ នោះ $y'=\frac{1}{x}$

បើ $y=\ln(ax+b)$ នោះ $y'=\frac{a}{ax+b}$

បើ $y=\ln u$ នោះ $y'=\frac{u'}{u}$

*សម្រាយបញ្ជាក់* ៖

តាង $f(x)=\ln x$ នោះ $f(x+h)=\ln(x+h)$

តាមនិយមន័យ $f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$

$$=\lim_{h\to 0}\frac{\ln(x+h)-\ln x}{h}$$

$$=\lim_{h\to 0}\frac{\ln(\frac{x+h}{x})}{h}$$

$$=\lim_{h\to 0}\frac{\ln(1+\frac{h}{x})}{\frac{h}{x}}\times\frac{1}{x}=\frac{1}{x}$$

ដូចនេះបើ $f(x)=\ln x$ នោះ $f'(x)=\frac{1}{x}$ ។

ឧទាហរណ៍១ គណនាដេរីវេនៃអនុគមន៍ $y=\dfrac{1-\ln x}{1+\ln x}$

គេបាន $y'=\dfrac{(1-\ln x)'(1+\ln x)-(1+\ln x)'(1-\ln x)}{(1-\ln x)^2}$

$$=\frac{-\frac{1}{x}(1+\ln x)-\frac{1}{x}(1-\ln x)}{(1+\ln x)^2}=-\frac{2}{x(1+\ln x)^2}$$

ដូចនេះ $y'=-\dfrac{2}{x(1+\ln x)^2}$ ។

ឧទាហរណ៍២ គណនាដេរីវេនៃអនុគមន៍ $y=\ln(x+\sqrt{1+x^2})$

គេបាន $y'=\dfrac{(x+\sqrt{1+x^2})'}{x+\sqrt{1+x^2}}$

$$=\frac{1+\frac{(1+x^2)'}{2\sqrt{1+x^2}}}{x+\sqrt{1+x^2}}=\frac{1+\frac{2x}{2\sqrt{1+x^2}}}{x+\sqrt{1+x^2}}$$

$$=\frac{\sqrt{1+x^2}+x}{(x+\sqrt{1+x^2})\sqrt{1+x^2}}=\frac{1}{\sqrt{1+x^2}}$$

ដូចនេះ $y'=\dfrac{1}{\sqrt{1+x^2}}$ ។

# លំហាត់អនុវត្តន៍

គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

1/ $y=\dfrac{e^x-1}{e^x+1}$

2/ $y=(x^2-x+1)e^{-x}$

3/ $y=e^{-x^2}$

4/ $y=x^3e^{2x}$

5/ $y=(x^2-x)e^x$

6/ $y=\dfrac{e^{2x}-e^{-2x}}{2}$

៣-គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

1/ $y=\dfrac{x+\ln x}{x}$

2/ $y=\dfrac{\ln x}{x^2}$

3/ $y=1-x+x\ln x$

4/ $y=\ln\dfrac{x-1}{x+1}$

5/ $y=\ln(x^2-4x+3)$

6/ $y=\ln(x+\sqrt{x^2+4})$

# ៦-ដេរីវេលំដាប់ខ្ពស់

## ក/ដេរីវេទី2នៃអនុគមន៍

ដេរីវេទីពីរនៃអនុគមន៍ $y=f(x)$ កំណត់តាងដោយ $y''=f''(x)$

ឬកំណត់តាងដោយ $\frac{d^2y}{dx^2}=f''(x)$ ។

ឧទាហរណ៍១ គេឲ្យអនុគមន៍ $y=\ln x$ ។ គណនា $\frac{d^2y}{dx^2}$ ?

គេមាន $\frac{dy}{dx}=y'=(\ln x)'=\frac{1}{x}$

ហើយ $\frac{d^2y}{dx^2}=(y')'=\left(\frac{1}{x}\right)'=-\frac{1}{x^2}$ ។

ឧទាហរណ៍២ គេឲ្យអនុគមន៍ $y=\sin x$ ។ គណនា $\frac{d^2y}{dx^2}$ ?

គេបាន $\frac{dy}{dx}=y'=(\sin x)'=\cos x$

ហើយ $\frac{d^2y}{dx^2}=(y')'=(\cos x)'=-\sin x$ ។

ខ/ដេរីវេលំដាប់ខ្ពស់

ដេរីវេនៃអនុគមន៍ $y = f(x)$ អាចមានដេរីវេខ្លួនឯងបន្តបន្ទាប់ទៀត ។

គេហៅដេរីវេបន្តបន្ទាប់ថា ដេរីវេទី1 , ដេរីវេទី2,……,ដេរីវេទី$n$

ដែលគេកំណត់តាងដោយ $y', y'', ...., y^{(n)}$ ។

ឧទាហរណ៍ គណនាដេរីវេទី $n$ នៃអនុគមន៍ $y = \sin x$ ?

គេបាន $y' = (\sin x)' = \cos x = \sin(\frac{\pi}{2} + x)$

$$y'' = (\sin(\frac{\pi}{2} + x))' = \cos(\frac{\pi}{2} + x) = \sin(\pi + x)$$

$$y''' = (\sin(\pi + x))' = \cos(\pi + x) = \sin(\frac{3\pi}{2} + x)$$

$$-------------------------$$

ឧបមាថា $y^{(n)} = \sin(\frac{n\pi}{2} + x)$ ពិត

យើងបាន $y^{(n+1)} = \left(y^{(n)}\right)' = \cos(\frac{n\pi}{2} + x) = \sin\left(\frac{(n+1)\pi}{2} + x\right)$ ពិត

ដូចនេះ $y^{(n)} = \sin(\frac{n\pi}{2} + x)$ ។

# លំហាត់អនុវត្តន៍

១-គេឲ្យអនុគមន៍ f កំណត់ដោយ $y = f(x) = \cos x$

ចូរស្រាយថាដេរីវេទី $n$ នៃអនុគមន៍កំណត់ដោយ $y^{(n)} = \cos(x + \frac{n\pi}{2})$

២-ចូរគណនាដេរីវេទី $n$ នៃអនុគមន៍ខាងក្រោម ៖

1/ $y = \ln x$

2/ $y = e^{2x}$

3/ $y = \frac{1}{x+1}$

4/ $y = \sin^2 x$

5/ $y = \frac{1}{x} + \frac{1}{x-1}$

6/ $y = \frac{2x+3}{(x+1)(x+2)}$

៣-គេឲ្យអនុគមន៍ $y = (x-\alpha)^m (x-\beta)^n$ ដែល $m, n \in IN, \alpha \neq \beta$

ក/ ចូរស្រាយថា $x - \alpha$ ចែកដាច់ $y^{(m-1)}$

ខ/ តាង $GCD(m,n) = d$ ។

តើ $(x-\alpha)(x-\beta)$ ចែកដាច់ $y^{(d-1)}$ ឬទេ ?

៤-គេឲ្យអនុគមន៍ f កំណត់ដោយ $f(x) = (x^2 - 3x + 1)^5$ ។

ចូរគណនា $f''(0)$ រួចទាញរកលេខមេគុណមុខតួ $x^2$ នៃអនុគមន៍ $f$ ។

# ៧-ដេរីវេនៃអនុគមន៍អាំព្លីស៊ីត

## ក/ និយមន័យ

អនុគមន៍អាំព្លីស៊ីត គឺជាអនុគមន៍ដែលបញ្ជាក់ពីទំនាក់ទំនងមួយ

បំពេញលក្ខខណ្ឌរួមគ្នា ។

ឧទាហរណ៍ $x^2+y^2=a^2$ , $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ , $x^2+xy+y^2=3$ ,....

សុទ្ធតែជាអនុគមន៍អាំព្លីស៊ីត ។

## ខ/ឧទាហរណ៍គំរូ

គណនា $y'$ ដោយដឹងថា $ax^2+bxy+cy^2=d$ ។

គេបាន $(ax^2+bxy+cy^2)'=(d)'$

$$2ax+by+bxy'+2cyy'=0$$

$$(bx+2cy)y'=-(2ax+by)$$

គេទាញបាន $y'=-\frac{2ax+by}{bx+2cy}$ ។

# លំហាត់អនុវត្តន៍

១-គណនា $y'=\dfrac{dy}{dx}$ ជាអនុគមន៍ x និង y ក្នុងករណីនីមួយៗខាងក្រោម

ក/ $x^2+y^2=r^2$

ខ/ $\dfrac{x^2}{a^2}+\dfrac{y^2}{b^2}=1$

គ/ $(y-k)^2=4p(x-h)$

ឃ/ $x^{\frac{2}{3}}+y^{\frac{2}{3}}=a^{\frac{2}{3}}$

ង/ $\dfrac{(x-h)^2}{a^2}+\dfrac{(y-k)^2}{b^2}=1$

ច/ $x^3+y^3=3xy+1$

ឆ/ $\sin(xy)=\sin x+\sin y$

ជ/ $x^2-4xy+3y^2=5$

ឈ/ $x^y=y^x$

ញ/ $e^x+e^y=e^{xy}+2$

២-ចូរគណនា $y''=\dfrac{d^2y}{dx^2}$ ជាអនុគមន៍ $x, y, y'$ រួចជាអនុគមន៍នៃ $x, y$

ក្នុងករណីនីមួយៗខាងក្រោម ៖

ក/ $x^2-xy+y^2=4$

ខ/ $x^3+y^3=6xy+1$

គ/ $\dfrac{1}{x}+\dfrac{1}{y}=xy$

ឃ/ $x^2-3xy+y^2=9$

ច/ $xy+y^3=x^2+4$

ឆ/ $x^2-3xy^2+2y=0$

ជំពូកទី២

# អនុវត្តន៍ដេរីវេនៃអនុគមន៍

## ១-អនុវត្តន៍ក្នុងការគណនាតម្លៃបរមា

សន្មតថា **f** ជាអនុគមន៍មានដេរីវេទីពីរលើចន្លោះមួយដែលមាន $x_0$ ។

☞ *អតិបរមាធៀប ៖*

អនុគមន៍ **f** មានអតិបរមាធៀបត្រង់ $x_0$ កាលណា $\begin{cases} f'(x_0) = 0 \\ f''(x_0) < 0 \end{cases}$

☞ *អប្បបរមាធៀប ៖*

អនុគមន៍ **f** មានអតិបរមាធៀបត្រង់ $x_0$ កាលណា $\begin{cases} f'(x_0) = 0 \\ f''(x_0) > 0 \end{cases}$

## ២-ល្បឿន និង សំទុះនៃចលនា

### ក/ល្បឿននៃចលនា

ល្បឿននៃចលនាមួយនៅខណៈ $t$ គឺ $V'(t) = \frac{dS}{dt} = S'(t)$

ដែល $S = S(t)$ ជាចម្ងាយចរនៅខណៈ $t$ ។

*ឧទាហរណ៍* ទូកមួយចាប់ផ្តើមចេញដំណើរពីចំណុចត្រួតពិនិត្យដែល

ខណៈ $t$ នាទីក្រោយមកទូកនោះមានចម្ងាយពីចំណុចត្រួតពិនិត្យ

ដែលតាងដោយអនុគមន៍ $S(t) = t^3 + 60t$ (គិតជាម៉ែត្រ)

ក/រកល្បឿនទូកត្រង់ចំណុចចាប់ផ្តើម ។

ខ/កំណត់ល្បឿននៃទូកនៅខណៈ $t = 3$ នាទី ។

*ដំណោះស្រាយ*

ក/រកល្បឿនទូកត្រង់ចំណុចចាប់ផ្តើម ៖

គេបាន $t$ គឺ $V'(t) = \frac{dS}{dt} = S'(t) = 3t^2 + 60$

បើ $t = 0$ នោះ $V'(0) = 3(0)^2 + 60 = 60m/mn$ ។

ខ/កំណត់ល្បឿននៃទូកនៅខណៈ $t = 3$ នាទី ៖

បើ $t = 3mn$ នោះ $V'(3) = 3(3)^2 + 60 = 27 + 60 = 87m/mn$ ។

## ខ/សំទុះនៃចលនា

សំទុះនៃចលនាមួយនៅខណៈ $t$ គឺ $a'(t) = \dfrac{dV}{dt} = V'(t)$

ដែល $V = V(t)$ ជាល្បឿននៃចលនានៅខណៈ $t$ ។

*ឧទាហរណ៍* រថយន្តមួយចាប់ផ្តើមចេញដំណើរដោយល្បឿនដែលតាង

ដោយអនុគមន៍ $V(t) = \dfrac{100t}{t+15}$ $(m/s)$

កំណត់សំទុះនៃរថយន្តនៅខណៈ $t = 10s$ ?

*ដំណោះស្រាយ*

គេបាន $a(t) = \dfrac{dV}{dt} = V'(t)$ ដោយ $V(t) = \dfrac{100t}{t+15}$ $(m/s)$

នោះ $a(t) = \dfrac{100(t+15) - 100t}{(t+15)^2} = \dfrac{1500}{(t+15)^2}$

បើ $t = 10s$ នោះ $a(10) = \dfrac{1500}{(10+15)^2} = \dfrac{1500}{625} = 2.4\ m/s^2$ ។

## ៣-ឌីផេរ៉ង់ស្យែល

### និយមន័យ ៖

បើអនុគមន៍ $y = f(x)$ មានដេរីវេនោះឌីផេរ៉ង់ស្យែលកំណត់ដោយ

$dy = f'(x).dx$ ។

កាលណាតម្លៃ $\Delta x$ កាន់តែតូចនោះ $dy$ អាចជាតម្លៃប្រហែលនៃ $\Delta y$

គេបាន $f(x+\Delta x) = f(x) + \Delta y \approx f(x) + dy = f(x) + f'(x).\Delta x$ ។

ឧទាហរណ៍ ចូរគណនាតម្លៃប្រហែលនៃ $\tan 46^o$ ?

តាងអនុគមន៍ $f(x) = \tan x$

យក $x = 45^o$ និង $\Delta x = 1^o$ នោះគេបាន ៖

$f(46^o) = f(45^o) + f'(45^o).\Delta x$

ដោយ $f'(x) = (\tan x)' = \dfrac{1}{\cos^2 x} = 1 + \tan^2 x$ នោះ $f'(45^o) = 2$

គេបាន $f(46^o) = 1 + 2 \times \dfrac{3.14}{180} = 1.035$ ។

ដូចនេះ $\tan 46^o = 1.035$ ។

# ៤-វិសមភាពកំណើនមានកំណត់

## ទ្រឹស្តីបទទី១

គេឲ្យ $f$ ជាអនុគមន៍កំណត់ និង ជាប់ ហើយមានដេរីវេលើចន្លោះ $I$ ។

បើមានពីរចំនួនពិត $m$ និង $M$ ដែលគ្រប់ $x\in I$ : $m\le f'(x)\le M$

នោះគ្រប់ចំនួនពិត $a,b\in I$ ដែល $a<b$ គេបាន ៖

$m(b-a)\le f(b)-f(a)\le M(b-a)$ ។

*សម្រាយបញ្ជាក់*

តាងអនុគមន៍ $g$ ដែល $g(x)=f(x)-mx$ មានដេរីវេលើ $I$

គេបាន $g'(x)=f'(x)-m\ge 0$ គ្រប់ $x\in I$ ព្រោះ $f'(x)\ge m$ ។

នោះ $g$ ជាអនុគមន៍កើនលើចន្លោះ $I$ ។

ចំពោះគ្រប់ចំនួនពិត $a,b\in I$ ដែល $a<b$ គេបាន $g(a)\le g(b)$

ឬ $f(a)-ma\le f(b)-mb$ នោះ $f(b)-f(a)\ge m(b-a)$ (i)

តាងអនុគមន៍ $h$ ដែល $h(x)=f(x)-Mx$ មានដេរីវេលើ $I$

គេបាន $h'(x)=f'(x)-M\le 0$ គ្រប់ $x\in I$ ព្រោះ $f'(x)\le M$ ។

នោះ $h$ ជាអនុគមន៍ចុះលើចន្លោះ $I$ ។

ចំពោះគ្រប់ចំនួនពិត $a,b\in I$ ដែល $a<b$ គេបាន $h(a)\geq h(b)$

ឬ $f(a)-Ma\geq f(b)-Mb$ នោះ $f(b)-f(a)\leq M(b-a)$ (ii)

តាមទំនាក់ទំនង (i) & (ii) គេបាន ៖

$m(b-a)\leq f(b)-f(a)\leq M(b-a)$ ។

ឧទាហរណ៍ គេឲ្យអនុគមន៍ $f$ កំណត់ដោយ ៖

$f(x)=\sqrt{(2k+1)x+k^2-(2k+1)n}$ ដែល $k>0$ , $n>0$ ។

ក/កំណត់តម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[n,n+1]$ ។

ខ/ បញ្ជាក់ថាចំពោះគ្រប់ $x\in[n,n+1]$ គេបាន ៖

$$\frac{2k+1}{2(k+1)}(x-n)+k\leq f(x)\leq\frac{2k+1}{2k}(x-n)+k$$

*ដំណោះស្រាយ*

ក/កំណត់តម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[n,n+1]$

គេមាន $f'(x)=\dfrac{2k+1}{2\sqrt{(2k+1)x+k^2-(2k+1)n}}=\dfrac{2k+1}{2f(x)}$

ដោយ $f(n)=\sqrt{(2k+1)n+k^2-(2k+1)n}=k$

ហើយ $f(n+1)=\sqrt{(2k+1)(n+1)+k^2-(2k+1)n}=k+1$

នោះគ្រប់ $x\in[n,n+1]$ គេបាន $\frac{2k+1}{2(k+1)}\le f'(x)\le\frac{2k+1}{2k}$ ។

ខ/ បញ្ជាក់ថាចំពោះគ្រប់ $x\in[n,n+1]$ គេបាន ៖

$$\frac{2k+1}{2(k+1)}(x-n)+k\le f(x)\le\frac{2k+1}{2k}(x-n)+k$$

តាមសម្រាយខាងលើចំពោះគ្រប់$x\in[n,n+1]$ គេមាន ៖

$\frac{2k+1}{2(k+1)}\le f'(x)\le\frac{2k+1}{2k}$ ។ តាមវិសមភាពកំណើនមានកំណត់

ចំពោះ $x\ge n$ គេបាន ៖

$\frac{2k+1}{2(k+1)}(x-n)\le f(x)-f(n)\le\frac{2k+1}{2k}(x-n)$ ដោយ $f(n)=k$

ដូចនេះ $\frac{2k+1}{2(k+1)}(x-n)+k\le f(x)\le\frac{2k+1}{2k}(x-n)+k$ ។

# ទ្រឹស្តីបទទី២

គេឲ្យ $f$ ជាអនុគមន៍ មានដេរីវេលើចន្លោះ $[a,b]$។

បើមានពីរចំនួនពិត $M$ ដែលគ្រប់ $x\in[a,b]:\ |f'(x)|\leq M$

នោះគេបាន $|f(b)-f(a)|\leq\ M.|b-a|$ ។

*សម្រាយបញ្ជាក់*

គេមានគ្រប់ $x\in[a,b]:\ |f'(x)|\leq M$

នោះគេទាញ $-M\leq f'(x)\leq M$

តាមវិសមភាពកំណើនមានកំណត់គេបាន ៖

ចំពោះ $a<b$ គេបាន $-M(b-a)\leq f(b)-f(a)\leq M(b-a)\quad(1)$

ចំពោះ $a>b$ គេបាន $-M(a-b)\leq f(a)-f(b)\leq M(a-b)\quad(2)$

តាម(1)និង(2)គេបាន $|f(b)-f(a)|\leq\ M.|b-a|$ ។

ដូចនេះទ្រឹស្តីបទត្រូវបានស្រាយបញ្ជាក់ ។

*ឧទាហរណ៍* គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\sin x$ ។

ចំពោះគ្រប់ $\alpha,\beta\in IR$ បង្ហាញថា $|\sin\alpha-\sin\beta|\le|\alpha-\beta|$ ?

គេមាន $f(x)=\sin x$ នោះ $f'(x)=\cos x$

ចំពោះគ្រប់ $x\in IR$ គេមាន $-1\le\cos x\le 1$ នោះ $|f(x)|\le 1$

ដូចនេះគ្រប់ $\alpha,\beta\in IR$ គេបាន $|\sin\alpha-\sin\beta|\le|\alpha-\beta|$ ។

## លំហាត់អនុវត្តន៍

១-គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\sqrt{5x-1}$

ក/កំណត់តម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[1,2]$ ។

ខ/ បញ្ជាក់ថាចំពោះគ្រប់ $x\in[1,2]$ គេបាន ៖

$$\frac{5x}{6}+\frac{7}{6}\le f(x)\le\frac{5x}{4}+\frac{3}{4}$$ ។

២-គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\cos x$ ។

ចំពោះគ្រប់ $\alpha,\beta\in IR$ បង្ហាញថា $|\cos\alpha-\cos\beta|\le|\alpha-\beta|$ ?

## ៥-ទ្រឹស្តីបទរ៉ូល

បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ មានដេរីវេលើចន្លោះ$(a,b)$ និង $f(a)=f(b)$នោះមានចំនួន $c\in(a,b)$ យ៉ាងតិចដែល $f'(c)=0$ ។

*សម្រាយបញ្ជាក់* ៖

គេតាង $f(a)=f(b)=\lambda$




-ករណីទី១ បើ $f(x)=\lambda$ គ្រប់ $x\in[a,b]$ នោះ $f$ ជាអនុគមន៍ថេរលើចន្លោះ $[a,b]$ និង $f'(x)=0$ គ្រប់ $x\in(a,b)$ ។

-ករណីទី២ បើ $f(x)>\lambda$ គ្រប់ $x\in[a,b]$ នោះ $f$ មានតម្លៃអតិបរមាយ៉ាងតិចមួយត្រង់ $x=c$ ដោយ $f$ មានដេរីវេត្រង់ $x=c$ នោះ $f'(c)=0$

-ករណីទី៣ បើ $f(x)<\lambda$ គ្រប់ $x\in[a,b]$នោះ $f$ មានតម្លៃអប្បបរមាយ៉ាងតិចមួយត្រង់ $x=c$ដោយ $f$ មានដេរីវេត្រង់ $x=c$ នោះ $f'(c)=0$

ឧទាហរណ៍ គេឲ្យអនុគមន៍ $f$ កំណត់ដោយ ៖

$$f(x)=x^3-(a+b+c)x^2+(ab+bc+ca)x-abc$$

ដែល $a,b,c\in IR$ ។

ក/គណនា $f(a)$ និង $f(b)$ រួចទាញថាសមីការ $f'(x)$ មានឫសយ៉ាងតិចមួយនៅចន្លោះចំនួន $a$ និង $b$ ។

ខ/ទាញបញ្ជាក់វិសមភាព $(a+b+c)^2\geq 3(ab+bc+ca)$ ។

ដំណោះស្រាយ

ក/គណនា $f(a)$ និង $f(b)$ ៖

គេបាន $f(a)=a^3-(a+b+c)a^2+(ab+bc+ca)a-abc=0$

$$f(b)=b^3-(a+b+c)b^2+(ab+bc+ca)b-abc=0$$

ដូចនេះ $f(a)=f(b)=0$ ។

ទាញថាសមីការ $f'(x)=0$ មានឫសយ៉ាងតិចមួយនៅចន្លោះ$(a,b)$ ៖

ដោយ $f$ ជាអនុគមន៍ជាប់លើ $[a,b]$ និង មានដេរីវេលើ $(a,b)$

ហើយ $f(a)=f(b)=0$ នោះតាមទ្រឹស្តីបទរ៉ូលមាន $\alpha\in(a,b)$

ដែល $f'(\alpha)=0$ នោះមានន័យថាសមីការ $f'(x)=0$ មានឬសយ៉ាងតិចមួយនៅចន្លោះ $(a,b)$ ។

ខ/ទាញបញ្ជាក់វិសមភាព $(a+b+c)^2 \geq 3(ab+bc+ca)$

គេមាន $f'(x)=3x^2-2(a+b+c)x+(ab+bc+ca)$

ដោយ $f'(x)=0$ ជាសមីការមានឬសនោះ $\Delta' \geq 0$

តែ $\Delta'=(a+b+c)^2-3(ab+bc+ca)$

ដូចនេះ $(a+b+c)^2 \geq 3(ab+bc+ca)$ ។

## លំហាត់អនុវត្តន៍

១-គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=x^4-2x^3+2x+4$

ក/គណនា $f(-1)$ និង $f(1)$ ។

ខ/បង្ហាញថាមាន $c\in(-1,1)$ ដែល $f'(c)=0$ ។

២-គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=x^2-10x+9$

ក/រកឬស $\alpha$ និង $\beta$ របស់សមីការ $f(x)=0$

ខ/បង្ហាញថាមាន $c\in(\alpha,\beta)$ ដែល $f'(c)=0$ រួចកំណត់ $c$ ។

## ៦-ទ្រឹស្តីបទតម្លៃមធ្យម ( ឬទ្រឹស្តីបទ Lagrange )

បើ f ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ មានដេរីវេលើចន្លោះ $(a,b)$

នោះមានចំនួន $c\in(a,b)$ យ៉ាងតិចមួយដែល $f'(c)=\dfrac{f(b)-f(a)}{b-a}$ ។

*សម្រាយបញ្ជាក់* ៖




យក $g(x)=f(b)-f(x)-\lambda(b-x)$

ដែល $\lambda=\dfrac{f(b)-f(a)}{b-a}$ ។

នោះ g ជាអនុគមន៍ជាប់ក្នុងចន្លោះ $[a,b]$ និង មានដេរីវេក្នុង$(a,b)$

ហើយដោយ $g(a)=g(b)=0$នោះតាមទ្រឹស្តីបទរ៉ូលមាន $c\in(a,b)$

មួយយ៉ាងតិចដែល $g'(c)=0$ ។ ដោយ $g'(c)=-f'(c)+\lambda$

នោះ $f'(c)=\lambda$ ។ ដូចនេះ $f'(c)=\dfrac{f(b)-f(a)}{b-a}$ ។

*ឧទាហរណ៍* ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $\alpha$ និង $\beta$ ដែល $\alpha<\beta$

ចូរស្រាយថា $\frac{\beta-\alpha}{\beta}<\ln(\frac{\beta}{\alpha})<\frac{\beta-\alpha}{\alpha}$ ។

តាងអនុគមន៍ $f(x)=\ln x$ ដែល $x\in[\alpha,\beta]$ និង $0<\alpha<\beta$

គេបាន $f$ ជាអនុគមន៍ជាប់លើ $[\alpha,\beta]$ និង មានដេរីវេលើ $(\alpha\,,\beta)$

នោះតាមទ្រឹស្តីបទតម្លៃមធ្យមមាន $c\in(\alpha,\beta)$ ដែល ៖

$$f'(c)=\frac{f(\beta)-f(\alpha)}{\beta-\alpha}=\frac{\ln\beta-\ln\alpha}{\beta-\alpha}\quad(1)$$

គេមាន $f'(x)=(\ln x)'=\frac{1}{x}$ នោះ $f'(c)=\frac{1}{c}$

តែ $c\in(\alpha,\beta)$ នោះ $\alpha<c<\beta$ ឬ $\frac{1}{\beta}<\frac{1}{c}<\frac{1}{\alpha}$

គេបាន $\frac{1}{\beta}<f'(c)<\frac{1}{\alpha}\quad(2)$

តាម (1) និង (2) គេទាញ $\frac{1}{\beta}<\frac{\ln\beta-\ln\alpha}{\beta-\alpha}<\frac{1}{\alpha}$

ដូចនេះ $\frac{\beta-\alpha}{\beta}<\ln(\frac{\beta}{\alpha})<\frac{\beta-\alpha}{\alpha}$ ។

# ៧-អនុវត្តន៍ដេរីវេក្នុងសេដ្ឋកិច្ច

យើងតាង $C = C(x)$ ជាអនុគមន៍ចំណាយសរុបក្នុងការផលិតសម្ភារៈ ចំនួន x គ្រឿង , $R = R(x)$ ជាអនុគមន៍ចំណូលសរុបពីការលក់សម្ភារៈ ចំនួន x គ្រឿងនិង$P = P(x) = R(x) - C(x)$ ជាអនុគមន៍ប្រាក់ចំណេញ ពីការលក់សម្ភារៈចំនួន x គ្រឿង ។

គេបាន $C'(x)$ ហៅថាអនុគមន៍នៃប្រាក់ចំណាយបន្ថែម

$R'(x)$ ហៅថាអនុគមន៍នៃប្រាក់ចំណូលបន្ថែម

$P'(x)$ ហៅថាអនុគមន៍នៃប្រាក់ចំណេញបន្ថែម ។

*ឧទាហរណ៍* គេឲ្យអនុគមន៍ប្រាក់ចំណូលសរុបពីការលក់សម្ភារៈ x គ្រឿងនិងអនុគមន៍ប្រាក់ចំណាយសរុបលើការផលិតសម្ភារៈ x កំណត់ រៀងគ្នាដោយ $R(x) = 300x$ និង $C(x) = 1000 - 72x^2 + x^3$ ។

ក/កំណត់អនុគមន៍ប្រាក់ចំណេញសរុប ។

ខ/កំណត់បរិមាណសម្ភារៈដែលត្រូវលក់ដើម្បីឲ្យគេទទួលបានប្រាក់ ចំណេញអតិបរមា រួចកំណត់រកប្រាក់ចំណេញអតិបរមានោះ ។

*ដំណោះស្រាយ*

ក/កំណត់អនុគមន៍ប្រាក់ចំណេញសរុប

តាង $P(x)$ ជាអនុគមន៍នៃប្រាក់ចំណេញសរុបពីការលក់សម្ភារះ

គេបាន $P(x) = R(x) - C(x) = 300x - 1000 + 72x^2 - x^3$

ដូចនេះ $P(x) = -x^3 + 72x^2 + 300x - 1000$ ។

ខ/កំណត់បរិមាណសម្ភារះដែលត្រូវលក់ដើម្បីឲ្យគេទទួលបានប្រាក់

ចំណេញអតិបរមា រួចកំណត់រកប្រាក់ចំណេញអតិបរមានោះ ៖

គេមាន $P'(x) = -3x^2 + 144x + 300 = -3(x-50)(x+2)$

បើ $P'(x) = 0$ នោះ $x_1 = 50$ , $x_2 = -2$(មិនយក)

គេមាន $P''(x) = -6x + 144$ នោះ $P''(50) = -300 + 144 < 0$

នោះមានន័យថា $P(x)$ មានអតិបរមាត្រង់ $x = 50$ ។

ដូចនេះដើម្បីបានប្រាក់ចំណេញអតិបរមាគេត្រូវលក់សម្ភារះ $50$ ឯកតា

ហើយប្រាក់ចំណេញអតិបរមានោះគឺ ៖

$P_{max} = P(50) = 69,000$ ឯកតារូបិយវត្ថុ ,

ជំពូកទី៣

# សិក្សាអថេរភាព និង ក្រាបនៃអនុគមន៍

## ១-សិក្សាអនុគមន៍សនិទាន

**ក/ សិក្សាអនុគមន៍** $y=\frac{ax^2+bx+c}{px+q}$

ដែល $a\neq 0$ , $p\neq 0$ និង $ax_0^2+bx_0+c\neq 0$ គ្រប់ $x_0=-\frac{q}{p}$

☞ ដែនកំណត់ ៖ $D=IR-\{-\frac{q}{p}\}$

☞ ដេរីវេ $f'(x)=\frac{apx^2+2aqx+bq-cp}{(px+q)^2}$

-បើ $f'(x)=0$ គ្មានឫសនោះអនុគមន៍គ្មានបរមាទេ ។

-បើ $f'(x)=0$ មានឫសពីរផ្សេងគ្នានោះអនុគមន៍មានអតិបរមាមួយ និងអប្បបរមាមួយ ។

☞ អាស៊ីមតូត ៖

-បន្ទាត់ $x = -\frac{p}{q}$ ជាអាស៊ីតមតូតឈរ ។

-បើអនុគមន៍អាចសរសេរ $f(x) = \alpha x + \beta + \frac{\gamma}{px + q}$ នោះបន្ទាត់

មានសមីការ $y = \alpha x + \beta$ ជាអាស៊ីមតូតទ្រេត ។

-ចំណុចប្រសព្វរវាងអាស៊ីមតូតទាំងពីរជាផ្ចិតឆ្លុះនៃក្រាប ។

-ក្រាបមានរាងទូទៅដូចរូបខាងក្រោម ៖

1/ករណី $ap < 0$ និង $f'(x) = 0$ គ្មានឫស



2/ករណី $ap > 0$ និង $f'(x) = 0$ គ្មានឫស




3/ករណី $ap < 0$ និង $f'(x) = 0$ មានឫសពីរផ្សេងគ្នា



4/ករណី $ap>0$ និង $f'(x)=0$ មានឬសពីរផ្សេងគ្នា




ឧទាហរណ៍១ គេឲ្យអនុគមន៍ f  កំណត់ដោយ $f(x)=\frac{x^2-x-6}{x-1}$

សិក្សាអថេរភាព និង សង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយ$(o,\vec{i},\vec{j})$

•ដែនកំណត់ $D=IR-\{1\}$

•សរសេរជារាងកាណូនិក

$$f(x)=\frac{x^2-x-6}{x-1}=\frac{x(x-1)-6}{x-1}=x-\frac{6}{x-1}$$

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=(x-\frac{6}{x-1})'=1+\frac{6}{(x-1)^2}>0$ គ្រប់ $x\in D$

នោះ f ជាអនុគមន៍កើនជានិច្ចលើដែនកំណត់របស់វា ។

-គណនាលីមីត

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(x-\frac{6}{x-1})=+\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}(x-\frac{6}{x-1})=-\infty$$

$$\lim_{x\to1^-} f(x)=\lim_{x\to1^-}(x-\frac{6}{x-1})=+\infty$$

$$\lim_{x\to1^+} f(x)=\lim_{x\to1^+}(x-\frac{6}{x-1})=-\infty$$

-អាសុីមតូត

ដោយ $\lim\limits_{x\to1} f(x)=\lim\limits_{x\to1}(x-\frac{6}{x-1})=\infty$ នោះបន្ទាត់សមីការ $x=1$

ជាអាសុីមតូតឈរនៃក្រាប ។

ម្យ៉ាងទៀត $f(x)=x-\frac{6}{x-1}$ ហើយ $\lim\limits_{x\to\infty}[f(x)-x]=\lim\limits_{x\to\infty}\frac{-6}{x-1}=0$

ដូចនេះបន្ទាត់មានសមីការ $y = x$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | $1$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ |
| $f(x)$ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ |

•សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស $(x'ox)$:

$y = 0$ សមមូល $\dfrac{x^2 - x - 6}{x - 1} = 0$ ឬ $x^2 - x - 6 = 0$

$\Delta = 1 + 24 = 25$ មានឬស $x_1 = \dfrac{1-5}{2} = -2$ , $x_2 = \dfrac{1+5}{2} = 3$ ។

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស $(y'oy)$:

$x = 0$ នោះ $y = \dfrac{-6}{-1} = 6$ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x=1$ និងអាស៊ីមតូតទ្រេត $y=x$ កាត់គ្នាត្រង់ $I(1,1)$

ដោយ $f(2a-x)+f(x)=f(2-x)+f(x)$

$$=2-x-\frac{6}{1-x}+x-\frac{6}{x-1}=2=2b$$

ដូចនេះ $I(1,1)$ ជាផ្ចិតឆ្លុះនៃក្រាប ។



ឧទាហរណ៍២ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{x^2-5x+4}{2-x}$

សិក្សាអថេរភាព និង សង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយ$(o,\vec{i},\vec{j})$

•ដែនកំណត់ $D=IR-\{2\}$

•សរសេរជារាងកាណូនិក

$$f(x)=\frac{x^2-5x+4}{2-x}=-x+3-\frac{2}{2-x}$$

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=(-x+3-\dfrac{2}{2-x})'=-1-\dfrac{2}{(2-x)^2}<0\ \forall x\in D$

នោះ f ជាអនុគមន៍ចុះជានិច្ចលើដែនកំណត់របស់វា ។

-គណនាលីមីត

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}(-x+3-\frac{2}{2-x})=-\infty$$

$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}(-x+3-\frac{2}{2-x})=+\infty$$

$$\lim_{x\to2^-}f(x)=\lim_{x\to2^-}(-x+3-\frac{2}{2-x})=-\infty$$

$$\lim_{x\to 2^+} f(x) = \lim_{x\to 2^+}\left(-x+3-\frac{2}{2-x}\right) = +\infty$$

-អាស៊ីមតូត

ដោយ $\lim_{x\to 2} f(x) = \lim_{x\to 2}\left(-x+3-\frac{2}{2-x}\right) = \infty$ នោះបន្ទាត់សមីការ

$x = 2$ ជាអាស៊ីមតូតឈរនៃក្រាប ។

ម្យ៉ាងទៀត $f(x) = -x+3-\frac{2}{2-x}$ ហើយ $\lim_{x\to\infty}\frac{2}{2-x} = 0$

ដូចនេះបន្ទាត់មានសមីការ $y = -x+3$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | |
| $f(x)$ | $+\infty$ ↘ | $-\infty$ | ‖ | $+\infty$ ↘ | $-\infty$ |

•សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស័ $(x'ox)$ :

$y=0$ សមមូល $\dfrac{x^2-5x+4}{2-x}=0$ ឬ $x^2-5x+4=0$

$a+b+c=0$ មានឬស $x_1=1$ , $x_2=4$ ។

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស័ $(y'oy)$ :

$x=0$ នោះ $y=\dfrac{4}{2}=2$ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x=2$ និងអាស៊ីមតូតទ្រេត $y=-x+3$ កាត់គ្នាត្រង់

ចំណុច $I(2,1)$

ដោយ $f(2a-x)+f(x)=f(4-x)+f(x)$

$$=x-1-\frac{2}{x-2}-x+3-\frac{2}{2-x}=2=2b$$

ដូចនេះ $I(2,1)$ ជាផ្ចិតឆ្លុះនៃក្រាប ។




ឧទាហរណ៍៣ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{x^2+3x+3}{x+1}$

សិក្សាអថេរភាព និង សង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយ$(o,\vec{i},\vec{j})$

•ដែនកំណត់ $D=IR-\{-1\}$

•សរសេរជារាងកាណូនិក

$$f(x)=\frac{x^2+3x+3}{x+1}=x+2+\frac{1}{x+1}$$

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=(x+2+\frac{1}{x+1})'=1-\frac{1}{(x+1)^2}=\frac{x(x+2)}{(x+1)^2}$

$f'(x)=0$ គេបាន $x(x+2)=0$ នោះ $x_1=0$ , $x_2=-2$ ។

-បរមានៃ f

ចំពោះ $x=-2$ អនុគមន៍មានតម្លៃអតិបរមាធៀប $f(-2)=-1$ ។

ចំពោះ $x=0$ អនុគមន៍មានតម្លៃអប្បបរមាធៀប $f(0)=3$ ។

-គណនាលីមីត

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(x+2+\frac{1}{x+1})=+\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}(x+2+\frac{1}{x+1})=-\infty$$

$$\lim_{x\to-1^-} f(x)=\lim_{x\to-1^-}(x+2+\frac{1}{x+1})=-\infty$$

$$\lim_{x\to-1^+} f(x)=\lim_{x\to-1^+}(x+2+\frac{1}{x+1})=+\infty$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to -1} f(x) = \lim\limits_{x\to -1}(x+2+\frac{1}{x+1}) = \infty$ នោះបន្ទាត់សមីការ

$x=-1$ ជាអាស៊ីមតូតឈរនៃក្រាប ។

ម្យ៉ាងទៀត $f(x)=x+2+\frac{1}{x+1}$ ហើយ $\lim\limits_{x\to\infty}\frac{1}{x+1}=0$

ដូចនេះបន្ទាត់មានសមីការ $y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $3$ | ↗ | $+\infty$ |

•សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស័ $(x'ox)$ :

$y=0$ សមមូល $\frac{x^2+3x+3}{x+1}=0$ ឬ $x^2+3x+3=0$

$\Delta=9-12<0$ សមីការគ្មានឫស ។

នោះក្រាបណៃអនុគមន៍មិនកាត់អក្សអាប់ស៊ីសទេ ។

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស $(y'oy)$ :

$x=0$ នោះ $y=\frac{3}{1}=3$ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x=-1$ និងអាស៊ីមតូតទ្រេត $y=x+2$ កាត់គ្នាត្រង់

ចំណុច $I(-1,1)$ ។

ដោយ $f(2a-x)+f(x)=f(-2-x)+f(x)$

$$=-x+\frac{1}{-1-x}+x+2+\frac{1}{x+1}$$
$$=2=2b$$

ដូចនេះ $I(-1,1)$ ជាផ្ចិតឆ្លុះនៃក្រាប ។




ឧទាហរណ៍៤ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{-x^2+5x-4}{2x}$

សិក្សាអថេរភាព និង សង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយ$(o,\vec{i},\vec{j})$

•ដែនកំណត់ $D=IR^*$

•សរសេរជារាងកាណូនិក

$$f(x)=\frac{-x^2+5x-4}{2x}=-\frac{x}{2}+\frac{5}{2}-\frac{2}{x}$$

•ទិសដៅអថេរភាព

-ដេរីវេ

$$f'(x)=\left(-\frac{x}{2}+\frac{5}{2}-\frac{2}{x}\right)'=-\frac{1}{2}+\frac{2}{x^2}=\frac{-x^2+4}{x^2}=\frac{(-x+2)(x+2)}{x^2}$$

$f'(x)=0$ គេបាន $x_1=2$ , $x_2=-2$ ។

-បរមានៃ f

ចំពោះ $x=2$ អនុគមន៍មានតម្លៃអតិបរមាធៀប $f(2)=\frac{1}{2}$ ។

ចំពោះ $x=-2$ អនុគមន៍មានតម្លៃអប្បបរមាធៀប $f(-2)=\frac{9}{2}$ ។

-គណនាលីមីត

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left(-\frac{x}{2}+\frac{5}{2}-\frac{2}{x}\right)=-\infty$$

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left(-\frac{x}{2}+\frac{5}{2}-\frac{2}{x}\right)=+\infty$$

$$\lim_{x\to0^-} f(x)=\lim_{x\to0^-}\left(-\frac{x}{2}+\frac{5}{2}-\frac{2}{x}\right)=+\infty$$

$$\lim_{x\to 0^+} f(x) = \lim_{x\to 0^+}\left(-\frac{x}{2}+\frac{5}{2}-\frac{2}{x}\right) = -\infty$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to 0} f(x) = \lim\limits_{x\to}\left(-\frac{x}{2}+\frac{5}{2}-\frac{2}{x}\right) = \infty$ នោះបន្ទាត់សមីការ

$x = 0$ ជាអាស៊ីមតូតឈរនៃក្រាប ។

ម្យ៉ាងទៀត $f(x) = -\frac{x}{2}+\frac{5}{2}-\frac{2}{x}$ ហើយ $\lim\limits_{x\to\infty}\left(-\frac{2}{x}\right) = 0$

ដូចនេះបន្ទាត់មានសមីការ $y = -\frac{x}{2}+\frac{5}{2}$ ជាអាស៊ីមតូតទ្រេតនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $-2$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | | $+$ | ‖ | $+$ | | $-$ | |
| $f(x)$ | $+\infty$ | ↘ | $\frac{9}{2}$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $\frac{1}{2}$ | ↘ | $-\infty$ |

•សំណង់ក្រាប

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស $(x'ox)$:

$y=0$ សមមូល $\frac{-x^2+5x-4}{2x}=0$ ឬ $-x^2+5x-4=0$

$a+b+c=0$ សមីការមានឫស $x_1=1$ , $x_2=4$ ។

-ចំណុចប្រសព្វរវាងក្រាបនិងអក្ស $(y'oy)$:

$x=0$ នោះ $y=\frac{3}{1}=3$ ។

-ផ្ចិតឆ្លុះ

អាស៊ីមតូតឈរ $x=0$ និងអាស៊ីមតូតទ្រេត $y=-\frac{x}{2}+\frac{5}{2}$ កាត់គ្នាត្រង់

ចំណុច $I(0,\frac{5}{2})$ ។

ដោយ $f(2a-x)+f(x)=f(-x)+f(x)$

$$=\frac{x}{2}+\frac{5}{2}+\frac{2}{x}-\frac{x}{2}+\frac{5}{2}-\frac{2}{x}$$
$$=5=2b$$

ដូចនេះ $I(0,\frac{5}{2})$ ជាផ្ចិតឆ្លុះនៃក្រាប ។




# លំហាត់អនុវត្តន៍

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម ៖

១/ $y=\frac{x^2-5x+7}{x-2}$

២/ $y=\frac{x^2-x+1}{2x}$

៣/ $y=\frac{x^2+2x-3}{x+1}$

៤/ $y=x+2+\frac{4}{x}$

៥/ $y=x-2+\frac{1}{x-1}$

៦/ $y=-x+3+\frac{4}{x+1}$

**ខ/សិក្សាអនុគមន៍** $y = \dfrac{ax^2+bx+c}{px^2+qx+r}$

ដែល $a \neq 0$ និង $p \neq 0$ ។

☞ ដែនកំណត់ ៖ $D = \{x / px^2+qx+r \neq 0\}$

☞ ដេរីវេ $f'(x) = \dfrac{(aq-bp)x^2+2(ar-cp)x+(br-cq)}{(px^2+qx+r)^2}$

-បើ $f'(x)=0$ គ្មានឬសនោះអនុគមន៍គ្មានបរមាទេ ។

-បើ $f'(x)=0$ មានឬសពីរផ្សេងគ្នានោះអនុគមន៍មានអតិបរមាមួយ

និងអប្បបរមាមួយ ។

-បើ $f'(x)=0$ មានឬសតែមួយនោះអនុគមន៍មានបរមាតែមួយគត់ ។

☞ អាស៊ីមតូត ៖

-បន្ទាត់ $y = \dfrac{a}{p}$ ជាអាស៊ីតមតូតដេកជានិច្ច។

-ចំនួនអាស៊ីមតូតឈរអាស្រ័យនឹងឬសរបស់សមីការភាគបែង

$px^2+qx+r=0$ ដែលមាន $\Delta = q^2-4pr$ ។

✓ បើ $\Delta = q^2 - 4pr < 0$ គ្មានអាស៊ីមតូតឈរ និង ក្រាបមានតែមួយ

✓ បើ $\Delta = q^2 - 4pr = 0$ មានអាស៊ីមតូតឈរ $x = -\frac{q}{2p}$ និង ក្រាប

មានពីរមែកដាច់ពីគ្នា ។

✓ បើ $\Delta = q^2 - 4pr > 0$ មានអាស៊ីមតូតឈរពីរ $x = \frac{-q \pm \sqrt{\Delta}}{2p}$

និង ក្រាបមានបីមែកដាច់ពីគ្នា។

-ក្រាបមានរាងទូទៅដូចរូបខាងក្រោម ៖

1/ករណី $\Delta = q^2 - 4pr < 0$




y
1
0
1
x


y
1
0
1
x


y
1
0
1
x

2/ករណី $\Delta = q^2 - 4pr = 0$







y
1
0
1
x


y
1
0
1
x

3/ករណី $\Delta = q^2 - 4pr > 0$







y
1
0
1
x


y
1
0
1
x

ឧទាហរណ៍១ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{x^2-2x-3}{x^2-2x+2}$

សិក្សាអថេរភាពនិងសង់ក្រាបតាងf ក្នុងតម្រុយអរតូនរម៉ាល់$(o,\vec{i},\vec{j})$ ។

•ដែនកំណត់

គេមាន $x^2-2x+2=(x-1)^2+1>0\ \ \forall x\in IR$

ដូចនេះ $D=IR$ ។

•សរសេរជារាងកាណូនិក

$$f(x)=\frac{x^2-2x-3}{x^2-2x+2}=1-\frac{5}{x^2-2x+2}$$

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=(1-\dfrac{5}{x^2-2x+2})'=\dfrac{5(2x-2)}{(x^2-2x+2)^2}$

$f'(x)=0$ គេបាន $\dfrac{5(2x-2)}{(x^2-2x+2)^2}=0$ នោះ $x=1$

ចំពោះ $x=1$ នាំឲ្យ $f(1)=1-5=-4$ ។

អនុគមន៍មានអប្បបរមាធៀបស្មើនឹង $-4$ ត្រង់ $x=1$ ។

-គណនាលីមីត ៖

$$\lim_{x\to\pm\infty} f(x) = \lim_{x\to\pm\infty}\left(1-\frac{5}{x^2-2x+2}\right)=1$$

-អាស៊ីមតូត ដោយ $\lim_{x\to\infty} f(x)=1$ នោះបន្ទាត់ $y=1$ ជាអាស៊ីមតូតដេក

នៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $1$ | $\searrow$ | $-4$ | $\nearrow$ | $1$ |

•សំណង់ក្រាប ៖

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អាប់ស៊ីស $y=0$ នោះ $x^2-2x-3=0$

គេទាញឫស $x_1=-1$ , $x_2=3$ ។

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អរដោនេ $x=0$ នោះ $y=-\frac{3}{2}$




ឧទាហរណ៍២ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{x^2+6x}{2(x^2-2x+2)}$

សិក្សាអថេរភាពនិងសង់ក្រាបតាង f ក្នុងតម្រុយអរតូនរម៉ាល់ $(o,\vec{i},\vec{j})$ ។

•ដែនកំណត់

គេមាន $x^2-2x+2=(x-1)^2+1>0 \quad \forall x\in IR$

ដូចនេះ $D=IR$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(2x+6)(x^2-2x+2)-(2x-2)(x^2+6x)}{2(x^2-2x+2)^2}$

$f'(x)=\dfrac{-8x^2+4x+12}{2(x^2-2x+2)^2}$ ។

បើ $f'(x)=0$ គេបាន $\dfrac{-8x^2+4x+12}{2(x^2-2x+2)^2}=0$

នោះ $-8x^2+4x+12=0$ នាំឲ្យ $x_1=-1\ ,\ x_2=\dfrac{3}{2}$

ចំពោះ $x=-1$ នាំឲ្យ $f(-1)=\dfrac{-5}{10}=-\dfrac{1}{2}$ ។

ចំពោះ $x=\dfrac{3}{2}$ នាំឲ្យ $f(\dfrac{3}{2})=\dfrac{9}{2}$

អនុគមន៍មានអប្បបរមាធៀបស្មើនឹង $-\dfrac{1}{2}$ ត្រង់ $x=-1$

និង មានអតិបរមាធៀបស្មើនឹង $\dfrac{9}{2}$ ត្រង់ $x=\dfrac{3}{2}$ ។

-គណនាលីមីត ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{x^2+6x}{2(x^2-2x+2)}=\frac{1}{2}$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to\infty} f(x)=\frac{1}{2}$ នោះបន្ទាត់ $y=\frac{1}{2}$ ជាអាស៊ីមតូតដេកនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $\frac{3}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $f(x)$ | $\frac{1}{2}$ | $\searrow$ | $-\frac{1}{2}$ | $\nearrow$ | $\frac{9}{2}$ | $\searrow$ | $\frac{1}{2}$ |

•សំណង់ក្រាប ៖

-ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្សអាប់ស៊ីស $y=0$ នោះ $x^2-2x-3=0$

គេទាញឫស $x_1=-1$ , $x_2=3$ ។

-ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្សអរដោនេ $x=0$ នោះ $y=-\frac{3}{2}$




ឧទាហរណ៍៣ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\frac{x^2-4x}{x^2-4x+3}$

សិក្សាអថេរភាពនិងសង់ក្រាបតាង f ក្នុងតម្រុយអរតូនរម៉ាល់ $(o,\vec{i},\vec{j})$ ។

•ដែនកំណត់

គេមាន $x^2-4x+3=(x-1)(x-3)$

ដូចនេះ $D = IR - \{\ 1\ ,\ 3\ \}$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\frac{(2x+6)(x^2-2x+2)-(2x-2)(x^2+6x)}{2(x^2-2x+2)^2}$

$$f'(x)=\frac{3x-6}{(x^2-4x+3)^2}=\frac{3(x-2)}{(x^2-4x+3)^2}$$ ។

បើ $f'(x)=0$ គេបាន $\frac{3(x-2)}{(x^2-4x+3)^2}=0$ នាំឲ្យ $x=2$ ។

ចំពោះ $x=2$ នាំឲ្យ $f(2)=4$ ។

អនុគមន៍មានអប្បបរមាធៀបស្មើនឹង 4 ត្រង់ $x=2$ ។

-គណនាលីមីត ៖

$$\lim_{x\to1^-} f(x)=\lim_{x\to1^-}\frac{x^2-4x}{(x-1)(x-3)}=-\infty$$

$$\lim_{x\to1^+} f(x)=\lim_{x\to1^+}\frac{x^2-4x}{(x-1)(x-3)}=+\infty$$

$$\lim_{x\to3^-} f(x)=\lim_{x\to3^-}\frac{x^2-4x}{(x-1)(x-3)}=+\infty$$

$$\lim_{x\to3^+} f(x)=\lim_{x\to3^+}\frac{x^2-4x}{(x-1)(x-3)}=-\infty$$

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{x^2-4x}{(x-1)(x-3)}=\lim_{x\to\pm\infty}\frac{x^2}{x^2}=1$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to 1} f(x)=\infty$ និង $\lim\limits_{x\to 3} f(x)=\infty$ នោះបន្ទាត់ $x=1$ និង $x=3$

ជាអាស៊ីមតូតឈរនៃក្រាប ។ ហើយ $\lim\limits_{x\to\infty} f(x)=1$ នោះបន្ទាត់ $y=1$

ជាអាស៊ីមតូតដេកនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | $0$ | $+$ | ‖ | $+$ | |
| $f(x)$ | $1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $4$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $1$ |

•សំណង់ក្រាប ៖

-ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្សអាប់ស៊ីស $y=0$ នោះ $x^2-4x=0$

គេទាញឬស $x_1=0$ , $x_2=4$ ។

-ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្សអរដោនេ $x=0$ នោះ $y=0$




ឧទាហរណ៍៤ គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{2x^2+6x-4}{x^2+2x-3}$

សិក្សាអថេរភាពនិងសង់ក្រាបតាង$f$ ក្នុងតម្រុយអរតូនរម៉ាល់$(o,\vec{i},\vec{j})$។

•ដែនកំណត់

គេមាន $x^2+2x-3=(x-1)(x+3)$

ដូចនេះ $D=IR-\{-3,1\}$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(4x+6)(x^2+2x-3)-(2x+2)(2x^2+6x-4)}{(x^2+2x-3)^2}$

$$f'(x)=\frac{-2x^2-4x-10}{(x^2+2x-3)^2}=-\frac{2[(x+1)^2+4]}{(x^2+2x-3)^2}$$ ។

ដោយ $(x+1)^2+4>0$ នោះ $f'(x)<0\ \forall x\in D$

នោះ $f$ ជាអនុគមន៍ចុះលើដែនកំណត់ ។

-គណនាលីមីត ៖

$$\lim_{x\to1^-}f(x)=\lim_{x\to1^-}\frac{2x^2+6x-4}{(x-1)(x+3)}=-\infty$$

$$\lim_{x\to1^+}f(x)=\lim_{x\to1^+}\frac{2x^2+6x-4}{(x-1)(x+3)}=+\infty$$

$$\lim_{x\to-3^-}f(x)=\lim_{x\to3^-}\frac{2x^2+6x-4}{(x-1)(x+3)}=-\infty$$

$$\lim_{x\to-3^+}f(x)=\lim_{x\to-3^+}\frac{2x^2+6x-4}{(x-1)(x+3)}=+\infty$$

$$\lim_{x\to\pm\infty}f(x)=\lim_{x\to\pm\infty}\frac{2x^2+6x-4}{(x-1)(x+3)}=\lim_{x\to\pm\infty}\frac{2x^2}{x^2}=2$$

-អាស៊ីមតូត

ដោយ $\lim_{x\to 1} f(x)=\infty$ និង $\lim_{x\to -3} f(x)=\infty$ នោះបន្ទាត់ $x=1$ និង $x=-3$

ជាអាស៊ីមតូតឈរនៃក្រាប ។ ហើយ $\lim_{x\to\infty} f(x)=2$ នោះបន្ទាត់ $y=2$

ជាអាស៊ីមតូតដេកនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $-3$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | \|\| | $-$ | \|\| | $-$ | |
| $f(x)$ | $2$ ↘ | | $-\infty$ \|\| $+\infty$ | ↘ | $-\infty$ \|\| $+\infty$ | ↘ | $2$ |

•សំណង់ក្រាប ៖

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អាប់ស៊ី $y=0$ នោះ $2x^2+6x-4=0$

គេទាញឫស $x_1=\frac{-3-\sqrt{17}}{2}$ , $x_2=\frac{-3+\sqrt{17}}{2}$ ។

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អរដោនេ $x=0$ នោះ $y=\frac{4}{3}$




ឧទាហរណ៍៥ គេឲ្យអនុគមន៍ **f** កំណត់ដោយ $\mathbf{f(x)=\dfrac{2x^2-x-7}{x^2-x-2}}$

សិក្សាអថេរភាពនិងសង់ក្រាបតាង**f** ក្នុងតម្រុយអរតូនរម៉ាល់$\mathbf{(o,\vec{i},\vec{j})}$។

•ដែនកំណត់

គេមាន $\mathbf{x^2-x-2=(x+1)(x-2)}$

ដូចនេះ $\mathbf{D=IR-\{\,-1\,,\,2\,\}}$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(4x-1)(x^2-x-2)-(2x-1)(2x^2-x-7)}{(x^2+2x-3)^2}$

$f'(x)=\dfrac{-x^2+6x-5}{(x^2-x-2)^2}$ ។

បើ $f'(x)=0$ គេបាន $\dfrac{-x^2+6x-5}{(x^2-x-2)^2}=0$

នោះ $-x^2+6x-5=0$ នាំឲ្យ $x_1=1$ , $x_2=5$

ចំពោះ $x=1$ នាំឲ្យ $f(1)=3$ ហើយ $x=3$ នាំឲ្យ $f(3)=\dfrac{2}{3}$

អនុគមន៍មានអប្បបរមាធៀបស្មើនឹង 3 ត្រង់ $x=1$

និង មានអតិបរមាធៀបស្មើនឹង $\dfrac{2}{3}$ ត្រង់ $x=3$ ។

-គណនាលីមីត ៖

$$\lim_{x\to -1^-} f(x)=\lim_{x\to -1^-}\frac{2x^2-x-7}{(x+1)(x-2)}=-\infty$$

$$\lim_{x\to -1^+} f(x)=\lim_{x\to -1^+}\frac{2x^2-x-7}{(x+1)(x-2)}=+\infty$$

$$\lim_{x\to 2^-} f(x) = \lim_{x\to 2^-} \frac{2x^2 - x - 7}{(x+1)(x-2)} = +\infty$$

$$\lim_{x\to 2^+} f(x) = \lim_{x\to 2^+} \frac{2x^2 - x - 7}{(x+1)(x-2)} = +\infty$$

$$\lim_{x\to \pm} f(x) = \lim_{x\to \pm\infty} \frac{2x^2 - x - 7}{(x+1)(x-2)} = 2$$

-អាស៊ីមតូត

ដោយ $\lim_{x\to -1} f(x) = \infty$ និង $\lim_{x\to 2} f(x) = \infty$ នោះបន្ទាត់ $x = -1$ និង $x = 2$

ជាអាស៊ីមតូតឈរនៃក្រាប ។ ហើយ $\lim_{x\to\infty} f(x) = 2$ នោះបន្ទាត់ $y = 2$

ជាអាស៊ីមតូតដេកនៃក្រាប ។

-តារាងអថេរភាព

| x | $-\infty$ | | $-1$ | | $1$ | | $2$ | | $5$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | | $+$ | ‖ | $+$ | | $-$ | |
| $f(x)$ | $2$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $3$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $\frac{2}{3}$ | ↘ | $2$ |

•សំណង់ក្រាប ៖

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អាប់ស៊ី $\mathbf{y=0}$ នោះ $\mathbf{2x^2-x-7=0}$

គេទាញឫស $\mathbf{x_1=\frac{1-\sqrt{57}}{4}}$ , $\mathbf{x_2=\frac{1+\sqrt{57}}{4}}$ ។

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អរដោនេ $\mathbf{x=0}$ នោះ $\mathbf{y=\frac{7}{2}}$ ។



ឧទាហរណ៍៦ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{x^2+2x-7}{x^2-2x+1}$

សិក្សាអថេរភាពនិងសង់ក្រាបតាងf ក្នុងតម្រុយអរតូនរម៉ាល់$(o,\vec{i},\vec{j})$។

•ដែនកំណត់

គេមាន $x^2-2x+1=(x-1)^2$

ដូចនេះ $D=IR-\{\ 1\ \ \}$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(2x+2)(x-1)^2-2(x-1)(x^2+2x-7)}{(x-1)^4}$

$$f'(x)=\frac{-4x+12}{(x-1)^3}$$ ។

បើ $f'(x)=0$ គេបាន $\dfrac{-4x+12}{(x-1)^3}=0$ នោះ $x=3$ ។

ចំពោះ $x=3$ នាំឲ្យ $f(3)=2$ ។

អនុគមន៍មានអតិបរមាធៀបស្មើនឹង $2$ត្រង់ $x=3$ ។

-គណនាលីមីត ៖

$$\lim_{x\to 1^-} f(x) = \lim_{x\to 1^-} \frac{x^2+2x-7}{(x-1)^2} = -\infty$$

$$\lim_{x\to 1^+} f(x) = \lim_{x\to 1^+} \frac{x^2+2x-7}{(x-1)^2} = -\infty$$

$$\lim_{x\to \pm\infty} f(x) = \lim_{x\to \pm\infty} \frac{x^2+2x-7}{(x-1)^2} = 1$$

-អាស៊ីមតូត

ដោយ $\lim\limits_{x\to 1} f(x) = -\infty$ នោះបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប ។

ហើយ $\lim\limits_{x\to \infty} f(x) = 1$ នោះបន្ទាត់ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $1$ ↘ $-\infty$ | | ‖ | $-\infty$ ↗ | $2$ | ↘ | $1$ |

•សំណង់ក្រាប ៖

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អាប់ស៊ី $\mathbf{y=0}$ នោះ $\mathbf{x^2+2x-7=0}$

គេទាញឬស $\mathbf{x_1=-1-2\sqrt{2}}$ , $\mathbf{x_2=-1+2\sqrt{2}}$ ។

-ចំណុចប្រសព្វរវាងក្រាបនឹងអក្ស័អរដោនេ $\mathbf{x=0}$ នោះ $\mathbf{y=-7}$ ។



# ៣-សិក្សាអនុគមន៍អសនិទាន

## ក/សិក្សាអនុគមន៍ $y=\sqrt{ax+b}$ , $a\neq 0$

☞ ដែនកំណត់ ៖ $D=\{x\,/\,ax+b\geq 0\}$

☞ ដេរីវេ $f'(x)=\dfrac{a}{2\sqrt{ax+b}}$

-បើ $a>0$ នោះ $f'(x)>0$ នោះ f ជាអនុគមន៍កើនដាច់ខាត។

-បើ $a<0$ នោះ $f'(x)<0$ នោះ f ជាអនុគមន៍ចុះដាច់ខាត។

☞ ក្រាបមានរូបដូចខាងក្រោម ៖






ឧទាហរណ៍១ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\sqrt{2x+6}$

សិក្សាអថេរភាពនិងសង់ក្រាបតាងf ក្នុងតម្រុយអរតូនរម៉ាល់$(o,\vec{i},\vec{j})$។

•ដែនកំណត់ $D=[-3\ ,+\infty)$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(2x+6)'}{2\sqrt{2x+6}}=\dfrac{1}{\sqrt{2x+6}}>0\ \forall x\in D$

គេបាន f ជាអនុគមន៍កើនជានិច្ចលើដែនកំណត់របស់វា ។

-រកលីមីត $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\sqrt{2x+6}=+\infty$

-តារាងអថេរភាព

| $x$ | $-3$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $0$ | $\nearrow$ | $+\infty$ |

•សំណង់ក្រាប

-កូអរដោនេចំណុចប្រសព្វរវាងក្រាបនិងអក្ស័ $(ox)$ គឺ $y = 0$

គេបាន $\sqrt{2x+6} = 0$ នោះ $x = -3$ ។

-កូអរដោនេចំណុចប្រសព្វរវាងក្រាបនិងអក្ស័ $(oy)$ គឺ $x = 0$

គេបាន $y = \sqrt{6}$ ។

ដូចនេះក្រាបកាត់អក្ស័អាប់ស៊ីសត្រង់ចំណុច $(-3, 0)$ និងអក្ស័អរដោនេ

ត្រង់ចំណុច $(0, \sqrt{6})$ ។



ឧទាហរណ៍២ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\sqrt{-2x+4}$

សិក្សាអថេរភាពនិងសង់ក្រាបតាងf ក្នុងតម្រុយអរតូនរម៉ាល់$(o,\vec{i},\vec{j})$។

•ដែនកំណត់ $D=(-\infty\ ,\ 2]$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(-2x+4)'}{2\sqrt{-2x+4}}=-\dfrac{1}{\sqrt{-2x+4}}<0\ \forall x\in D$

គេបាន f ជាអនុគមន៍ចុះជានិច្ចលើដែនកំណត់របស់វា ។

-រកលីមីត $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\sqrt{-2x+4}=+\infty$

-តារាងអថេរភាព

| | | |
|---|---|---|
| $x$ | $-\infty$ | $2$ |
| $f'(x)$ | $-$ | |
| $f(x)$ | $+\infty$ ↘ | $0$ |

•សំណង់ក្រាប

-កូអរដោនេចំណុចប្រសព្វរវាងក្រាបនិងអក្ស័ (ox) គឺ $y=0$

គេបាន $\sqrt{-2x+4}=0$ នោះ $x=2$ ។

-កូអរដោនេចំណុចប្រសព្វរវាងក្រាបនិងអក្ស័ (oy) គឺ $x=0$

គេបាន $y=2$ ។

ដូចនេះក្រាបកាត់អក្ស័អាប់ស៊ីសត្រង់ចំណុច $(2,0)$ និងអក្ស័អរដោនេត្រង់ចំណុច $(0,2)$ ។



## ខ/សិក្សាអនុគមន៍ $y=\sqrt{ax^2+bx+c}$

ដែល $a\neq 0$ និង $\Delta=b^2-4ac$ ។

☞ ដែនកំណត់ ៖ $D=\{x / ax^2+bx+c\geq 0\}$

☞ ដេរីវេ $f'(x)=\dfrac{2ax+b}{2\sqrt{ax^2+bx+c}}$

☞ អាស៊ីមតូត ៖

-បើ $a<0$ នោះក្រាបគ្មានអាស៊ីមតូតទេ

-បើ $a>0$ នោះក្រាបមានអាស៊ីមតូតពីរ ។

$$f(x)=\sqrt{ax^2+bx+c}=\sqrt{a}\,|x+\frac{b}{2a}|+\varepsilon(x)$$

ដែល $\lim\limits_{x\to\infty}\varepsilon(x)=0$

កាលណា $x\to-\infty$ នោះក្រាបមានអាស៊ីមតូតទ្រេត $y=\sqrt{a}(x+\dfrac{b}{2a})$

កាលណា $x\to-\infty$ នោះក្រាបមានអាស៊ីមតូតទ្រេត $y=-\sqrt{a}(x+\dfrac{b}{2a})$

☞ ក្រាបមានរូបដូចខាងក្រោម ៖

-ករណីទី១ $a > 0$ , $\Delta > 0$




-ករណីទី២ $a < 0$ , $\Delta > 0$



-ករណីទី៣ $a > 0$ , $\Delta < 0$




ឧទាហរណ៍១ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x) = \sqrt{x^2 - 4x + 13}$

សិក្សាអថេរភាពនិងសង់ក្រាបតាងf ក្នុងតម្រុយអរតូនរម៉ាល់$(o, \vec{i}, \vec{j})$។

•ដែនកំណត់ $D = IR$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x) = \frac{(x^2 - 4x + 13)'}{2\sqrt{x^2 - 4x + 13}} = \frac{x - 2}{\sqrt{x^2 - 4x + 13}}$

$f'(x) = 0$ នាំឲ្យ $x = 2$ ។

ចំពោះ $x=2$ នាំឲ្យ $f(2)=\sqrt{4-8+13}=3$ ។

អនុគមន៍ $f$ មានអប្បបរមាស្មើ 3 ត្រង់ $x=2$ ។

-រកលីមីត $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\sqrt{x^2-4x+13}=+\infty$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\sqrt{x^2-4x+13}=+\infty$$

-សមីការអាស៊ីមតូត

គេមាន $f(x)=\sqrt{x^2-4x+13}=\sqrt{(x-2)^2+9}=|x-2|+\varepsilon(x)$

ដោយ $\lim\limits_{x\to-\infty}\varepsilon(x)=0$ និង $\lim\limits_{x\to+\infty}\varepsilon(x)=0$ នោះបន្ទាត់ $y=-(x-2)$

និង $y=x-2$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប ។

-តារាងអថេរភាព

| $x$ | $-\infty$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | ↘ | $3$ | ↗ | $+\infty$ |

•សំណង់ក្រាប

-កូអរដោនេចំណុចប្រសព្វរវាងក្រាបនិងអក្ស័ (ox) គឺ $y=0$

គេបាន $\sqrt{x^2-4x+13}=0$ នោះ $x^2-4x+13=0$

$\Delta'=4-13=-9<0$ នោះសមីការគ្មានឫស ។

- ចំណុចប្រសព្វរវាងក្រាបនិងអក្ស័ (oy) គឺ $x=0$ នោះ $y=\sqrt{13}$

-អក្ស័ឆ្លុះ បន្ទាត់ $x=2$ ព្រោះ $f(2a-x)=f(x)$

ឬ $f(4-x)=\sqrt{(4-x)^2-4(4-x)+13}=\sqrt{x^2-4x+13}=f(x)$



ឧទាហរណ៍២ គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\sqrt{x^2-6x+5}$

សិក្សាអថេរភាពនិងសង់ក្រាបតាង$f$ ក្នុងតម្រុយអរតូនរម៉ាល់$(o,\vec{i},\vec{j})$។

•ដែនកំណត់ $D=(-\infty,1]\cup[5,+\infty)$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(x^2-6x+5)'}{2\sqrt{x^2-6x+5}}=\dfrac{x-3}{\sqrt{x^2-6x+5}}$

គ្រប់$x\in(-\infty,1]$ គេបាន $f'(x)\le 0$ និ $x\in(5,+\infty]$ គេបាន$f'(x)>0$

ដូចនេះអនុគមន៍ $f$ ចុះលើចន្លោះ$x\in(-\infty,1]$និងកើនលើ$x\in(5,+\infty]$

-រកលីមីត $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\sqrt{x^2-6x+5}=+\infty$

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\sqrt{x^2-6x+5}=+\infty$$

-សមីការអាស៊ីមតូត

គេមាន $f(x)=\sqrt{x^2-6x+5}=\sqrt{(x-3)^2-4}=|x-3|+\varepsilon(x)$

ដោយ $\lim\limits_{x\to-\infty}\varepsilon(x)=0$ និង $\lim\limits_{x\to+\infty}\varepsilon(x)=0$ នោះបន្ទាត់ $y=-(x-3)$

និង $y=x-3$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប ។

-តារាងអថេរភាព

| x | $-\infty$ | | 1 | | 5 | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | 0 | | 0 | $+$ | |
| $f(x)$ | $+\infty$ | ↘ | 0 | | 0 | ↗ | $+\infty$ |

•សំណង់ក្រាប



ឧទាហរណ៍៣ គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\sqrt{-x^2-2x+8}$

សិក្សាអថេរភាពនិងសង់ក្រាបតាង$f$ ក្នុងតម្រុយអរតូនរម៉ាល់$(o, \vec{i}, \vec{j})$។

•ដែនកំណត់ $D=[-4\ ,\ 2]$ ។

•ទិសដៅអថេរភាព

-ដេរីវេ $f'(x)=\dfrac{(-x^2-2x+8)'}{2\sqrt{-x^2-2x+8}}=\dfrac{-x-1}{\sqrt{-x^2-2x+8}}$

$f'(x)=0$ គេបាន $\dfrac{-x-1}{\sqrt{-x^2-2x+8}}=0$ នាំឲ្យ $x=-1$ ។

អនុគមន៍មានអតិបរមាធៀបត្រង់ $x=-1$ គឺ $f(-1)=3$

-តារាងអថេរភាព

| $x$ | $-4$ | | $-1$ | | $2$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $0$ | ↗ | $3$ | ↘ | $0$ |

•សំណង់ក្រាប

គេមាន $y = \sqrt{-x^2 - 2x + 8} = \sqrt{9 - (x+1)^2}$

សមមូល $\begin{cases} (x+1)^2 + y^2 = 9 \\ y \geq 0 \end{cases}$

ដូចនេះក្រាបគឺជាកន្លះរង្វង់ដែលមានផ្ចិត $I(-1,0)$ និងកាំ $R = 3$ ។



# លំហាត់អនុវត្តន៍

១-ចូរសិក្សាអថេរភាព និង សង់ក្រាបតាងអនុគមន៍ខាងក្រោម ៖

ក/ $\mathbf{y=\sqrt{x}}$

ខ/ $\mathbf{y=\sqrt{2x+4}}$

គ/ $\mathbf{y=\sqrt{4-x}}$

ឃ/ $\mathbf{y=\sqrt{-\frac{x}{2}+1}}$

ង/ $\mathbf{y=\sqrt{x^2+4}}$

ច/ $\mathbf{y=\sqrt{x^2-4x}}$

ឆ/ $\mathbf{y=\sqrt{x^2-2x+10}}$

ជ/ $\mathbf{y=\sqrt{x^2-4x+3}}$

ឈ/ $\mathbf{y=\sqrt{x^2-4x-5}}$

ញ/ $\mathbf{y=\sqrt{3+2x-x^2}}$

២-គេឲ្យអនុគមន៍ $\mathbf{f}$ កំណត់ដោយ $\mathbf{f(x)=\sqrt{ax^2+bx+c}}$

ក/កំណត់លេខមេគុណ $\mathbf{a,b,c}$ ដើម្បីឲ្យក្រាប $\mathbf{(c)}$ តាង $\mathbf{f}$ មាន អប្បបរមាស្មើ $\mathbf{3}$ ត្រង់ $\mathbf{x=2}$ និងកាត់តាមចំណុច $\mathbf{A(0,\sqrt{13})}$ ។

ខ/ចំពោះតម្លៃ $\mathbf{a,b,c}$ ដែលបានរកឃើញខាងលើចូរសិក្សាអថេរភាព និងគូសក្រាប $\mathbf{(c)}$ ក្នុងតម្រុយអរតូណរម៉ាល់ $\mathbf{(o,\vec{i},\vec{j})}$ ។

## ៣-អនុគមន៍អិចស្ប៉ូណង់ស្យែល

*រំលឹករូបមន្តលីមីត ៖*

1/ $\lim_{x\to+\infty} e^{x} = +\infty$

2/ $\lim_{x\to+\infty} e^{-x} = 0$

3/ $\lim_{x\to+\infty} \frac{e^{x}}{x^{n}} = +\infty\ , n > 0$

4/ $\lim_{x\to+\infty} \frac{x^{n}}{e^{x}} = 0\ ,\ n > 0$

*រំលឹករូបមន្តដេរីវេ ៖*

1/ បើ $y = e^{x}$ នោះ $y' = e^{x}$

2/ បើ $y = e^{u(x)}$ នោះ $y' = u'(x)e^{u(x)}$

ឧទាហរណ៍១

គេឱ្យអនុគមន៍ $f(x) = (x+2)e^{-x}$

ក-ចូរសិក្សាទិសដៅអថេរភាព និងសង់ក្រាប (c) តាងអនុគមន៍នេះ ។

ខ-ចូរគណនាក្រឡាផ្ទៃ $S(\lambda)$ ខណ្ឌដោយក្រាប (c) និងអក្ស័អាប់ស៊ីស

ក្នុងចន្លោះ $[-2\ ,\lambda]$ រួចទាញរកលីមីត $\lim_{\lambda\to+\infty} S(\lambda)$ ។

ដំណោះស្រាយ

ក-សិក្សាទិសដៅអថេរភាព និងសង់ក្រាប (c)

គេមាន $f(x)=(x+2)e^{-x}$ មានដែនកំនត់ $D=IR$

.ទិសដៅអថេរភាព

$f'(x)=(x+2)'e^{-x}+(e^{-x})'(x+2)$

$f'(x)=e^{-x}-e^{-x}(x+2)=(-x-1)e^{-x}$

បើ $f'(x)=0$ សមមូល $(-x-1)e^{-x}=0$ នាំឱ្យ $x=-1$ ។

ចំពោះ $x=-1$ អនុគមន៍មានតម្លៃអតិបរមា $f(-1)=e$ ។

លីមីត និង អាសុីមតូត៖

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}(x+2)e^{-x}=-\infty$$

( ព្រោះ $\lim_{x\to-\infty}(x+2)=-\infty$ , $\lim_{x\to-\infty} e^{-x}=+\infty$ )

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(x+2)e^{-x}=0$$ ( ព្រោះ $\lim_{x\to+\infty} e^{-x}=0$ )

នាំឱ្យបន្ទាត់ $y=0$ ជាអាសុីមតូតដេកនៃក្រាប (c) ។

តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | |
| $y$ | $-\infty$ | $\nearrow$ | $e$ | $\searrow$ | $0$ |

សង់ក្រាប $(c): y=(x+2)e^{-x}$

.ចំនុចប្រសព្វរវាងក្រាបជាមួយអ័ក្សកូអរដោនេ៖

បើ $y=0$ សមមូល $(x+2)e^{-x}=0$ នាំឱ្យ $x=-2$

ចំពោះ $x=0$ នាំឱ្យ $y=f(0)=2$ ។



ខ-គណនាក្រឡាផ្ទៃ $S(\lambda)$

យើងបាន $S(\lambda)=\int_{-2}^{\lambda}(x+2)e^{-x}.dx$

តាង $\begin{cases}u=x+2\\ dv=e^{-x}.dx\end{cases}$ នាំឱ្យ $\begin{cases}du=dx\\ v=-e^{-x}\end{cases}$

គេបាន $S(\lambda)=[-(x+2)\,e^{-x}]_{-2}^{\lambda}+\int_{-2}^{\lambda}e^{-x}.dx$

$$=-(\lambda+2)e^{-\lambda}+\left[-e^{-x}\right]_{-2}^{\lambda}$$

$$=-(\lambda+2)e^{-\lambda}-e^{-\lambda}+e^{2}$$

$$=-(\lambda+3)e^{-\lambda}+e^{2}$$

ដូចនេះ $\boxed{S(\lambda)=e^{2}-(\lambda+3)e^{-\lambda}}$ ។

ហើយ $\lim\limits_{\lambda\to+\infty}S(\lambda)=\lim\limits_{\lambda\to+\infty}\left[e^{2}-(\lambda+3)e^{-\lambda}\right]=e^{2}$ ។

ដូចនេះ $\boxed{\lim\limits_{\lambda\to+\infty}S(\lambda)=e^{2}}$

ឧទាហរណ៍២

គេឱ្យអនុគមន៍ $f(x)=1+(x-1)e^{x}$

ក-គណនាលីមីត $\lim_{x\to-\infty} f(x)$ និង $\lim_{x\to+\infty} f(x)$ រួចបញ្ជាក់សមីការ

អាស៊ីមតូតនៃក្រាប $(c)$ តាងអនុគមន៍ $y=f(x)$ ។

ខ-គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ។

គ-រកសមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង $(c)$ ត្រង់ចំនុច $x=1$ ។

សង់ក្រាប $(c)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(o,\vec{i},\vec{j})$ តែមួយ

ឃ-រកក្រឡាផ្ទៃខណ្ឌដោយ $(c)$ និងអក្សអាប់ស៊ីសក្នុងចន្លោះ $[0,1]$ ។

ដំណោះស្រាយ

ក-គណនាលីមីត $\lim_{x\to-\infty} f(x)$ និង $\lim_{x\to+\infty} f(x)$

យើងបាន $\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left[1+(x-1)e^{x}\right]=1$

ព្រោះ $\lim_{x\to-\infty}(x-1)e^{x}=0$ ។

និង $\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left[1+(x-1)e^{x}\right]=+\infty$

ព្រោះ $\lim\limits_{x\to+\infty}(x-1)e^{x}=+\infty$ ។

ដោយ $\lim\limits_{x\to-\infty} f(x)=1$ នាំឱ្យបន្ទាត់ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប

ខ-គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f(x)$

យើងមាន $f(x)=1+(x-1)e^{x}$ កំនត់លើ $D=IR$

យើងបាន $f'(x)=(x-1)'e^{x}+(e^{x})'(x-1)=xe^{x}$ ។

បើ $f'(x)=xe^{x}=0$ នោះ $x=0$ ។

ចំពោះ $x=0$ អនុគមន៍មានតម្លៃអប្បរមា $f(0)=0$ ។

តារាងអថេរភាព

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | |
| $y$ | $-\infty$ | ↗ | $0$ | ↘ | $0$ |

គ-រកសមីការបន្ទាត់ (T) ប៉ះនឹងខ្សែកោង (c)

បើ $x=1$ គេបាន $y=f(1)=1$ នាំឱ្យ $A(1,1)$ ជាចំនុចប៉ះ ។

តាមរូបមន្ត $(T):\ y-y_A=f'(x_A)(x-x_A)$

ដោយ $f'(x_A=1)=e$

គេបាន $(T):y-1=e(x-1)$

ដូចនេះ $\boxed{(T):y=ex-e+1}$ ។ សង់ក្រាប (c) និងបន្ទាត់ (T) ៖



## ឃ-គណនាក្រឡាផ្ទៃ

យើងបាន $S=\int_0^1\left[1+(x-1)e^x\right].dx=\int_0^1 dx+\int_0^1 (x-1)e^x.dx=1+\int_0^1 (x-1)e^x.dx$

តាង $\begin{cases} u=x-1 \\ dv=e^x dx \end{cases}$ នាំឱ្យ $\begin{cases} du=dx \\ v=e^x \end{cases}$

$$S=1+\left[(x-1)e^x\right]_0^1-\int_0^1 e^x.dx=2-\left[e^x\right]_0^1$$

$$=3-e=3-2.718=0.282$$

ដូចនេះ $\boxed{S=0.282}$ ( ឯកតាផ្ទៃក្រឡា ) ។

ឧទាហរណ៍៣

គេឱ្យអនុគមន៍ $f(x)=\dfrac{e^x}{x}$

ក-ចូរសិក្សាទិសដៅអថេរភាពនៃអនុគមន៍ $f(x)$ និង សង់ក្រាប $(c)$

តាងអនុគមន៍ $y=f(x)$ ក្នុងតំរុយអរតូនរម៉ាល់ $(o,\vec{i},\vec{j})$ មួយ ។

ខ-ដោយប្រើក្រាប $(c)$ ចូរសិក្សាអត្ថិភាព និង សញ្ញានៃឬសរបស់

សមីការ $e^x-kx=0$ ដែល $k$ ជាប៉ារ៉ាម៉ែត្រ ។

ដំណោះស្រាយ

ក-សិក្សាទិសដៅអថេរភាព និងសង់ក្រាប $(c)$

គេមាន $f(x)=\dfrac{e^x}{x}$ ដែនកំនត់ $D=IR-\{0\}$

.ទិសដៅអថេរភាព

$$f'(x)=\frac{(e^x)'x-(x)'e^x}{x^2}=\frac{(x-1)e^x}{x^2}$$

បើ $f'(x)=0$ សមមូល $(x-1)e^x=0$ នាំឱ្យ $x=1$ ។

ចំពោះ $x=1$ អនុគមន៍មានតម្លៃអតិបរមា $f(1)=e=2.7182$ ។

## លីមីត និង អាស៊ីមតូត៖

$\lim_{x\to 0^-} f(x) = \lim_{x\to 0^-} \frac{e^x}{x} = -\infty$ និង $\lim_{x\to 0^+} f(x) = \lim_{x\to 0^+} \frac{e^x}{x} = +\infty$

$\lim_{x\to -\infty} f(x) = \lim_{x\to -\infty} \frac{e^x}{x} = 0$ និង $\lim_{x\to +\infty} f(x) = \lim_{x\to +\infty} \frac{e^x}{x} = +\infty$ ។

នាំឱ្យបន្ទាត់ $y=0$ ជាអាស៊ីមតូតដេកនៃក្រាប (c) ។

## តារាងអថេរភាព

| $x$ | $-\infty$ | | 0 | | 1 | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $-$ | 0 | $+$ | |
| $y$ | 0 ↘ $-\infty$ | | ‖ | $+\infty$ ↘ | $e$ | ↗ | $+\infty$ |

សង់ក្រាប (c) ៖




ខ-សិក្សាអត្ថិភាព និង សញ្ញានៃឫសនៃ $e^{x} - kx = 0$

សមីការអាចសរសេរ $\frac{e^{x}}{x} = k$ ជាសមីការអាប់ស៊ីសចំនុចរួមរវាង(c)

និង $(d): y = k$ ។

តាមក្រាហ្វិកយើងអាចសន្និដ្ឋានដូចតទៅ៖

-ចំពោះ $k \in (-\infty \ , 0)$ សមីការមានឫសតែមួយគត់គឺ $x < 0$ ។

-ចំពោះ $k \in [0 , e)$ សមីការគ្មានឫស ។

-ចំពោះ $k = e$ សមីការមានឫសឌុបមួយគឺ $x_1 = x_2 = 1 > 0$ ។

-ចំពោះ $k \in (e \ , +\infty)$ សមីការមានឫសពីរផ្សេងគ្នា $0 < x_1 < x_2$ ។

# ៤-អនុគមន៍លោការីតនេពែ

*រំលឹករូបមន្តលីមីត ៖*

1/ $\lim_{x\to+\infty} \ln x = +\infty$

2/ $\lim_{x\to 0^+} \ln x = -\infty$

3/ $\lim_{x\to+\infty} \frac{\ln x}{x^n} = +\infty \ , n > 0$

4/ $\lim_{x\to 0^+} x^n \ln x = 0 \ , \ n > 0$

*រំលឹករូបមន្តដេរីវេ ៖*

1/ បើ $y = \ln x$ នោះ $y' = \frac{1}{x}$

2/ បើ $y = \ln u(x)$ នោះ $y' = \frac{u'(x)}{u(x)}$

ឧទាហរណ៍១

គេឱ្យអនុគមន៍ $f$ កំនត់លើ $(0,+\infty)$ ដោយ $f(x) = 1 + x\ln x$

ក-ចូរគណនាលីមីត $\lim_{x\to 0^+} f(x)$ និង $\lim_{x\to+\infty} f(x)$ ។

ខ-គណនាដេរីវេ $f'(x)$ រួចសិក្សាសញ្ញារបស់ $f'(x)$ ។

គូសតារាងអថេរភាពនៃ $f(x)$ ។

គ-កំនត់សមីការបន្ទាត់ (T) ប៉ះនឹងខ្សែកោង (c) តាង f ត្រង់ចំនុច

មានអាប់ស៊ីស $x=1$ ។ចូរសង់ ក្រាប (c) និងបន្ទាត់ (T) ក្នុងតំរុយអរតូនរ

ម៉ាល់ $(o, \vec{i}, \vec{j})$ តែមួយ ។

ឃ-គណនាក្រឡាផ្ទៃ $S(\alpha)$ ខណ្ឌដោយ (c) និងអក្សអាប់ស៊ីសក្នុង

ចន្លោះ $[\alpha, 1]$ , $\alpha > 0$ រួចទាញរកលីមីត $\lim\limits_{\alpha \to 0^+} S(\alpha)$ ។

ដំណោះស្រាយ

ក-គណនាលីមីត $\lim\limits_{x \to 0^+} f(x)$ និង $\lim\limits_{x \to +\infty} f(x)$

យើងបាន $\lim\limits_{x \to 0^+} f(x) = \lim\limits_{x \to 0^+} (1 + x\ln x) = 1$ ព្រោះ $\lim\limits_{x \to 0^+} x\ln x = 0$

និង $\lim\limits_{x \to +\infty} f(x) = \lim\limits_{x \to +\infty} x\ln x = +\infty$ ។

ខ-គណនាដេរីវេ $f'(x)$ រួចសិក្សាសញ្ញារបស់ $f'(x)$

យើងបាន $f'(x) = (x)'\ln x + (\ln x)'x = \ln x + 1$

-បើ $\ln x + 1 > 0$ នាំឱ្យ $x > \frac{1}{e}$ នោះ $f'(x) > 0$

-បើ $\ln x + 1 = 0$ នាំឱ្យ $x = \frac{1}{e}$ នោះ $f'(x) = 0$ ។

-បើ $\ln x+1<0$ នាំឱ្យ $x<\frac{1}{e}$ នោះ $f'(x)<0$ ។

គូសតារាងអថេរភាពនៃ $f(x)$ ៖

| $x$ | $0$ | | $\frac{1}{e}$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $1$ | ↘ | $1-\frac{1}{e}$ | ↗ | $+\infty$ |

គ-កំនត់សមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង $(c)$ តាង $f$ ត្រង់ចំនុចមាន

អាប់ស៊ីស $x=1$ ៖

ចំពោះ $x=1$ នោះ $y=f(1)=1+0=1$ នាំឱ្យ $A(1,1)$ ជាចំនុចប៉ះ ។

តាមរូបមន្ត $(T): y-y_A=f'(x_A)(x-x_A)$

ដោយ $f'(x_A=1)=1+\ln 1=1$ គេបាន $(T): y-1=x-1$

នាំឱ្យ $(T): y=x$ ។

សង់ ក្រាប (c)  និងបន្ទាត់ (T)  ក្នុងតំរុយអរតូនរម៉ាល់ $(o, \vec{i}, \vec{j})$ ៖




ឃ-គណនាក្រឡាផ្ទៃ $S(\alpha)$ ខណ្ឌដោយ (c)  និងអក្ស័រអាប់ស៊ីសក្នុង

ចន្លោះ $[\alpha, 1]$ , $\alpha > 0$

យើងបាន $S(\alpha) = \int_{\alpha}^{1} (1 + x\ln x).dx = \int_{\alpha}^{1} dx + \int_{\alpha}^{1} x\ln x.dx = (1 - \alpha) + \int_{\alpha}^{1} x\ln x.dx$

តាង $\begin{cases} u = \ln x \\ dv = xdx \end{cases}$  នាំឱ្យ  $\begin{cases} du = \frac{1}{x}dx \\ v = \frac{x^2}{2} \end{cases}$

គេបាន $S(\alpha)=1-\alpha+\left[\frac{x^2}{2}\ln x\right]_{\alpha}^{1}-\frac{1}{2}\int_{\alpha}^{1}xdx=1-\alpha-\frac{\alpha^2}{2}\ln\alpha-\frac{1}{4}\left[x^2\right]_{\alpha}^{1}$

$$=1-\alpha-\frac{\alpha^2}{2}\ln\alpha-\frac{1}{4}+\frac{1}{4}\alpha^2=\frac{3}{4}-\alpha+\frac{\alpha^2}{4}-\frac{\alpha^2}{2}\ln\alpha$$

ដូចនេះ $S(\alpha)=\frac{3}{4}-\alpha+\frac{\alpha^2}{4}-\frac{\alpha^2}{2}\ln\alpha$ និង $\lim_{\alpha\to0^+}S(\alpha)=\frac{3}{4}$ ។

ជំពូកទី៤

# លំហាត់ជ្រើសរើសមានដំណោះស្រាយ

## លំហាត់ទី១

គេឱ្យអនុគមន៍ $f$ មានដេរីវេលើ $(-2\,,+\infty)$ ដែល $f(x)=\sqrt{x+2}$

ក. រកតម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[-1,2]$

ខ. បង្ហាញថាចំពោះគ្រប់ $x\in[-1\,,2]$ គេបាន ៖

$\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$ ។

## ដំណោះស្រាយ

ក. រកតម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[-1,2]$

គេមាន $f(x)=\sqrt{x+2}$

គេបាន $f'(x)=\frac{(x+2)'}{2\sqrt{x+2}}=\frac{1}{2\sqrt{x+2}}$

ដោយ $-1\le x\le 2$ នោះ $1\le x+2\le 4$ ឬ $1\le\sqrt{x+2}\le 2$

គេទាញ $\frac{1}{4}\le\frac{1}{2\sqrt{x+2}}\le\frac{1}{2}$

ដូចនេះ $\frac{1}{4}\le f'(x)\le\frac{1}{2}$ ចំពោះគ្រប់ $x\in[-1,2]$ ។

ខ. បង្ហាញថាចំពោះគ្រប់ $x\in[-1,2]$ គេបាន ៈ

$$\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$$

តាមសម្រាយខាងលើគេមាន $\frac{1}{4}\le f'(x)\le\frac{1}{2}$ ចំពោះគ្រប់ $x\in[-1,2]$

តាមទ្រឹស្តីបទវិសមភាពកំណើនមានកំណត់អនុវត្តន៍ចំពោះអនុគមន៍ $f$ ក្នុងចន្លោះ $[-1,2]$ គេបាន៖

ចំពោះ $x\ge-1$ នោះ $\frac{1}{4}(x+1)\le f(x)-f(-1)\le\frac{1}{2}(x+1)$

ឬ $\frac{1}{4}x+\frac{1}{4}\le\sqrt{x+2}-1\le\frac{1}{2}x+\frac{1}{2}$

ដូចនេះ $\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$ ។

# លំហាត់ទី២

គេឱ្យអនុគមន៍ f មានដេរីវេលើ IR ដែល $f(x)=\ln(x+\sqrt{1+x^2})$

ក. រកតម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[\frac{3}{4},\frac{4}{3}]$ ។

ខ. បង្ហាញថាចំពោះគ្រប់ $x\in[\frac{3}{4},\frac{4}{3}]$ គេបាន ៈ

$$\frac{3x}{5}-\frac{9}{20}+\ln 2\le \ln(x+\sqrt{1+x^2})\le \frac{4x}{5}-\frac{3}{5}+\ln 2$$

# ដំណោះស្រាយ

ក. រកតម្លៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[\frac{3}{4},\frac{4}{3}]$

គេបាន $f'(x)=\frac{(x+\sqrt{1+x^2})'}{x+\sqrt{1+x^2}}$

$$=\frac{1+\frac{2x}{2\sqrt{1+x^2}}}{x+\sqrt{1+x^2}}=\frac{\sqrt{1+x^2}+x}{(x+\sqrt{1+x^2})\sqrt{1+x^2}}$$

$$=\frac{1}{\sqrt{1+x^2}}$$

ចំពោះគ្រប់ $x\in[\frac{3}{4},\frac{4}{3}]$ គេបាន $\frac{25}{16}\le 1+x^2\le\frac{25}{9}$

ឬ $\frac{5}{4} \le \sqrt{1+x^2} \le \frac{5}{3}$ នាំឱ្យ $\frac{3}{5} \le \frac{1}{\sqrt{1+x^2}} \le \frac{4}{5}$

ដូចនេះ $\frac{3}{5} \le f'(x) \le \frac{4}{5}$ ចំពោះគ្រប់ $x \in [\frac{3}{4}, \frac{4}{3}]$ ។

ខ. បង្ហាញថាចំពោះគ្រប់ $x \in [\frac{3}{4}, \frac{4}{3}]$ គេបាន ៈ

$$\frac{3x}{5} - \frac{9}{20} + \ln 2 \le \ln(x + \sqrt{1+x^2}) \le \frac{4x}{5} - \frac{3}{5} + \ln 2$$

តាមសម្រាយខាងលើគេមាន $\frac{3}{5} \le f'(x) \le \frac{4}{5}$ ចំពោះគ្រប់ $x \in [\frac{3}{4}, \frac{4}{3}]$

តាមទ្រឹស្តីបទវិសមភាពកំណើនមានកំណត់គេបាន៖

ចំពោះ $x \ge \frac{3}{4}$ : $\frac{3}{5}(x - \frac{3}{4}) \le f(x) - f(\frac{3}{4}) \le \frac{4}{5}(x - \frac{3}{4})$

ឬ $\frac{3x}{5} - \frac{9}{20} \le \ln(x + \sqrt{1+x^2}) - \ln 2 \le \frac{4x}{5} - \frac{3}{5}$

ដូចនេះ $\frac{3x}{5} - \frac{9}{20} + \ln 2 \le \ln(x + \sqrt{1+x^2}) \le \frac{4x}{5} - \frac{3}{5} + \ln 2$ ។

## លំហាត់ទី៣

គេមានអនុគមន៍ $f(x)=\sqrt{3x+1}$ កំនត់លើ $[-\frac{1}{3};+\infty)$

ក. ចំពោះគ្រប់ $1\le x\le 5$ ចូរបង្ហាញថា $\frac{3}{8}\le f'(x)\le\frac{3}{4}$ ។

ខ. ដោយប្រើវិសមភាពកំណើនមានកំនត់អនុវត្តន៍ទៅនឹងអនុគមន៍ f

ចំពោះគ្រប់ $x\in[1,5]$ ចូរបង្ហាញថា $\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4}$

## ដំណោះស្រាយ

ក. ចំពោះគ្រប់ $1\le x\le 5$ បង្ហាញថា $\frac{3}{8}\le f'(x)\le\frac{3}{4}$

គេមាន $f(x)=\sqrt{3x+1}$ នាំឱ្យ $f'(x)=\frac{3}{2\sqrt{3x+1}}$

ចំពោះគ្រប់ $x\in[1,5]$ គេមាន $1\le x\le 5$ ឬ $4\le 3x+1\le 16$

$$\frac{1}{4}\le\frac{1}{\sqrt{3x+1}}\le\frac{1}{2}$$

$$\frac{3}{8}\le\frac{3}{2\sqrt{3x+1}}\le\frac{3}{4}$$

ដូចនេះ $\boxed{\frac{3}{8}\le f'(x)\le\frac{3}{4}}$ ចំពោះគ្រប់ $x\in[1,5]$ ។

ខ. បង្ហាញថា $\frac{3}{8}x+\frac{13}{8} \le \sqrt{3x+1} \le \frac{3}{4}x+\frac{5}{4}$

ចំពោះគ្រប់ $x\in[1,5]$ គេមាន $\frac{3}{8}\le f'(x)\le\frac{3}{4}$

តាមទ្រឹស្តីបទវិសមភាពកំណើនមានកំនត់

ចំពោះ $x\ge 1$ គេមាន $\frac{3}{8}(x-1)\le f(x)-f(1)\le\frac{3}{4}(x-1)$

ដោយ $f(x)=\sqrt{3x+1}$

គេបាន $\frac{3}{8}x-\frac{3}{8}\le\sqrt{3x+1}-2\le\frac{3}{4}x-\frac{3}{4}$

នាំឱ្យ $\frac{3}{8}x+\frac{13}{8} \le \sqrt{3x+1} \le \frac{3}{4}x+\frac{5}{4}$ ។

# លំហាត់ទី៤

គេឱ្យ f ជាអនុគមន៍កំនត់ដោយ $f(x)=(x+\sqrt{1+x^2})^n$

ដែល $x\in IR$ និង $n\in IN$ ។

ក-ចូរគណនាដេរីវេ $f'(x)$ រួចបង្ហាញថា ៖

$\sqrt{1+x^2}.f'(x)=n.f(x)$ ។

ខ-ចូរស្រាយបញ្ជាក់ទំនាក់ទំនង ៖

$(1+x^2).f''(x)+x.f'(x)=n^2.f(x)$ ។

# ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$

គេមាន $f(x)=(x+\sqrt{1+x^2})^n$

តាមរូបមន្ត $(u^n)'=nu'.u^{n-1}$

គេបាន $f'(x)=n.(x+\sqrt{1+x^2})'.(x+\sqrt{1+x^2})^{n-1}$

$$f'(x)=n.\left(1+\frac{(1+x^2)'}{2\sqrt{1+x^2}}\right).(x+\sqrt{1+x^2})^{n-1}$$

$$=n.\left(1+\frac{2x}{2\sqrt{1+x^2}}\right).(x+\sqrt{1+x^2})^{n-1}$$

$$=n.\frac{\sqrt{1+x^2}+x}{\sqrt{1+x^2}}.(x+\sqrt{1+x^2})^{n-1}$$

$$=\frac{n}{\sqrt{1+x^2}}(x+\sqrt{1+x^2})^{n}$$

ដូចនេះ $\boxed{f'(x)=\frac{n}{\sqrt{1+x^2}}.(x+\sqrt{1+x^2})^{n}}$ ។

បង្ហាញថា $\sqrt{1+x^2}.f'(x)=n.f(x)$

គេមាន $f'(x)=\frac{n}{\sqrt{1+x^2}}.(x+\sqrt{1+x^2})^{n}$

ដោយ $f(x)=(x+\sqrt{1+x^2})^{n}$

គេបាន $f'(x)=\frac{n}{\sqrt{1+x^2}}.f(x)$ នាំឱ្យ $\sqrt{1+x^2}.f'(x)=n.f(x)$ ។

ដូចនេះ $\boxed{\sqrt{1+x^2}.f'(x)=n.f(x)}$ ។

ខ-ស្រាយបញ្ជាក់ទំនាក់ទំនង៖

$$(1+x^2).f''(x)+x.f'(x)=n^2.f(x)$$

គេមាន $\sqrt{1+x^2}.f'(x)=n.f(x)$ នាំឱ្យ $f'(x)=n.\dfrac{f(x)}{\sqrt{1+x^2}}$

គេបាន $f''(x)=n.\dfrac{f'(x)\sqrt{1+x^2}-(\sqrt{1+x^2})'f(x)}{(\sqrt{1+x^2})^2}$

$$f''(x)=n\dfrac{f'(x).\sqrt{1+x^2}-\dfrac{2x}{2\sqrt{1+x^2}}.f(x)}{1+x^2}$$

$$f''(x)=n.\dfrac{\sqrt{1+x^2}.f'(x)-x.\dfrac{f(x)}{\sqrt{1+x^2}}}{1+x^2} \quad (1)$$

គេមាន $\sqrt{1+x^2}.f'(x)=n.f(x) \quad (2)$

និង $\dfrac{1}{n}.f'(x)=\dfrac{f(x)}{\sqrt{1+x^2}} \quad (3)$

យក (2) និង (3) ជួសក្នុងទំនាក់ទំនង (1) គេបាន៖

ដូចនេះ $\boxed{(1+x^2).f''(x)+x.f'(x)=n^2.f(x)}$ ។

# លំហាត់ទី៥

គេឱ្យ f ជាអនុគមន៍កំនត់ដោយ៖

$$f(x)=\sin^6 x+\cos^6 x+k.\sin^2 x.\cos^2 x$$

ក-ចូរគណនាដេរីវេ $f'(x)$ ។

ខ-ចូរកំនត់ចំនួនពិត k ដើម្បីឱ្យ $f(x)$ ជាអនុគមន៍ថេរជានិច្ចគ្រប់ $x\in IR$

# ដំណោះស្រាយ

ក-គណនាដេរីវេ $f'(x)$

$$f'(x)=6.(\sin x)'\sin^5 x+6.(\cos x)'\cos^5 x+k(\sin^2 x)'\cos^2 x+k(\cos^2 x)'\sin^2 x$$

$$=6\cos x\sin^5 x-6\sin x\cos^5 x+2k\sin x\cos^3 x-2k\cos x\sin^3 x$$

$$=6\cos x\sin x(\sin^4 x-\cos^4 x)+2k\sin x\cos x(\cos^2 x-\sin^2 x)$$

$$=3\sin 2x(\sin^2 x-\cos^2 x)(\sin^2 x+\cos^2 x)+k\sin 2x.\cos 2x$$

$$=-3\sin 2x\cos 2x+k.\sin 2x\cos 2x$$

$$=(-3+k).\sin 2x\cos 2x=\frac{1}{2}(k-3)\sin 4x$$

ដូចនេះ $\boxed{f'(x)=\frac{1}{2}(k-3).\sin 4x}$ ។

ខ-កំនត់ចំនួនពិត $k$

ដើម្បីឱ្យ $f(x)$ ជាអនុគមន៍ថេរជានិច្ចចំពោះគ្រប់ $x \in IR$ លុះត្រាតែ

$f'(x) = 0$ គ្រប់ $x \in IR$ ។

ដោយ $f'(x) = \frac{1}{2}(k-3).\sin 4x$

គេទាញ $k - 3 = 0$ នាំឱ្យ $k = 3$ ។

## លំហាត់ទី៦

គេឲ្យអនុគមន៍ $f(x)$ កំនត់ និងមានដេរីវេលើ IR ។

គេដឹងថា $\begin{cases} f(1) = f'(1) = 3 \\ \dfrac{1}{2x-1}f''(x) - \dfrac{2}{(2x-1)^2}f'(x) = 4x+1 \end{cases}$

ចូរកំនត់រកអនុគមន៍ $f(x)$ ។

## ដំណោះស្រាយ

កំនត់រកអនុគមន៍ $f(x)$ ៖

គេមាន $\dfrac{1}{2x-1}f''(x) - \dfrac{2}{(2x-1)^2}f'(x) = 4x+1 \quad (1)$

តាង $g(x) = f'(x).\dfrac{1}{2x-1}$ គេបាន $g'(x) = \dfrac{1}{2x-1}f''(x) - \dfrac{1}{(2x-1)^2}f'(x)$

ទំនាក់ទំនង (1) ក្លាយទៅជា $g'(x) = 4x+1$ នោះ $g(x) = 2x^2 + x + C$

បើ $x = 1$ នោះ $g(1) = 3 + C$ តែ $g(1) = f'(1).\dfrac{1}{2(1)-1} = f'(1) = 3$

គេបាន $3 + C = 3$ នាំឲ្យ $C = 0$ ដូចនេះ $g(x) = 2x^2 + x$

ដោយ $g(x) = f'(x).\dfrac{1}{2x-1}$ គេទាញ $\dfrac{f'(x)}{2x-1} = 2x^2 + x$

$f'(x) = 4x^3 - x$ នាំឲ្យ $f(x) = x^4 - \frac{1}{2}x^2 + k$

បើ $x = 1$ នោះ $f(1) = \frac{1}{2} + k = 3$ នាំឲ្យ $k = \frac{5}{2}$ ។

ដូចនេះ $f(x) = x^4 - \frac{1}{2}x^2 + \frac{5}{2}$ ។

# លំហាត់ទី៧

គេឲ្យអនុគមន៍ $f(x)$ កំនត់ និង មានដេរីវេលើ IR ដោយ ៖

$$\begin{cases} f'(x).f^2(x) = x(x-2) \\ f(0) = 2 \end{cases}$$ ចំពោះគ្រប់ $x \in IR$ ។

ចូរកំនត់រកអនុគមន៍ $f(x)$ ។

# ដំណោះស្រាយ

កំនត់រកអនុគមន៍ $f(x)$ ៖

គេមាន $f'(x).\,f^2(x) = x(x-2) \quad (1)$

តាង $g(x) = f^3(x)$ គេបាន $g'(x) = 3f'(x).f^2(x)$

ឬ $\frac{1}{3}g'(x) = f'(x).f^2(x)$

ទំនាក់ទំនង (1) ទៅជា $\frac{1}{3}g'(x) = x(x-2)$

$$g'(x) = 3x^2 - 6x$$
$$g(x) = x^3 - 3x^2 + k$$

បើ $x = 0$ នោះ $g(0) = k$

ដោយ $g(0)=f^3(0)=(2)^3=8$

គេបាន $g(x)=x^3-3x^2+8$ តែ $g(x)=f^3(x)$

គេទាញ $f^3(x)=x^3-3x^2+8$ នាំឲ្យ $f(x)=\sqrt[3]{x^3-3x^2+8}$

ដូចនេះ $f(x)=\sqrt[3]{x^3-3x^2+8}$ ។

## លំហាត់ទី៨

គេឲ្យអនុគមន៍ $f(x)=\dfrac{x^3+3x^2-3x+1}{3x^2-3x+1}$ កំនត់ចំពោះគ្រប់ $x\in IR$ ។

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a$ និង $b$ ចូរស្រាយបញ្ជាក់ថា ៖

$$f\left(\frac{1+a+b}{2}\right) \geq f\left(\frac{1+a+b+ab}{2+a+b}\right)$$ ។

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា ៖

$$f\left(\frac{1+a+b}{2}\right) \geq f\left(\frac{1+a+b+ab}{2+a+b}\right)$$

យើងមាន $f(x)=\dfrac{x^3+3x^2-3x+1}{3x^2-3x+1}$ កំនត់ចំពោះគ្រប់ $x\in IR$

$$f'(x)=\frac{(3x^2+6x-3)(3x^2-3x+1)-(6x-3)(x^3+3x^2-3x+1)}{(3x^2-3x+1)^2}$$

$$=\frac{3x^4-6x^3+3x^2}{(3x^2-3x+1)^2}=\frac{3x^2(x-1)^2}{(3x^2-3x+1)^2}\geq 0\ ,\ \forall x\in IR$$

ដូចនេះ $f(x)$ ជាអនុគមន៍កើនលើ $IR$ ។

ម៉្យាងទៀតយើងសន្មតថា $\dfrac{1+a+b}{2}\geq\dfrac{1+a+b+ab}{2+a+b}$

គេបាន $\dfrac{2}{1+a+b} \le \dfrac{2+a+b}{1+a+b+ab}$

$$\frac{2}{1+a+b} \le \frac{(1+a)+(1+b)}{(1+a)(1+b)}$$

$$\frac{2}{1+a+b} \le \frac{1}{1+a} + \frac{1}{1+b}$$

ដោយ $\dfrac{1}{1+a+b} \le \dfrac{1}{1+a}$ និង $\dfrac{1}{1+a+b} \le \dfrac{1}{1+b}$

គ្រប់ចំនួនពិតវិជ្ជមាន $a$ និង $b$ ។

គេទាញ $\dfrac{2}{1+a+b} \le \dfrac{1}{1+a} + \dfrac{1}{1+b}$

នាំឲ្យការសន្មត $\dfrac{1+a+b}{2} \ge \dfrac{1+a+b+ab}{2+a+b}$ ពិត។

ដូចនេះតាមលក្ខណៈអនុគមន៍កើនគេទាញ

$$f\left(\frac{1+a+b}{2}\right) \ge f\left(\frac{1+a+b+ab}{2+a+b}\right)$$ ។

## លំហាត់ទី៩

គេឱ្យ a និង b ជាពីរចំនួនពិតដែល $0 \le a < b < \frac{\pi}{2}$

ចូរស្រាយថា $\frac{b-a}{\cos^2 a} < \tan b - \tan a < \frac{b-a}{\cos^2 b}$

## ដំណោះស្រាយ

ស្រាយថា $\frac{b-a}{\cos^2 a} < \tan b - \tan a < \frac{b-a}{\cos^2 b}$

តាងអនុគមន៍ $f(x) = \tan x$ ដែល $x \in [0, \frac{\pi}{2})$

គេបាន $f'(x) = \frac{1}{\cos^2 x}$ ។

ដោយ $f(x)$ ជាអនុគមន៍ជាប់ និងមានដេរីវេលើចន្លោះ $x \in [0, \frac{\pi}{2})$

នោះតាមទ្រឹស្តីបទតម្លៃមធ្យម នោះមាន $c \in (a, b)$ ដែល៖

$$f'(c) = \frac{f(b) - f(a)}{b - a} = \frac{\tan b - \tan a}{b - a} \quad (1)$$

ហើយចំពោះ $x \in [a, b]$ ដែល $0 \le a < b < \frac{\pi}{2}$

គេមាន $\cos b \le \cos x \le \cos a$

នោះគេទាញ $\frac{1}{\cos^2 a} < f'(x) < \frac{1}{\cos^2 b}$

យក $x = c$ គេបាន $\frac{1}{\cos^2 a} < f'(c) < \frac{1}{\cos^2 b}$ (2)

តាម (1) និង (2) គេទាញ

$\frac{b-a}{\cos^2 a} \leq \tan b - \tan a \leq \frac{b-a}{\cos^2 b}$ ។

## លំហាត់ទី១១

ចំពោះគ្រប់ចំនួនពិត $0<a<b$ ចូរស្រាយបញ្ជាក់ថា៖

$$\frac{b-a}{b}\le \ln b-\ln a\le \frac{b-a}{a}$$ ។

## ដំណោះស្រាយ

ស្រាយថា $\frac{b-a}{b}\le \ln b-\ln a\le \frac{b-a}{a}$

តាងអនុគមន៍ $f(x)=\ln x$ ដែល $x\in(0,+\infty)$

គេបាន $f'(x)=\frac{1}{x}$ ។

ដោយ $f(x)$ ជាអនុគមន៍ជាប់ និងមានដេរីវេលើចន្លោះ $x\in(0\,,+\infty\,)$

នោះតាមទ្រឹស្តីបទតម្លៃមធ្យម នោះមាន $c\in(a,b)$ ដែល៖

$$f'(c)=\frac{f(b)-f(a)}{b-a}=\frac{\ln b-\ln a}{b-a}\ (1)$$

ហើយចំពោះ $x\in[a,b\,]$ ដែល $0<a<b$

គេមាន $a\le x\le b$ នោះគេទាញ $\frac{1}{b}\le f'(x)\le\frac{1}{a}$

យក $x=c$ គេបាន $\frac{1}{b}<f'(c)<\frac{1}{a}$ (2)

តាម (1) និង (2) គេទាញ $\frac{1}{b}<\frac{\ln b-\ln a}{b-a}<\frac{1}{a}$

ដូចនេះ $\frac{b-a}{b}<\ln b-\ln a<\frac{b-a}{a}$ ។

## លំហាត់ទី១២

ចំពោះគ្រប់ចំនួនពិត $0 \le a < b \le \frac{\pi}{2}$ ចូរស្រាយបញ្ជាក់ថា៖

$(b-a)\cos b \le \sin b - \sin a \le (b-a)\cos a$ ។

## ដំណោះស្រាយ

ស្រាយថា $(b-a)\cos b \le \sin b - \sin a \le (b-a)\cos a$

តាងអនុគមន៍ $f(x) = \sin x$ ដែល $x \in [0, \frac{\pi}{2}]$

គេបាន $f'(x) = \cos x$ ។

ដោយ $f(x)$ ជាអនុគមន៍ជាប់ និងមានដេរីវេលើចន្លោះ $x \in [0, \frac{\pi}{2}]$

នោះតាមទ្រឹស្តីបទតម្លៃមធ្យម នោះមាន $c \in (a, b)$ ដែល៖

$$f'(c) = \frac{f(b) - f(a)}{b - a} = \frac{\sin b - \sin a}{b - a} \quad (1)$$

ហើយចំពោះ $x \in [a, b]$ ដែល $0 \le a < b \le \frac{\pi}{2}$

គេមាន $\cos b < \cos x < \cos a$

នោះគេទាញ $\cos b < f'(x) < \cos a$

យក $x = c$ គេបាន $\cos b < f'(c) < \cos a \quad (2)$

តាម (1) និង (2) គេទាញ $\cos b < \dfrac{\sin b - \sin a}{b - a} < \cos a$

ដូចនេះ $(b-a)\cos b < \sin b - \sin a < (b-a)\cos a$ ។

## លំហាត់ទី១៣

ចំពោះគ្រប់ចំនួនពិត $0 \le a < b$ ចូរស្រាយបញ្ជាក់ថា៖

$na^{n-1}(b-a) \le b^n - a^n \le nb^{n-1}(b-a)$ ដែល $n \in IN$ ។

## ដំណោះស្រាយ

ស្រាយថា $na^{n-1}(b-a) \le b^n - a^n \le nb^{n-1}(b-a)$

តាងអនុគមន៍ $f(x) = x^n$ ដែល $x \in [0, +\infty)$

គេបាន $f'(x) = nx^{n-1}$ ។

ដោយ $f(x)$ ជាអនុគមន៍ជាប់ និងមានដេរីវេលើចន្លោះ $x \in [0, +\infty)$

នោះតាមទ្រឹស្តីបទតម្លៃមធ្យម នោះមាន $c \in (a, b)$ ដែល៖

$$f'(c) = \frac{f(b) - f(a)}{b - a} = \frac{b^n - a^n}{b - a} \quad (1)$$

ហើយចំពោះ $x \in [a, b]$ ដែល $0 \le a < b$

គេមាន $a^{n-1} < x^{n-1} < b^{n-1}$ នោះគេទាញ $na^{n-1} < f'(x) < nb^{n-1}$

យក $x = c$ គេបាន $na^{n-1} < f'(c) < nb^{n-1}$ (2)

តាម (1) និង (2) គេទាញ $na^{n-1} < \frac{b^n - a^n}{b - a} < nb^{n-1}$

ដូចនេះ $na^{n-1}(b-a) < b^n - a^n < nb^{n-1}(b-a)$ ។

## លំហាត់ទី១៤

គណនា $y'$ ជាអនុគមន៍នៃ $x$ និង $y$ បើគេដឹងថា៖

$x^y = y^x$ គ្រប់ $x > 0, y > 0$ ។

## ដំណោះស្រាយ

គណនា $y'$ ជាអនុគមន៍នៃ $x$ និង $y$

គេមាន $x^y = y^x$ នាំឱ្យ $y\ln x = x\ln y$

ធ្វើដេរីវេលើសមីការនេះ $y'\ln x + y.\frac{1}{x} = \ln y + x.\frac{y'}{y}$

ឬ $(\ln x - \frac{x}{y})y' = \ln y - \frac{y}{x}$

ដូចនេះ $y' = \frac{\ln y - \frac{y}{x}}{\ln x - \frac{x}{y}}$ ។

# លំហាត់ទី១៥

ចូរគណនា $y''$ ជាអនុគមន៍នៃ $x$ និង $y$ បើគេដឹងថា៖

$x^3+y^3+4=3xy$ ។

# ដំណោះស្រាយ

គណនា $y''$ ជាអនុគមន៍នៃ $x$ និង $y$

គេមាន $x^3+y^3+2=3xy$

ធ្វើដេរីវេលើអង្គទាំងពីរនៃសមីការនេះគេបាន៖

$$3x^2+3y'y^2=3y+3xy'$$

$$x^2+y'y^2=y+xy'$$

$$y'=\frac{y-x^2}{y^2-x}$$

ហើយ $y''=\dfrac{(y'-2x)(y^2-x)-(2yy'-1)(y-x^2)}{(y^2-x)^2}$

$$=\frac{(x^2-2xy^2+y)-(y^2-2x^2y+x)y'}{(y^2-x)^2}$$

ជំនួស $y'=\frac{y-x^2}{y^2-x}$ រួចបង្រួមគេទទួលបាន៖

$y''=\frac{2xy(3xy-x^3-y^3-1)}{(y^2-x)^3}$ ដោយ $x^3+y^3+2=3xy$

ដូចនេះ $y''=\frac{2xy}{(y^2-x)^3}$ ។

# លំហាត់ទី១៦

គេឱ្យអនុគមន៍ $f(x)=\dfrac{1}{1-x}$ ដែល $x\neq 1$

ក. គណនាដេរីវេទី $n$ នៃអនុគមន៍ $f(x)$ តាងដោយ $f^{(n)}(x)$ ។

ខ.ចូរស្រាយថាអនុគមន៍ $f(x)$ អាចសរសេរជារាង៖

$$f(x)=f(0)+\frac{x}{1!}f'(x)+\frac{x^2}{2!}f''(0)+...+\frac{x^n}{n!}f^{(n)}(0)+R_n(x)$$

ដែល $R_n(x)=\dfrac{x^{n+1}}{1-x}$ គ្រប់ $x\neq 1$ ។

# ដំណោះស្រាយ

ក. គណនាដេរីវេទី $n$ នៃអនុគមន៍ $f(x)$ ៖

គេមាន $f(x)=\dfrac{1}{1-x}=(1-x)^{-1}$

គេបាន $f'(x)=-(1-x)'(1-x)^{-2}=(1-x)^{-2}=1!(1-x)^{-2}$

$$f''(x)=2(1-x)^{-3}=2!(1-x)^{-3}$$

$$f^{(3)}(x)=6(1-x)^{-4}=3!(1-x)^{-4}$$

--------------------

ឧបមាថា $f^{(n)}(x)=n!(1-x)^{-n-1}$ ពិត

យើងនឹងស្រាយថា $f^{(n+1)}(x)=(n+1)!(1-x)^{-n-2}$ ពិត

គេមាន

$f^{(n+1)}(x)=[f^{(n)}(x)]'=[n!(1-x)^{-n-1}]'=(n+1)!(1-x)^{-n-2}$ ពិត

ដូចនេះ $f^{(n)}(x)=n!(1-x)^{-n-1}=\dfrac{n!}{(1-x)^{n+1}}$ ។

ខ.ស្រាយថាអនុគមន៍ $f(x)$ អាចសរសេរជារាង៖

$$f(x)=f(0)+\frac{x}{1!}f'(x)+\frac{x^2}{2!}f''(0)+...+\frac{x^n}{n!}f^{(n)}(0)+R_n(x)$$

គេមាន $f^{(n)}(x)=\dfrac{n!}{(1-x)^{n+1}}$ នោះ $f^{(n)}(0)=n!$ និង $f(0)=1$

ហើយ $R_n(x)=\dfrac{x^{n+1}}{1-x}$ នោះគេបាន៖

$$f(x)=f(0)+\frac{x}{1!}f'(x)+\frac{x^2}{2!}f''(0)+...+\frac{x^n}{n!}f^{(n)}(0)+R_n(x)$$

$$=1+x+x^2+....+x^n+\frac{x^{n+1}}{1-x}$$

$$=\frac{(1-x)(1+x+x^2+....+x^n)+x^{n+1}}{1-x}$$

$$=\frac{1-x^{n+1}+x^{n+1}}{1-x}=\frac{1}{1-x}$$ ពិត

## លំហាត់ទី១៧

គេឱ្យអនុគមន៍ $y = f(x) = \frac{x^3 - 8x^2 + 13x - 2}{x^2 - 2x + 1}$

ក. សិក្សាអថេរភាព និងសង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយអរតូណរម៉ាល់ $(o, \vec{i}, \vec{j})$ មានឯកតា 1cm នៅលើអក្ស័ ។

ខ. ដោយប្រើក្រាប (c) ចូរសិក្សាតាមតម្លៃ m នូវអត្ថិភាពនៃឬសរបស់សមីការ $x^3 - (m+8)x^2 + (2m+13)x - (m+2) = 0$

( $m \in IR$ ជាប៉ារ៉ាម៉ែត្រ )

## ដំណោះស្រាយ

-ដែនកំនត់ $D = IR - \{1\}$

-ទិសដៅអថេរភាព

.សរសេរជារាងកាណូនិច

$$f(x) = \frac{(x^3 - 2x^2 + x) - (6x^2 - 12x + 6) + 4}{x^2 - 2x + 1}$$

$$f(x) = x - 6 + \frac{4}{(x-1)^2}$$

.ដេរីវេ $f'(x)=1-\frac{8}{(x-1)^3}=\frac{(x-1)^3-8}{(x-1)^3}$

.ចំនុចបរមា

បើ $f'(x)=0$ គេបាន $(x-1)^3-8=0$ ឬ $x=3$

អនុគមន៍មានតម្លៃអប្បបរមាធៀបត្រង់ $x=3$ គឺ

$$f(3)=3-6+\frac{4}{(3-1)^2}=-2$$

.គណនាលីមីត

$$\lim_{x\to 1^-} f(x)=\lim_{x\to 1^-}\left[x-6+\frac{4}{(x-1)^2}\right]=+\infty$$

និង $$\lim_{x\to 1^+} f(x)=\lim_{x\to 1+}\left[x-6+\frac{4}{(x-1)^2}\right]=+\infty$$

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\left[x-6+\frac{4}{(x-1)^2}\right]=\pm\infty$$

.អាស៊ីមតូត

ដោយគេមាន $\lim_{x\to 1} f(x)=+\infty$ នាំឲ្យបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ ។

ម៉្យាងទៀតគេមាន $f(x)=x-6+\dfrac{4}{(x-1)^2}$ ដោយ $\lim\limits_{x\to\pm\infty}\dfrac{4}{(x-1)^2}=0$

ដូចនេះបន្ទាត់ $y=x-6$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង (c) ។

.តារាងអថេរភាព

| $x$ | $-\infty$ | | $1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | \|\| | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $+\infty$ \|\| $+\infty$ | ↘ | $-2$ | ↗ | $+\infty$ |

-សង់ក្រាប $(c): y=\dfrac{x^3-8x^2+13x-2}{x^2-2x+1}$




ខ. ដោយប្រើក្រាប (c)  សិក្សាតាមតម្លៃ m នូវអត្ថិភាពនៃឬស សមីការ៖

$$x^3-(m+8)x^2+(2m+13)x-(m+2)=0$$

សមីការនេះអាចសរសេរដូចខាងក្រោម៖

$$x^3-mx^2-8x^2+2mx+13x-m-2=0$$

$$x^3-8x^2+13x-2=m(x^2-2x+1)$$

$$\frac{x^3-8x^2+13x-2}{x^2-2x+1}=m$$

ជាសមីការអាប់ស៊ីសចំណុចប្រសព្វរវាង ខ្សែកោង(c) និងបន្ទាត់ $(\Delta): y = m$ ។

តាមក្រាហ្វិកយើងអាចសន្និដ្ឋានលទ្ធផលដូចខាងក្រោម៖

-ចំពោះ $m \in (-\infty , -2)$ សមីការមានឫសតែមួយគត់ ។

-ចំពោះ $m = -2$ សមីការមានឫសឌុប $x_1 = x_2 = 3$ និងឫសទោល $x_3 = 0$ ។

-ចំពោះ $m \in (-2 , +\infty)$ សមីការមានឫសបីផ្សេងគ្នា ។

## លំហាត់ទី១៨

គេឱ្យអនុគមន៍ $y = f(x) = \dfrac{x^3 - 6x^2 + 9x - 4}{x^2 - 4x + 4}$

ក. សិក្សាអថេរភាព និងសង់ក្រាប (c) តាងអនុគមន៍ f ក្នុងតម្រុយអរតូណរម៉ាល់ $(o, \vec{i}, \vec{j})$ មានឯកតា 1cm នៅលើអក្ស ។

ខ. ដោយប្រើក្រាប (c) ចូរសិក្សាតាមតម្លៃ m នូវអត្ថិភាពនៃឫសរបស់សមីការ $x^3 - (m+6)x^2 + (4m+9)x - 4(m+1) = 0$

( $m \in IR$ ជាប៉ារ៉ាម៉ែត្រ )

## ដំណោះស្រាយ

-ដែនកំនត់ $D = IR - \{ 2 \}$

-ទិសដៅអថេរភាព

.សរសេរជារាងកាណូនិច

$$f(x) = \frac{(x^3 - 4x^2 + 4x) - (2x^2 - 8x + 8) - 3x + 4}{x^2 - 4x + 4}$$

$$f(x) = x - 2 - \frac{3x - 4}{(x-2)^2}$$

.ដេរីវេ $f'(x)=1-\dfrac{3(x-2)^2-2(x-2)(3x-4)}{(x-2)^4}$

$$f'(x)=1-\frac{3x-6-6x+8}{(x-2)^3}$$

$$=\frac{x^3-6x^2+12x-8+3x-2}{(x-2)^3}$$

$$=\frac{x^3-6x^2+15x-10}{(x-2)^3}$$

$$=\frac{(x-1)(x^2-5x+10)}{(x-2)^3}$$

.ចំនុចបរមា

បើ $f'(x)=0$ គេបាន $(x-1)(x^2-5x+10)=0$

ដោយត្រីធា $x^2-5x+10=0\ ,\Delta=25-40<0$ (គ្មានឫស)

ដូចនេះគេបាន $x=1$ ។

អនុគមន៍មានតម្លៃអតិបរមាត្រង់ $x=1$ គឺ $f(1)=1-2-\dfrac{3-4}{(1-2)^2}=0$

.គណនាលីមីត

$$\lim_{x\to 2^-} f(x)=\lim_{x\to 2^-}\left[x-2-\frac{3x-4}{(x-2)^2}\right]=-\infty$$

និង $\lim\limits_{x\to 2^+} f(x)=\lim\limits_{x\to 2+}\left[x-2-\frac{3x-4}{(x-2)^2}\right]=-\infty$

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\left[x-2-\frac{3x-4}{(x-2)^2}\right]=\pm\infty$$

.អាស៊ីមតូត

ដោយគេមាន $\lim\limits_{x\to 1} f(x)=+\infty$ នាំឲ្យបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ ។

ម៉្យាងទៀតគេមាន $f(x)=x-2-\frac{3x-4}{(x-2)^2}$

ដោយ $\lim\limits_{x\to\pm\infty}\frac{3x-4}{(x-2)^2}=0$ ដូចនេះបន្ទាត់ $y=x-2$ ជាអាស៊ីមតូតទ្រេត នៃខ្សែកោង (c) ។

.តារាងអថេរភាព

| $x$ | $-\infty$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | | $0$ | | \|\| | | |
| $f(x)$ | $-\infty$ | ↗ | $0$ | ↘ $-\infty$ | \|\| | $-\infty$ ↗ | $+\infty$ |

-សង់ក្រាប $(c): y = \dfrac{x^3 - 6x^2 + 9x - 4}{x^2 - 4x + 4}$




ខ. ដោយប្រើក្រាប (c) សិក្សាតាមតម្លៃ m នូវអត្ថិភាពនៃឬសរបស់

សមីការ $x^3 - (m+6)x^2 + (4m+9)x - 4(m+1) = 0$

សមីការនេះអាចសរសេរ $\dfrac{x^3 - 6x^2 + 9x - 4}{x^2 - 4x + 4} = m$

ជាសមីការអាប់ស៊ីសចំណុចប្រសព្វរវាង ខ្សែកោង(c) និងបន្ទាត់ $(\Delta): y = m$ ។

តាមក្រាហ្វិកយើងអាចសន្និដ្ឋានលទ្ធផលដូចខាងក្រោមៈ

-ចំពោះ $m \in (-\infty, 0)$ សមីការមានឫសបីផ្សេងគ្នា ។

-ចំពោះ $m = 0$ សមីការមានឫសឌុប $x_1 = x_2 = 1$ និងឫសទោល $x_3 = 4$ ។

-ចំពោះ $m \in (0, +\infty)$ សមីការមានឫសតែមួយគត់។

# លំហាត់ទី១៩

គេឱ្យអនុគមន៍ $f(x)=(1-x).e^{x}-1$ កំនត់លើ IR ។

ក. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ f ។

ទាញបញ្ជាក់សញ្ញានៃអនុគន៍ $f(x)$ ។

ខ. គេឱ្យ g ជាអនុគមន៍ កំនត់លើ IR ដោយ $g(x)=(2-x).e^{x}+2-x$

ចូរគណនាលីមីត $\lim\limits_{x\to-\infty} g(x)$ និង $\lim\limits_{x\to+\infty} g(x)$ ។

គ. គណនាដេរីវេ $g'(x)$ រួចបញ្ជាក់សញ្ញារបស់ $g'(x)$ ។

គូសតារាងអថេរភាពនៃ $g(x)$ ។

ឃ. ស្រាយបញ្ជាក់ថាបន្ទាត់ $(d): y=2-x$ ជាអាស៊ីមតូតទ្រេតនៃក្រាប

$(C)$ តាងអនុគមន៍g កាលណា $x\to-\infty$ ។

សិក្សាទីតាំងធៀបរវាងខ្សែកោង $(C)$ និងបន្ទាត់ $(d)$ ។

ង.សរសេរសមីការបន្ទាត់ $(T)$ ប៉ះនឹង $(C)$ ហើយស្របនឹងបន្ទាត់$(d)$ ។

ច. កំនត់កូអរដោនេចំនុចរបត់ I របស់ខ្សែកោង $(C)$ ។

ឆ. សង់ក្រាប$(C)$ បន្ទាត់$(T)$ និង$(d)$ ក្នុងតំរុយអរតូណរម៉ាល់ $(0,\vec{i},\vec{j})$

# ដំណោះស្រាយ

ក. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f$

គេមាន $f'(x)=(1-x)'.e^x+\left(e^x\right)'.(1-x)$

$$=-e^x+e^x(1-x)$$

$$=-e^x+e^x-x.e^x$$

$$=-x.e^x$$

បើ $f'(x)=-x.e^x=0$ នាំអោយ $x=0$ ។

ចំពោះ $x=0$ គេបាន $f(0)=(1-0).e^0-1=0$ ។

គណនាលីមីត:

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}\left[(1-x).e^x-1\right]=-1$$

និង $\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left[(1-x).e^x-1\right]=-\infty$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-1$ | ↗ | $0$ | ↘ | $-\infty$ |

ទាញបញ្ហាក់សញ្ញានៃអនុគមន៍ $f(x)$ ៈ

តាមតារាងខាងលើគេទាញបាន $\forall x \in IR : f(x) \le 0$ ។

ខ/គណនាលីមីត $\lim_{x\to-\infty} g(x)$ និង $\lim_{x\to+\infty} g(x)$ ៖

គេបាន $\lim_{x\to-\infty} g(x) = \lim_{x\to-\infty}\left[(2-x).e^x + (2-x)\right] = +\infty$

ព្រោះ $\begin{cases} \lim_{x\to-\infty}(2-x) = +\infty \\ \lim_{x\to-\infty}\left(e^x\right) = 0 \end{cases}$

គេបាន $\lim_{x\to+\infty} g(x) = \lim_{x\to+\infty}\left[(2-x).e^x + (2-x)\right] = -\infty$

ព្រោះ $\begin{cases} \lim_{x\to+\infty}(2-x) = -\infty \\ \lim_{x\to+\infty}\left(e^x\right) = +\infty \end{cases}$

គ. គណនាដេរីវេ $g'(x)$ រួចបញ្ហាក់សញ្ញារបស់ $g'(x)$ ៈ

គេមាន $g(x) = (2-x).e^x + 2 - x = (2-x)\left(e^x + 1\right)$

គេបាន $g'(x) = (2-x)'\left(e^x+1\right) + \left(e^x+1\right)'(2-x)$

$$= -\left(e^x + 1\right) + e^x.(2 - x)$$

$$= -e^x - 1 + 2e^x - x.e^x = e^x - x.e^x - 1$$

$$= (1 - x).e^x - 1$$

ដូចនេះ $g'(x) = (1 - x).e^x - 1$

ម៉្យាងទៀតដោយ $g'(x) = (1 - x).e^x - 1 = f(x)$

ហើយគេមាន $\forall x \in IR : f(x) \le 0$

ដូចនេះ $\forall x \in IR : g'(x) \le 0$ ។

គូសតារាងអថេរភាពនៃ $g(x)$ ៖

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $g'(x)$ | | $-$ | $0$ | $-$ | |
| $g(x)$ | $+\infty$ | ↘ | $4$ | ↘ | $-\infty$ |

ចំពោះ $x = 0$ នាំអោយ $g(0) = 4$

ឃ. ស្រាយ ថាបន្ទាត់ $(d): y = 2 - x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$

គេមាន $\begin{cases} (C): g(x) = (2-x).e^x + 2 - x \\ (d): y = 2 - x \end{cases}$

គេបាន $g(x) - y = (2-x).e^x$

ដោយគេមាន $\lim_{x\to-\infty}\left[g(x) - y\right] = \lim_{x\to-\infty}\left[(2-x).e^x\right] = 0$

ដូចនេះ បន្ទាត់ $(d): y = 2 - x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

សិក្សាទីតាំងធៀបរវាងខ្សែកោង $(C)$ និងបន្ទាត់ $(d)$ ៈ

គេមាន $g(x) - y = (2-x).e^x$ មានសញ្ញាដូច $2 - x$

ព្រោះ $\forall x \in IR : e^x > 0$ ។

-ចំពោះ $x \in ]-\infty, 2[$ ខ្សែកោង $(C)$ នៅពីលើបន្ទាត់ $(d)$ ។

-ចំពោះ $x = 2$ ខ្សែកោង $(C)$ ប្រសព្វបន្ទាត់ $(d)$ ត្រង់ចំនុច $A(2,0)$ ។

-ចំពោះ $x \in ]2, +\infty[$ ខ្សែកោង $(C)$ នៅពីក្រោមបន្ទាត់ $(d)$ ។

ង. រកសមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង $(C)$ ហើយស្របនឹង $(d)$ ៖

តាង $M_0(x_0, y_0)$ ជាចំនុចប៉ះរវាងបន្ទាត់ $(T)$ ជាមួយ $(C)$

តាមរូបមន្ត $(T): y - y_0 = y'_0 .(x - x_0)$

ដោយ $(T)//(d): y = 2 - x$ នាំឱ្យ $y'_0 = -1$

តែ $y'_0 = g'(x_0) = (1 - x_0)e^{x0} - 1$

គេទាញបាន $(1 - x_0)e^{x0} - 1 = -1$ នាំឱ្យ $x_0 = 1$

ហើយ $y_0 = g(x_0) = e + 1$ ។

គេបាន $(T): y - (e + 1) = -1.(x - 1)$

ដូចនេះ $(T): y = -x + e + 2$ ។

ច. កំនត់កូអរដោនេចំនុចរបត់ $I$ របស់ខ្សែកោង $(C)$ ៖

គេមាន $g'(x) = (1 - x).e^x - 1 = f(x)$

គេបាន $g''(x) = f'(x) = -x.e^x$ មានឫស $x = 0$ ។

ចំពោះ $x = 0$ គេបាន $g(0) = 4$ ។

តារាងសិក្សាសញ្ញានៃ $g''(x) = -x.e^{x}$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $g''(x)$ | | | |
| $g(x)$ | | | |

ដោយត្រង់ចំនុច $x = 0$ កន្សោម $g''(x)$ ប្តូរសញ្ញាពី $(+)$ ទៅ $(-)$

នាំឱ្យ $I(0,4)$ ជាចំនុចរបត់នៃក្រាប ។

ឆ. សង់ក្រាប $(C)$ បន្ទាត់ $(T)$ និង $(d)$ ក្នុងតំរុយអរតូណរម៉ាល់៖



## លំហាត់ទី២០

គេឱ្យអនុគមន៍ $f(x)=(x-1)(e^{2x}+1)$ ដែល $x\in IR$ ។

ក-ចូរគណនាលីមីត $\lim_{x\to-\infty} f(x)$ និង $\lim_{x\to+\infty} f(x)$ ។

ខ-គណនាដេរីវេ $f'(x)$ និង $f''(x)$ រួចគូសតារាងអថេរភាពនៃ $f'(x)$ ។

( មិនបាច់រកលីមីតនៃ $f'(x)$ ត្រង់ $-\infty$ និង $+\infty$ ) ។

គ-កំនត់សញ្ញារបស់ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f(x)$ ។

ឃ-ស្រាយបញ្ជាក់ថាបន្ទាត់ $(d): y=x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប

$(c)$ នៃ $y=f(x)$ ។កាលណា $x\to-\infty$ ។

បញ្ជាក់ទីតាំងធៀបរវាងខ្សែកោង $(c)$ និងបន្ទាត់ $(d)$

ង-កំនត់សមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង $(c)$ ហើយស្របជាមួយនឹងបន្ទាត់ $(d)$ ។

ច-ចូរគូសក្រាប $(c)$ និងបន្ទាត់ $(d),(T)$ ក្នុងតម្រុយអរតូនរម៉ាល់

$(o,\vec{i},\vec{j})$ តែមួយ ។

# ដំណោះស្រាយ

ក-គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$

យើងមាន $f(x)=(x-1)(e^{2x}+1)$

យើងបាន $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left[(x-1)(e^{2x}+1)\right]=-\infty$

ព្រោះ $\begin{cases}\lim\limits_{x\to-\infty}(x-1)=-\infty\\ \lim\limits_{x\to-\infty}(e^{2x}+1)=1\end{cases}$

និង $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to-\infty}\left[(x-1)(e^{2x}+1)\right]=+\infty$

ព្រោះ $\begin{cases}\lim\limits_{x\to+\infty}(x-1)=+\infty\\ \lim\limits_{x\to+\infty}(e^{2x}+1)=+\infty\end{cases}$

ខ-គណនាដេរីវេ $f'(x)$ និង $f''(x)$

យើងមាន $f(x)=(x-1)(e^{2x}+1)$ កំនត់លើ $D=IR$

យើងបាន $f'(x)=(x-1)'(e^{2x}+1)+(e^{2x}+1)'(x-1)$

$$=e^{2x}+1+2e^{2x}(x-1)$$

$$=1+(2x-1)e^{2x}$$

និង $f''(x)=(2x-1)'e^{2x}+(e^{2x})'(2x-1)=4xe^{2x}$

ដូចនេះ $f'(x)=1+(2x-1)e^{2x}$ , $f''(x)=4xe^{2x}$ ។

គូសតារាងអថេរភាពនៃ $f'(x)$

យើងមាន $f''(x)=4xe^{x}$ មានឫស $x=0$

ចំពោះ $x=0$ នោះ $f'(0)=1-1=0$ ។




គ-កំនត់សញ្ញារបស់ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f(x)$

តាមតារាងអថេរភាពខាងលើយើងទាញបាន $f'(x)\geq 0$ , $\forall x\in IR$

ដូចនេះ $f'(x)$ មានសញ្ញាវិជ្ជមាន ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-2$ | ↗ | $+\infty$ |

ឃ-ស្រាយបញ្ជាក់ថាបន្ទាត់ $(d): y = x - 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប

យើងមាន $f(x) = (x-1)(e^{2x}+1) = x - 1 + (x-1)e^{2x}$

ដោយគេមាន $\lim\limits_{x\to-\infty} (x-1)e^{2x} = 0$

ដូចនេះ បន្ទាត់ $(d): y = x - 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប$(c)$ ។

-បញ្ជាក់ទីតាំងធៀបរវាងខ្សែកោង $(c)$ និងបន្ទាត់ $(d)$ ៈ

គេមាន $f(x) - y = (x-1)\,e^{2x}$ មានសញ្ញាដូច $x-1$

ព្រោះ $e^{2x} > 0 , \forall x \in IR$ ។

-បើ $x - 1 > 0$ ឬ $x > 1$ នោះខ្សែកោង $(c)$ នៅលើបន្ទាត់ $(d)$ ។

-បើ $x-1<0$ ឬ $x<1$ នោះខ្សែកោង (c) នៅក្រោមបន្ទាត់ (d) ។

-បើ $x-1=0$ ឬ $x=1$ នោះខ្សែកោងកាត់បន្ទាត់ត្រង់ចំនុចមួយ

$A(1,0)$ ។

ង-កំនត់សមីការបន្ទាត់ (T) ប៉ះនឹងខ្សែកោង (c) ៖

តាង $M_0(x_0,y_0)$ ជាចំនុចប៉ះរវាងបន្ទាត់ (T) និងក្រាប (c)

តាមរូបមន្តសមីការបន្ទាត់ប៉ះសរសេរ $(T): y-y_0=f'(x_0)(x-x_0)$

ដោយ $(T)//(d): y=x-1$ នាំឱ្យ $f'(x_0)=1$

តែ $f'(x_0)=1+(2x_0-1)e^{2x_0}$

គេបាន $1+(2x_0-1)e^{2x_0}=1$ នាំឱ្យ $x_0=\frac{1}{2}$

ហើយ $y_0=f(\frac{1}{2})=(\frac{1}{2}-1)(e+1)=-\frac{1}{2}(e+1)$

គេបាន $(T):\ y+\frac{1}{2}(e+1)=1(x-\frac{1}{2})$ នាំឱ្យ $y=x-1-\frac{e}{2}$ ។

ដូចនេះ $(T):\ y=x-1-\frac{e}{2}$ ។

ច-គូសក្រាប (c) និងបន្ទាត់ (d),(T) ៖

-កូអរដោនេចំណុចប្រសព្វរវាង(c) ជាមួយអក្ស័អាប់ស៊ីស ៖

គឺ $y=(x-1)(e^{2x}+1)=0$ នោះ $x=1$ ។

-កូអរដោនេចំណុចប្រសព្វរវាង(c) ជាមួយអក្ស័អរដោណេ ៖

គឺ $x=0$ នោះ $x=1$ ។



ជំពូកទី៥

# លំហាត់អនុវត្តន៍

១-ចូរគណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

1/ $y = 3\cos x - \cos^3 x$

2/ $y = \sin^3 x \cos 3x$

3/ $y = \sin 4x \cos^4 x$

4/ $y = \dfrac{\sin x}{1 + \sin x}$

5/ $y = \dfrac{\cos x}{1 - \cos x}$

6/ $y = \dfrac{\sin x - \cos x}{\sin x + \cos x}$

7/ $y = \dfrac{1 - \tan x}{1 + \tan x}$

8/ $y = \dfrac{1}{2}\tan^2 x + \dfrac{1}{3}\tan^3 x$

9/ $y = x - \cot x$

10/ $y = \cot^4 x$

២-គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

1/ $y = \dfrac{e^x - 1}{e^x + 1}$

2/ $y = (x^2 - x + 1)e^{-x}$

3/ $y = e^{-x^2}$

4/ $y = x^3 e^{2x}$

5/ $y = (x^2 - x)e^x$

6/ $y = \dfrac{e^{2x} - e^{-2x}}{2}$

៣-គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

1/ $y=\frac{x+\ln x}{x}$ 2/ $y=\frac{\ln x}{x^2}$

3/ $y=1-x+x\ln x$ 4/ $y=\ln\frac{x-1}{x+1}$

5/ $y=\ln(x^2-4x+3)$ 6/ $y=\ln(x+\sqrt{x^2+4})$

៤-គេឲ្យត្រីកោណ ABC មួយចារិកក្នុងរង្វង់ផ្ចិត O ដែលមានកាំ 6 cm ។

គេដឹងថា $\angle BOC=120^0$ ។

ចូរកំនត់ជ្រុងរបស់ត្រីកោណនេះដើម្បីឲ្យវាមានក្រឡាផ្ទៃអតិបរមា

រួចកំនត់រកក្រឡាផ្ទៃអតិបរមានោះ

៥-គេមានត្រីកោណ ABC មួយមានជ្រុង ៖

AB = 3 cm , AC = 4 cm , BC = 5 cm ។

M និង N ជាចំនុចស្ថិតនៅលើជ្រុងរៀងគ្នា [AB] និង [AC]

ដែល MN = 3 cm កំនត់រកក្រឡាផ្ទៃរបស់ចតុកោណ BMNC

បើផលបូកអង្កត់ទ្រូងទាំងពីររបស់វាមានតម្លៃអតិបរមា ។

៦-គេឲ្យចតុកោណព្នាយ **ABCD** មួយកែងត្រង់ **A** និង **D** ហើយគេយក **M** ជាចំនុចមួយនៃ**[AD]** ។គេដឹងថា $AB = 8$ cm , $AD = 10$ cm និង $CD = 12$ cm ។

ចូរកំនត់រកទីតាំងនៃចំនុច **M** ដើម្បីឲ្យត្រីកោណ **MBC** មានបរិមាត្រតូចបំផុត ។

៧-គេឲ្យកន្លះរង្វង់មួយមានវិជ្ឈមាត្រ $AB = 8$cm ហើយ **P** ជាចំនុចមួយនៃកន្លះរង្វង់នេះ ។

គេតាង $PA = x$ , $PB = y$ ដែល $0 < x < 8$ cm , $0 < y < 8$ cm ។

កំនត់ $x$ និង $y$ ដើម្បីឲ្យក្រឡាផ្ទៃត្រីកោណ **PAB** មានតម្លៃអតិបរមា

៨-ត្រីកោណ **ABC** មួយកែងត្រង់ **A** ដែល $AB = 5$ cm និង $AC = 12$ cm យក**M** ជាចំនុចមួយនៃជ្រុង **[AC]** ដែល $AM = x$ ។

តាម **M** គេសង់ចតុកោណកែង **MNPA** ចារិកក្នុងត្រីកោណនេះ

កំនត់ $x$ ដើម្បីឲ្យចតុកោណ**MNPA** មានក្រឡាផ្ទៃអតិបរមារួចកំនត់រកក្រឡាផ្ទៃអតិបរមានោះ ។

៩-គេឲ្យត្រីកោណ **ABC** មួយមានជ្រុង

**AB = 51 cm , AC = 52 cm , BC = 53 cm** ។

**M** ជាចំនុចមួយនៃជ្រុង **[AB]** ។

តាម **M** គេគូសបន្ទាត់ **(MN)** ស្របនឹងជ្រុង **[BC]** ហើយកាត់ជ្រុង

**[AC]** ត្រង់ **N** ។ **K** និង **L** ជាជើងនៃចំណោលកែងចំនុច **M**

និង **N** រៀងគ្នាលើជ្រុង **[BC]** ។យក **AM = x** ដែល $0 < x < 51$ **cm**

កំនត់តម្លៃ **x** ដើម្បីឲ្យចតុកោណ **KMNL** មានក្រឡាផ្ទៃអតិបរមា ។

១០-ក្នុងតម្រុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ គេសង់បន្ទាត់ **(L)** កាត់តាម

ចំនុច $A(3,4)$ ។បន្ទាត់ **(L)** កាត់អក្ស័ **(ox)** ត្រង់ **P**

និង កាត់អក្ស័ **(oy)** ត្រង់ **Q** ។ គេសន្មតថា $P(a,0)$

និង $Q(0,b)$ ដែល $a > 0 , b > 0$ ។

កំនត់ **a** និង **b** ដើម្បីឲ្យត្រីកោណ **OPQ** មានក្រឡាផ្ទៃអប្បបរមា

១១-ក្នុងតម្រុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ គេមានចំនុច $P(x,y)$ មួយ

ដែល $x>0, y>0$ ។K និង L ជាចំណោលកែងនៃចំនុច P

លើអក្ស័រៀងគ្នា (ox) និង (oy) ។

ក.កំនត់សំណុំចំនុច P ដើម្បីឲ្យបរិមាត្រត្រីកោណ KPL

ស្មើនឹង 12cm ។

ខ.សន្មត់ថាបរិមាត្រត្រីកោណ KPL ស្មើនឹង 12cm ។

កំនត់ទីតាំងចំនុ P ដើម្បីឲ្យត្រីកោណKPL មានក្រឡាផ្ទៃអតិបរមា ។

១២-គេចង់ធ្វើអាងទឹកមួយគ្មានគំរបរាងចតុកោណកែងដែលមានបាត

ខាងក្នុងជាការេ ហើយផ្ទៃខាងសរុបផ្នែកខាងក្នុងអាងស្មើនឹង $108\ m^2$

កំនត់រកវិមាត្ររបស់អាងទឹកនេះដើម្បីឲ្យវាអាចដាក់ទឹកបានច្រើនបំផុត ។

១៣-បង្គោលពីរមួយមានកំពស់4 m និងមួយទៀតមានកំពស់9m ដាក់

បញ្ឈរឃ្លាតពីគ្នា 10m ដើម្បីឲ្យបង្គោលទាំងពីរនៅនឹងគេបានចងខ្សែ

លួសពីរខ្សែភ្ជាប់ទៅនឹងស្នឹងមួយទៅកំពូលបង្គោលនីមួយៗ ។

តើគេត្រូវបោះស្នឹងនៅត្រង់ណាដើម្បីឲ្យប្រើខ្សែលួសអស់តិចបំផុត ។

១៤-កោណមួយមានកំពស់ $15\ cm$ កាំថាសបាត $6\ cm$ ។

គេសង់ស៊ីឡាំងមួយចារិកក្នុងកោណនេះ ។

កំនត់កពស់និងកាំថាសបាត ស៊ីឡាំងដើម្បីឲ្យវាមានមាឌអតិបរមា

១៥-គេឲ្យស្វ៊ែមួយមានកាំ $6\ cm$ ។ គេសង់ស៊ីឡាំងមួយចារិកក្នុងស្វ៊ែនេះ

កំនត់កពស់និងកាំថាសបាតនៃស៊ីឡាំងដើម្បីឲ្យវាមានមាឌអតិបរមា

១៦-គេកាត់ចំរៀកថាសមួយមានមុំផ្ចិត $\theta$ ចេញពីរង្វង់មួយមានកាំ

$r = 12\ dm$ ហើយចំរៀកថាសដែលនៅសល់ពីកាត់ គេបានយក

ទៅធ្វើជាកោនមួយ ។

គណនារង្វាស់មុំ $\theta$ ដើម្បីឲ្យកោនមានមាឌអតិបរមា ។

១៧-មនុស្សពីរនាក់ស្ថិតនៅចម្ងាយពីគ្នា $100\ km$ រត់សំដៅរកចំនុច $O$

លើផ្លូវពីរកែងគ្នា ។មនុស្សទីមួយរត់ចេញពីរចំនុច $A$ ដោយល្បឿន

$10\ km/h$ ហើយមនុស្សទីពីររត់ចេញពីចំនុច $B$ ដោយល្បឿន

$12\ km/h$ ។ គេដឹងថា $OA = 60\ km$ , $OB = 80\ km$ ។

ចូរគណនាចម្ងាយអប្បបរមានៃមនុស្សទាំងពីរនាក់ ។

១៨-ត្រីកោណ **ABC** មួយមានបរិមាត្រ $15\ cm$ និងមុំ $A = 120^0$ ។

តាង $x$ , $y$ , $z$ ជារង្វាស់ជ្រុងរបស់ត្រីកោណនេះ ។

ចូរកំនត់ $x$ , $y$ , $z$ ដើម្បីឲ្យត្រីកោណ **ABC** ។

មានក្រឡាផ្ទៃអតិបរមា ។

១៩-ប្រលេពីប៉ែតកែងមួយមានវិមាត្រតាងដោយ **a , b , c**

ហើយមានមាឌ $27\ cm^3$ ។

បើគេបន្ថែម **1cm** ទៅលើទ្រនុង **a** ហើយ **1cm** លើទ្រនុង **b**

និង **1 cm** លើទ្រនុង **c** នោះគេបានប្រលេពីប៉ែតកែងមួយទៀត

មានមាឌ **V** ។ កំនត់ **a , b , c** កាលណា **V** មានតម្លៃអប្បបរមា

២០-គេឲ្យពីរចំនួនពិត $x$ និង $y$ ផ្ទៀងផ្ទាត់សមីការ $x^2 - xy + y^2 = 12$

ចូររកតម្លៃអតិបរមា និង អប្បបរមានៃ $P(x;y) = (x^2 - 2)(y^2 - 2)$

២១-បុរសម្នាក់នៅលើទូកចំងាយ **2 km** ពីចំនុចជិតបំផុត

នៅលើឆ្នេរសមុត្រ ។គាត់បានធ្វើដំណើរឆ្ពោះទៅរកចំនុច **Q**

មួយនៅខាងក្រោមឆ្នេរមានចម្ងាយ **3 km** និង **1 km** ពីមាត់សមុទ្រ

បើគាត់អុំទូកក្នុងល្បឿន $2\ km/h$ និងដើរក្នុងល្បឿន $4km/h$

ចូររកទីតាំងនៅលើឆ្នេរដែលគាត់ត្រូវធ្វើដំណើរឆ្ពោះទៅដល់ចំនុច Q

ដោយប្រើពេលអស់តិចបំផុត ។

២២-ក្នុងតម្រុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ គេឲ្យអេលីប $(E)$

មានសមីការ $x^2+4y^2=1$ ដែលនៅលើនោះគេមានចំនុច $M_0(x_0, y_0)$

ដែល $x_0>0$ , $y_{.0}>0$ ។

គេគូសបន្ទាត់ $(L)$ មួយប៉ះទៅនឹងអេលីបនេះ ។

K និង L ជាចំនុចប្រសព្វរវាងបន្ទាត់ $(L)$ ជាមួយអក្ស័រៀងគ្នា

$(ox)$ និង $(oy)$ ។កំនត់ទីតាំងនៃចំនុច $M_0$ ដើម្បីឲ្យត្រីកោណ OKL

មានក្រឡាផ្ទៃអតិបរមា។

២៣-គេឲ្យអនុគមន៍ $f(x)=\dfrac{x^2-x+2}{x}$ មានខ្សែកោងតំនាង$(c)$

ក្នុងតំរុយអរតូនរម៉ាល់$(O,\vec{i},\vec{j})$ និង $(\Delta)$ ជាបន្ទាត់មានសមីការ

$y=mx-2m+3$ ដែល $m\in IR$ ជាប៉ារ៉ាម៉ែត្រ ។

ក.បើ $m=1$ ចូររកគណនាកូអរដោនេចំនុចប្រសព្វ A រវាងបន្ទាត់ $(\Delta)$ ជាមួយខ្សែកោង (c) ។

ខ.បើ $m\neq 1$ ចូរបង្ហាញថាបន្ទាត់ $(\Delta)$ កាត់ខ្សែកោង(c) ជានិច្ចត្រង់ពីរ

ចំនុច P និង Q ។

គ.បង្ហាញថាបន្ទាត់ (AP) និង (AQ) កែងនឹងគ្នាជានិច្ចគ្រប់តម្លៃ m ។

២៤-គេឲ្យអនុគមន៍ $f(x)=\dfrac{x^2-3x+4}{x-1}$

មានខ្សែកោងតំនាង(c) ក្នុងតំរុយអរតូនរម៉ាល់ $(O,\vec{i},\vec{j})$

ក.ចូររកសមីការបន្ទាត់(T) ដែលប៉ះនឹងខ្សែកោង(c) ត្រង់ចំនុច A

មានអាប់ស៊ីស $x=2$ ។

ខ.តើបន្ទាត់ $(\Delta)$ មានមេគុណប្រាប់ទិស m ត្រូវគូសចេញពីចំនុចណា

ដើម្បីឲ្យកាត់ខ្សែកោង (c) បានពីរចំនុច K និង L ដែលបន្ទាត់ភ្ជាប់ពី

ចំនុច K និង L ទៅចំនុច A កែងនឹងគ្នាជានិច្ចចំពោះគ្រប់តម្លៃ m ។

២៥-គេឲ្យខ្សែកោង (c) មានសមីការ $y = f(x) = \frac{x^2}{2} - 3x + \frac{5}{2}$

តើបន្ទាត់ ($\Delta$) មានមេគុណប្រាប់ទិស m ត្រូវគូសចេញពីចំនុចណា

ដើម្បីឲ្យកាត់ខ្សែកោង (c) បានពីរចំនុច K និង L ដែលបន្ទាត់ប៉ះ

(c) ត្រង់ K និង L កែងនឹងគ្នាជានិច្ចចំពោះគ្រប់តម្លៃ m ។

២៦-គេឲ្យខ្សែកោង(c) មានសមីការ $y = \frac{x^2 - (m+1)x + 2m - 1}{x - 2}$

ដែល $m \in IR$ ជាប៉ារ៉ាម៉ែត្រ ។

បង្ហាញថាខ្សែកោង (c) មានកំពូលពីរជានិច្ចដែលមានចម្ងាយពីគ្នាថេរ

ចំពោះគ្រប់ m ។

២៧-គេឲ្យខ្សែកោង ($c_m$) តាងអនុគមន៍

$$f(x) = \frac{x^2 - 2(m+1)x + 5m - 1}{x - m}$$

ក.រកលក្ខខណ្ឌសម្រាប់ m ដើម្បីឲ្យខ្សែកោង ($c_m$) មានអាស៊ីមតូតពីរ

ដែលត្រូវកំនត់ ។

ខ.តាង I ជាចំនុចប្រសព្វរវាងអាស៊ីមតូតទាំងពីរ ។

រកសំណុំចំនុច $I$ កាលណា $m$ ប្រែប្រួល។

គ.បង្ហាញថាមានខ្សែកោងពីរនៃគ្រួសារខ្សែកោង $(c_m)$ ដែលប៉ះនឹង

អក្ស័អាប់ស៊ីស ។

២៨-គេឲ្យអនុគមន៍ $f(b)=\sum_{k=1}^{n}\left[\ (y_k-ax_k-b\ )^2\ \right]$ ។

ចូរស្រាយថាអនុគមន៍ $f(b)$ មានតម្លៃអប្បបរមាលុះត្រាតែគេមាន

ទំនាក់ទំនង $\bar{y}=a\bar{x}+b$ ដែល $\bar{x}=\dfrac{\sum_{k=1}^{n}(x_k)}{n}$ និង $\bar{y}=\dfrac{\sum_{k=1}^{n}(y_k)}{n}$ ។

២៩-គេឲ្យអនុគមន៍ $f(x)=\dfrac{\sin x+2\cos x+3}{3\cos x+2}$ ។

ចូររកតម្លៃអតិបរមា និង អប្បរមានៃអនុគមន៍នេះ ។

៣០-គេឲ្យអនុគមន៍ $y=f(x)=\dfrac{x^2+(m+1)x+2m-1}{x+2}$

ចូរកំនត់តម្លៃរបស់ $m$ ដើម្បីឲ្យអនុគមន៍នេះមានតម្លៃអតិបរមាស្មើ $\alpha$

និង មានតម្លៃអប្បបរមាស្មើ $\beta$ ដែល $\alpha^2+\beta^2=10$ ។

៣២-គេឲ្យអនុគមន៍ $y=f(x)=\dfrac{x^2-mx+3}{x-2}$

ចូរកំនត់តម្លៃរបស់ $m$ ដើម្បីឲ្យអនុគមន៍នេះមានតម្លៃអតិបរមាស្មើ $\alpha$ និង មានតម្លៃអប្បបរមាស្មើ $\beta$ ដែល $|\alpha-\beta|=4$ ។

៣៣-គេមានអនុគមន៍ $y=f(x)=\dfrac{ax^2+bx+4}{x^2+1}$

កំនត់ចំនួនពិត $a$ និង $b$ ដើម្បីឲ្យអនុគមន៍ $f(x)$ មានចំនុចបរមាតែមួយគត់ និង មានបន្ទាត់ $y=2$ ជាអាស៊ីតូតឈរ ។

៣៤-គេឲ្យអនុគមន៍ $y=f(x)=\dfrac{x^2-x+1}{x^2-3x+3}$

ដោយមិនប្រើដេរីវេចូរកំនត់រកតម្លៃអតិបរមានិងអប្បបរមានៃអនុគមន៍

៣៥-គេឲ្យអនុគមន៍ $y=f(x)=\dfrac{x^2+ax+b}{x^2+1}$

ចូររកលក្ខខ័ណ្ឌនៃ $a$ និង $b$ ដើម្បីឲ្យខ្សែកោង $(c)$ តាងអនុគមន៍ $f(x)$ កាត់អក្សអាប់ស៊ីសបានពីរចំនុចដែលបន្ទាត់ប៉ះវាត្រង់ពីរចំនុចនោះកែងនឹងគ្នា ។

៣៦-គេឲ្យអនុគមន៍ $f(x)=\dfrac{x^3-3mx^2+3(m^2-1)x-m^3+2}{x^2+1}$

កំនត់តម្លៃ $m$ ដើម្បីឲ្យខ្សែកោង $(c)$ តាងអនុគមន៍ $f(x)$

កាត់អក្ស័អាប់ស៊ីសបានបីចំនុចផ្សេងគ្នាដែលមានអាប់ស៊ីសវិជ្ជមាន ។

៣៧-គេឲ្យអនុគមន៍ $f(x)=\dfrac{ax^2+bx+c}{x+d}$

ចូរកំនត់បួនចំនួនពិត $a , b , c , d$ ដើម្បីឲ្យអនុគមន៍នេះមានតម្លៃ

អប្បបរមា $f(3)=3$ និងមានបន្ទាត់ $y=x-1$ ជាអាស៊ីមតូតទ្រេត ។

៣៨-គេឲ្យអនុគមន៍ $f(x)=\dfrac{ax^2+bx+2}{x^2+2x+4}$ កំនត់ $a ,b , c$ ដើម្បីឲ្យ $f(x)$

ជាអនុគមន៍ថេរ ។

៣៩-គេឲ្យអនុគមន៍ $f(x)=\dfrac{x^2+2}{x}$ មានខ្សែកោង $(c)$ និងបន្ទាត់

$(d):\ y=mx+2\sqrt{3}$ ដែល $m$ ជាប៉ារ៉ាម៉ែត្រ។

ក-កំនត់វ៉ង់របស $m$ ដើម្បីឲ្យ $(d)$ កាត់ $(c)$ បានពីរចំនុច $A$ និង $B$ ។

ខ-កំនត់តម្លៃ$m$ ដើម្បីឲ្យបន្ទាត់ប៉ះ$(c)$ ត្រង់ចំនុច $A$ និង $B$ កែងនឹងគ្នា ។

៤០-គេឲ្យខ្សែកោង $(c): y = x^2 - 2x + 3$ និងចំនុច $A(6, 1)$ ។

ចូររកចំនុចទាំងអស់នៅលើខ្សែកោង (c) ដែលមានចំងាយខ្លីបំផុតទៅ

ចំនុច A ។

៤១-គេឲ្យអនុគមន៍ $f(x) = \frac{4\sqrt{2}}{x^2}$ មានខ្សែកោង (c) ។

ចូរសរសេរសមីការរង្វង់ផ្ចិត O ដែលប៉ះទៅនឹងខ្សែកោង (c) ខាងលើ

៤២-គេឲ្យខ្សែកោង $(c): y = x^2$ និងបន្ទាត់ $(d): 4x - y - 21 = 0$

កំនត់រកកូអរដោនេនៃចំនុចទាំងអស់នៅលើខ្សែកោង(c) ដែលមាន

ចំងាយខ្លីបំផុតទៅបន្ទាត់ (d) ។

៤៣-គេឲ្យខ្សែកោង $(c): y = \frac{x^2 - 3x + 1}{x - 1}$ និងបន្ទាត់ $(d): y = ax + b$

កំនត់ a និង b ដើម្បីឲ្យបន្ទាត់ (d) កាត់ខ្សែកោង (c) បានពីរចំនុច A

និង B ឆ្លុះគ្នាធៀបទៅនឹងបន្ទាត់ពុះទីមួយនៃអក្ស័កូអរដោនេ ។

៤៤-គេឲ្យអនុគមន៍ $f(x)=\frac{x^2-x-2}{x}$ មានខ្សែកោង $(c)$ ។

A និង B ជាចំនុចពីរនៅលើ $(c)$ មានអាប់ស៊ីសរៀងគ្នា $\frac{1}{2}$ និង $2$

រកចំនុចទាំងអស់នៅលើខ្សែកោង $(c)$ ដែលបន្ទាត់ប៉ះវាត្រង់ចំនុចទាំង

នោះស្របនឹងបន្ទាត់$(AB)$ ។

៤៥-គេឲ្យអនុគមន៍ $f(x)=\frac{x^2-1}{x}$ មានខ្សែកោង $(c)$ ហើយ A និង B

ជាចំនុចពីរមានអាប់ស៊ីសរៀងគ្នា $a$ និង $b$ ដែល $0<a<b$ ស្ថិតនៅ

លើខ្សែកាងនេះ។ ចូរស្រាយថាមានចំនួនពិត $c$ ជានិច្ចស្ថិតនៅចន្លោះ

ចំនួន $a$ និង $b$ ដែលផ្ទៀងផ្ទាត់សមភាព $f(b)-f(a)=f'(c)\,(b-a)$ ។

៤៦-គេឲ្យខ្សែកោង $y=x^2+2x+2$ ហើយ A និង B ជាចំនុចពីរមាន

អាប់ស៊ីសរៀងគ្នា $a$ និង $b$ ស្ថិតនៅលើខ្សែកាងនេះ។

ចូរបំណកស្រាយតាមបែបធរណីមាត្រថា ៖

$f(b)-f(a)=(b-a).f'(\frac{a+b}{2})$ ។

៤៧-ចូរស្រាយបញ្ជាក់ថា $\lim\limits_{x\to a}\dfrac{af(x)-x\,f(a)}{x-a}=af'(a)-f(a)$ ។

៤៨-ចូរស្រាយថា $\lim\limits_{h\to 0}\dfrac{f^2(x+h)-f^2(x-h)}{h}=4f'(x)f(x)$ ។

៤៩-ចូរស្រាយថា $f''(x)=\lim\limits_{\Delta x\to 0}\dfrac{f(x+2\Delta x)-2f(x+\Delta x)+f(x)}{(\Delta x)^2}$ ។

៥០-គេឲ្យអនុគមន៍ $f(x)=e^{ax}+e^{bx}$ ដែល $a,b\in IR$ ។

ចូរកំនត់តម្លៃ $a$ និង $b$ ដើម្បីឲ្យ $f''(x)+f'(x)=2f(x)$ ចំពោះគ្រប់ $x$

៥១-គេឲ្យអនុគមន៍ $f(x)=e^{2x}+e^{3x}$ ។

បង្ហាញថា $f''(x)-5f'(x)+6f(x)=0$ ចំពោះគ្រប់ $x$ ។

៥២-គេឲ្យអនុគមន៍ $f(x)=(\sin 2x+\cos 2x)e^{x}$ ។

បង្ហាញថា $f''(x)-2f'(x)+5f(x)=0$ ចំពោះគ្រប់ $x$ ។

៥៣-ចូរកំនត់រកអនុគមន៍ $y=f(x)$ បើគេដឹងថា ៖

$f'(0)=f(0)=1$ និង $\dfrac{1}{2x-1}f''(x)-\dfrac{2}{(2x-1)^2}f'(x)=6x^2-4x$

៥៤-ចូរកំនត់រកអនុគមន៍ $y=f(x)$ បើគេដឹងថា ៖

$f(0)=2$ និង $f'(x)f^2(x)=x^2-4x+1$

៥៥-ចូរកំនត់រកអនុគមន៍ $y=f(x)$ បើគេដឹងថា ៖

$f(1)=4$ និង $2x\,f(x)+(x^2+1)\,f'(x)=4x^3+3x^2+2x+1$

៥៦-ចូរកំនត់រកអនុគមន៍ $y=f(x)$ បើគេដឹងថា ៖

$f(1)=2$ និង $xf'(x)+2f(x)=4x^2+9x$

៥៧-គេឲ្យអនុគមន៍ $f$ កំនត់ជាប់ និង មានដេរីវេលើ IR

ដែលចំពោះគ្រប់ $x,y\in IR$ គេមាន $f(x+y)=f(x)f(y)$

និង $f'(0)=4$ ។ចូរកំនត់រកអនុគមន៍ $f(x)$ ។

៥៨-ចូរកំនត់រកអនុគមន៍ $f$ មានដេរីវេលើ IR បើគេដឹងថា

$\forall x\in IR, y\in IR$ គេមាន $f\left(\frac{x+y}{2}\right)=\sqrt{f(x)f(y)}$ ។

៥៩-គេឲ្យអនុគមន៍ $f(x)=x^3-6x^2+12x$ កំនត់លើ IR

ក-ចូរកំនត់រកអនុគមន៍ $f^{-1}$ ជាអនុគមន៍ច្រាស់នៃអនុគមន៍ $f$

ខ-ចូរគណនាដេរីវេនៃអនុគមន៍ $f(x)$ និង $f^{-1}(x)$ ។

៦០-គេមានអនុគមន៍ $f$ កំនត់និងមានដេរូវេលើ $IR$ ដែលចំពោះ

គ្រប់ $x\in IR$ គេមានទំនាក់ទំនង $f'(x)=2xf(x)$ ហើយ $f(0)=1$ ។

ចូរកំនត់រកអនុគមន៍ $f(x)$ ។

៦១-គេឲ្យអនុគមន៍ $f$ និង $g$ មានដេរីវេលើ $IR$ ដែលចំពោះគ្រប់

$x\in IR$ គេមានទំនាក់ទំនង $f'(x)\,f^2(x)=g'(x)g^2(x)$ ។

ចូររកទំនាក់ទំនងរវាង $f$ និង $g$ ។

៦២-គេឲ្យអនុគមន៍ $f$ កំនត់លើ $IR$ ដោយ $f(x)=\sqrt{x+\sqrt{1+x^2}}$

ក-បង្ហាញថា $f$ មានដេរីវេលើ $IR$ និង $2\sqrt{1+x^2}.f'(x)=f(x)$

ខ-ទាញបញ្ជាក់ថាដេរីវេ $f''$ ផ្ទៀងផ្ទាត់ទំនាក់ទំនង

$4(1+x^2)f''(x)+4xf'(x)=f(x)$ ។

៦៣-គេឲ្យអនុគមន៍ $f:x\to\sqrt{x+2}$ កំនត់លើ $[-2,+\infty)$ ។

ដោយអនុវត្តន៍វិសមភាពកំនើនមានកំនត់ទៅនឹងអនុគមន៍ $f$

លើចន្លោះ $[-1\,,\,2\,]$ ចូរបង្ហាញថា $\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$ ។

៦៤-គេឲ្យអនុគមន៍ $f$ កំនត់លើ $[\,0\,,2]$ ដោយ $f(x)=\dfrac{1}{x^2+x+1}$

ក/សិក្សាទិសដៅអថេរភាពនៃអនុគមន៍ $f$ ។

ខ/បង្ហាញថាចំពោះគ្រប់ $x\in[0\,,2]:\dfrac{1}{7}\le\dfrac{1}{x^2+x+1}\le 1$ ។

គ/គេឲ្យ $g$ និង $h$ ជាពីរអនុគមន៍កំនត់លើ $[0\,,2]$ ដោយ ៖

$g(x)=f(x)-\left(-\dfrac{1}{3}x+\dfrac{2}{3}\right)$ និង $h(x)=f(x)-\left(-\dfrac{3}{7}x+1\right)$ ។

ចូរសិក្សាសញ្ញានៃ $g$ និង $h$ ។

ឃ/ទាញបញ្ជាក់ថាចំពោះគ្រប់ ៖

$$x\in[0,2]:-\frac{1}{3}x+\frac{2}{3}\le f(x)\le-\frac{3}{7}x+1$$

៦៥-បង្ហាញថាចំពោះគ្រប់ចំនួនពិត $a$ និង $b$ ដែល $0\le a<b<\dfrac{\pi}{2}$

គេបាន $\dfrac{b-a}{\cos^2 a}\le\tan b-\tan a\le\dfrac{b-a}{\cos^2 b}$

រួចទាញរកតម្លៃអមនៃ $\tan(0,6)$ ។

៦៦-បង្ហាញថាចំពោះគ្រប់ចំនួនពិត $a$ និង $b$ ដែល $0 < a \le b$ គេបាន

$\frac{b-a}{b} \le \ln(\frac{b}{a}) \le \frac{b-a}{a}$ រួចទាញរកតម្លៃអមនៃ $\ln(11)$ ។

( គេឲ្យ $\ln 10 = 2.30$ )

៦៧-ក/ចូរស្រាយថា $\forall n \in IN$ : $\frac{1}{n+1} \le \ln(n+1) - \ln(n) \le \frac{1}{n}$ ។

ខ/គេតាង $U_n = 1 + \frac{1}{2} + \frac{1}{3} + \dots\dots\dots\dots + \frac{1}{n}$ ។

ចូររកកន្សោមអមនៃ $U_n$ រួចទាញថា $\lim_{n\to+\infty} U_n = +\infty$ ។

៦៨-ក/ចំពោះគ្រប់ $k \in IN$ ចូរស្រាយថា៖

$$\frac{1}{2\sqrt{1+k}} \le \sqrt{k+1} - \sqrt{k} \le \frac{1}{2\sqrt{k}}$$

ខ/រកកន្សោមអមនៃ $S_n = \frac{1}{\sqrt{n}}(1 + \frac{1}{\sqrt{2}} + \frac{1}{\sqrt{3}} + \dots + \frac{1}{\sqrt{n}})$

រួចទាញរកលីមីតនៃ $S_n$ កាលណា $n \to +\infty$ ។

៦៩-ក/បង្ហាញថាចំពោះគ្រប់ចំនួនពិត $a$ និង $b$ ដែល $0 \le a < b \le \frac{\pi}{2}$

គេបាន $(b-a)\cos b \le \sin b - \sin a \le (b-a)\cos a$ ។

ខ/រកកន្សោមអមនៃ ៖

$$S_n = \frac{1}{n}\left(\cos\frac{\pi}{2n+1} + \cos\frac{2\pi}{2n+1} + ..... + \cos\frac{n\pi}{2n+1}\right)$$

រួចទាញរកលីមីតនៃ $S_n$ កាលណា $n \to +\infty$ ។

៧០-គេឱ្យអនុគមន៍ $y = f(x) = \frac{x^2 - x - 2}{2(x-3)}$ មានក្រាបតំនាង $(c)$ ។

ក. ចូររក $\lim_{x\to 3^-} f(x)$ , $\lim_{x\to 3^+} f(x)$ និង $\lim_{x\to\infty} f(x)$ រួចទាញបញ្ជាក់

សមីការអាស៊ីមតូតឈរនៃក្រាប $(c)$ ។

ខ. ចូររកបីចំនួនពិត $a$ ,$b$ និង $c$ ដើម្បីឱ្យ $f(x) = ax + b + \frac{c}{2(x-3)}$

ចំពោះគ្រប់ $x \ne 3$ ។

ទាញរកសមីការអាស៊ីមតូតទ្រេតនៃក្រាប $(c): y = f(x)$ ។

គ. ចូររកដេរីវេ $y' = f'(x)$ ។ ចូរគូសតារាងអថេរភាពនៃ $f$ ។

ឃ. ចូរស្រាយបញ្ជាក់ថាចំនុច $\Omega(3\ ,\frac{5}{2})$ ជាផ្ចិតបម្លែងឆ្លុះនៃក្រាប(c)

ង. ក្រាប (c) តំនាងអនុគមន៍ $y=f(x)$ កាត់អក្ស័អាប់ស៊ីស (x'0x)

ត្រង់ពីរចំនុច A និង B ។

ចូរសរសេរសមីការបន្ទាត់$(T_1)$ និង$(T_2)$ ដែលប៉ះនឹងខ្សែកោង(c)

ត្រង់ចំនុច A និង B ។

ច. ចូរគណនាតម្លៃ $f(-2)$ ,$f(4)$ និង $f(6)$ ។

ចូរគូសក្រាប (c) ក្នុងតំរុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ ។

៧១-គេមានអនុគមន៍ $y=f(x)=\dfrac{4x-4}{x^2-2x-3}$ មានក្រាបតំនាង (c) ។

ក. ចូររកលីមីត $\lim\limits_{x\to -1^-} f(x)$ , $\lim\limits_{x\to -1^+} f(x)$, $\lim\limits_{x\to 3^-} f(x)$, $\lim\limits_{x\to 3^+} f(x)$

និង $\lim\limits_{x\to\infty} f(x)$ រួចទាញបញ្ជាក់សមីការអាស៊ីមតូតនៃក្រាប (c) ។

ខ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $y=f(x)$ ។

គ. ខ្សែកោង (c) កាត់អក្ស័អាប់ស៊ីស (x'0x) ត្រង់ចំនុច I ។

ចូរបង្ហាញថា I ជាផ្ចិតឆ្លុះនៃក្រាប (c) ។

ចូរសរសេរសមីការបន្ទាត់ (T) ដែលប៉ះទៅនឹងខ្សែកោង (c) ត្រង់ចំនុចរបត់ I ។

ឃ. ចូរសង់ក្រាប (c) តំនាងអនុគមន៍ $y = f(x)$ និង បន្ទាត់ (T) ក្នុងតំរុយអរតូនរម៉ាល់ ។

ង. ដោយប្រើខ្សែកោង (c) ចូរពិភាក្សាតាមតម្លៃ m នូវអត្ថិភាពនៃឫសរបស់សមីការ

$(E)\ :\ mx^2 - 2(m+2)x - 3m + 4 = 0$ ។ ( m ជាប៉ារ៉ាម៉ែត្រ ) ។

៧២-គេឱ្យអនុគមន៍ $y = f(x) = \dfrac{x^2 + 4x}{x^2 + 4x + 3}$ មានក្រាបតំនាង (c) ។

ក. ចូររកលីមីត $\lim\limits_{x \to -3} f(x)$ , $\lim\limits_{x \to -1} f(x)$ និង $\lim\limits_{x \to \infty} f(x)$ រួចទាញបញ្ជាក់សមីការអាស៊ីមតូតនៃក្រាប (c) ។

ខ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $y = f(x)$ ។

គ. ចូរបង្ហាញថាបន្ទាត់សមីការ $x = -2$ ជាអក្ស័ឆ្លុះនៃក្រាប(c) ។

ឃ. សង់ក្រាប (c) តំនាង $y = f(x)$ ក្នុងតំរុយអរតូនរម៉ាល់$(0, \vec{i}, \vec{j})$

៧៣-គេឱ្យអនុគមន៍ $y = f(x) = \frac{x^2 + 4x - 4}{x^2}$ ។

ក. គណនាលីមីត $\lim_{x \to 0} f(x)$ និង $\lim_{x \to \infty} f(x)$ រួចទាញបញ្ជាក់សមីការអាស៊ីមតូតនៃក្រាប (c) តំនាង f ។

ខ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ f ។

គ. ចូរបង្ហាញថាខ្សែកោង (c) មានចំនុចរបត់ I មួយដែលគេនឹងបញ្ជាក់កូអរដោនេ ។

ឃ.ចូរសរសេរសមីការបន្ទាត់ (T) ដែលប៉ះទៅនឹងខ្សែកោង (c) ត្រង់ចំនុចរបត់ I ។

ង. ចូរសង់ក្រាប (c) តំនាងអនុគមន៍ $y = f(x)$ និង បន្ទាត់ (T) ក្នុងតំរុយអរតូនរម៉ាល់ $(0, \vec{i}, \vec{j})$ ។

៧៤-គេឱ្យអនុគមន៍ $y = f(x) = \frac{2x^2 - 5x + 4}{x^2 - 3x + 3}$ មានក្រាបតំនាង (c) ។

ក. ចូរបង្ហាញថាអនុគមន៍ f(x) កំនត់ជានិច្ចលើ IR ។

គណនា $\lim_{x \to \infty} f(x)$ រួចបញ្ជាក់សមីការអាស៊ីមតូតដេកនៃក្រាប (c)

ខ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. សង់ក្រាប $(c)$ តាងអនុគមន៍ $f$ ក្នុងតំរុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$

ឃ.ដោយប្រើខ្សែកោង $(c)$ ចូរពិភាក្សាតាមតម្លៃ $m$ នូវអត្ថិភាពនៃ

ឫសរបស់សមីការ $(E)\ :\ (m-2)x^2-(3m-5)x+3m-4=0$ ។

( $m$ ជាប៉ារ៉ាម៉ែត្រ ) ។

៧៥-គេឱ្យអនុគមន៍ $y=f(x)=\dfrac{2(x-2)^2}{x^2-4x+3}$ មានក្រាបតំនាង $(c)$ ។

ក. ចូររកលីមីត $\lim\limits_{x\to1}f(x)$ ,$\lim\limits_{x\to3}f(x)$ និង $\lim\limits_{x\to\infty}f(x)$ រួចទាញបញ្ជាក់

សមីការអាសុីមតូតនៃក្រាប $(c)$ ។

ខ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f$

គ. ចូរបង្ហាញថាបន្ទាត់មានសមីការ $x=2$ ជាអក្ស័ឆ្លុះនៃក្រាប $(c)$

ឃ. ចូរសង់ក្រាប $(c)$ តំនាង$f$ តំរុយអរតូនរម៉ាល់ $(0,\vec{i},\vec{j})$ ។

៧៦-គេឱ្យអនុគមន៍ $y = f(x) = \dfrac{x^3 - 6x^2 + 9x - 4}{x^2 - 6x + 9}$

មានក្រាបតំនាង (c) ។

ក. ចូររកលីមីត $\lim\limits_{x \to 3} f(x)$ និង $\lim\limits_{x \to \pm\infty} f(x)$ រួចបញ្ជាក់សមីការ

អាស៊ីមតូតឈរនៃក្រាប (c) ។

ខ. ស្រាយថាបន្ទាត់ពុះទី១ នៃអក្ស័កូអរដោនេជាអាស៊ីមតូតទ្រេតនៃ

ក្រាប (c) ។

គ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ f ។

ឃ. ផ្ទៀងផ្ទាត់ថាចំនុច A(4 ,0) ជាចំនុចស្ថិតនៅលើក្រាប (c)

រួចរកសមីការនៃបន្ទាត់ប៉ះខ្សែកោង (c) ត្រង់ A ។

ង. សង់ក្រាប (c) តំនាងអនុគមន៍ f ក្នុងតំរុយអរតូនរម៉ាល់ $(0, \vec{i}, \vec{j})$

៧៧- គេមានអនុគមន៍ $y = f(x) = -x - 1 + \frac{4}{(x-2)^2}$

មានក្រាបតំនាង (c) ។

ក. ចូររកលីមីត $\lim_{x \to 3} f(x)$ និង $\lim_{x \to \pm\infty} f(x)$ រួចបញ្ជាក់សមីការ

អាសុីមតូតឈរនៃក្រាប (c) ។

ខ. កំនត់រកសមីការអាសុីមតូតទ្រេតមួយរបស់ក្រាប (c) ។

គ. គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ f ។

ឃ. សង់ក្រាប (c) តំនាងអនុគមន៍ f ក្នុងតំរុយអរតូនរម៉ាល់ $(0, \vec{i}, \vec{j})$

៧៨-គេអោយអនុគមន៍ $y = f(x) = (1-x).e^x - 1$ កំនត់លើ IR ។

ក-គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f(x)$ ។

ទាញបញ្ជាក់សញ្ញានៃអនុគមន៍ $f(x)$ ។

ខ-តាង g ជាអនុគមន៍កំនត់លើ IR ដោយ $g(x) = (2-x).e^x + 2 - x$ ។

ចូរគណនាលីមីត $\lim_{x \to -\infty} g(x)$ និង $\lim_{x \to +\infty} g(x)$ ។

គ-គណនាដេរីវេ $g'(x)$ រួចកំនត់សញ្ញានៃ $g'(x)$ ។

គូសតារាងអថេរភាពនៃអនុគមន៍ $g(x)$ ។

ឃ-បង្ហាញថាបន្ទាត់ $(d): y = 2 - x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$

តាង f កាលណា $x \to -\infty$ ។

ចូរបញ្ជាក់ទីតាំងធៀបរវាងបន្ទាត់ $(d)$ ជាមួយខ្សែកោង $(C)$ ។

ង-រកសមីការបន្ទាត់ $(T)$ ប៉ះនឹង $(C)$ ហើយស្របនឹងបន្ទាត់ $(d)$ ។

ច-កំនត់កូអរដោនេចំនុចរបត់ I របស់ខ្សែកោង $(C)$ ។

ឆ-ចូរសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(O, \vec{i}, \vec{j})$ ។

៧៩-គេអោយអនុគមន៍ $y = f(x) = (1-x).e^{2x}$ កំនត់លើ IR ។

ក-ចូរគណនាលីមីត $\lim_{x\to-\infty} g(x)$ និង $\lim_{x\to+\infty} g(x)$ រួចបញ្ជាក់សមីការ

អាស៊ីមតូតនៃក្រាប $(C)$ តាង $f(x)$ ។

ខ- គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f(x)$ ។

គ- កំនត់កូអរដោនេចំនុចរបត់ I របស់ខ្សែកោង $(C)$ ។

ឃ-ចូរសរសេរសមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង $(C)$ ត្រង់ចំនុច I ។

ង- ចូរសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(O, \vec{i}, \vec{j})$

៨០-គេអោយអនុគមន៍ $y = f(x) = (1-x)\left(e^{2x}+1\right)$ កំនត់លើ $IR$ ។

ក-គណនាលីមីត $\lim_{x\to-\infty} g(x)$ និង $\lim_{x\to+\infty} g(x)$ ។

ខ-គណនាដេរីវេ $f'(x)$ និង $f''(x)$ រួចគូសតារាងអថេរភាពនៃ $f'(x)$ ។

គ-កំនត់សញ្ញានៃ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f(x)$ ។

ឃ-បង្ហាញថាបន្ទាត់ $(d): y = 1-x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$

តាង $y = f(x)$ កាលណា $x \to -\infty$ ។

ចូរបញ្ជាក់ទីតាំងធៀបរវាងបន្ទាត់ $(d)$ ជាមួយខ្សែកោង $(C)$ ។

ង-រកសមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង$(C)$ ហើយស្របនឹងបន្ទាត់$(d)$ ។

ច-កំនត់កូអរដោនេចំនុចរបត់ $I$ របស់ខ្សែកោង $(C)$ ។

ឆ-ចូរសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(O, \vec{i}, \vec{j})$ ។

៨១-គេអោយអនុគមន៍ $y = f(x) = \left(\frac{1}{2}x - 1\right).e^{x}$ កំនត់លើ $IR$ ។

ក-ចូរគណនាលីមីត $\lim_{x\to-\infty} g(x)$ និង $\lim_{x\to+\infty} g(x)$ រួចបញ្ជាក់សមីការ

អាស៊ីមតូតនៃក្រាប $(C)$ តាង $f(x)$ ។

ខ- គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f(x)$ ។

គ- កំនត់កូអរដោនេចំនុចរបត់ $I$ របស់ខ្សែកោង $(C)$ ។

ឃ-សរសេរសមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង$(C)$ ត្រង់ចំនុច $I$ ។

ង- ចូរសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(O,\vec{i},\vec{j})$

៨២-គេអោយអនុគមន៍ $y=f(x)=\frac{x+\ln x}{x}$ កំនត់លើ $(0,+\infty)$ ។

ក-គណនាលីមីត $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ រួចបញ្ជាក់សមីការអាស៊ីមតូតនៃក្រាប$(C)$ តាង $f(x)$ ។

ខ- គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f(x)$ ។

គ-រកសមីការបន្ទាត់ $(T)$ ប៉ះនឹង$(C)$ ត្រង់ចំនុច $A$ មានអាប់ស៊ីស $x=1$ ។

ឃ-រកសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(O,\vec{i},\vec{j})$ ។

៨៣-គេអោយអនុគមន៍ $f(x)=-x+1+x.\ln x$ កំនត់លើ $(0,+\infty)$ ។

ក-គណនាលីមីត $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។

ខ- គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f(x)$ ។

គ-រកសមីការបន្ទាត់ $(T)$ ប៉ះនឹង$(C)$ ត្រង់ចំនុច $A$ មានអាប់ស៊ីស $x=1$

ឃ-ចូរសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូនរម៉ាល់ $(O,\vec{i},\vec{j})$ ។

៨៤-គេអោយអនុគមន៍ $f$ កំនត់លើ $IR$ ដោយ $f(x)=\frac{2x+2}{e^{2x}}$ ។

ក/គណនាលីមីត $\lim_{x\to-\infty} f(x)$ និង $\lim_{x\to+\infty} f(x)$ រួចបញ្ជាក់សមីការ

អាស៊ីមតូតនៃក្រាប ។

ខ/គណនាដេរីវេ $f'(x)$ រួចគូសតារាងអថេរភាពនៃអនុគមន៍ $f$ ។

គ/គណនាដេរីវេ $f''(x)$ រួចសិក្សាសញ្ញានៃ $f''(x)$ ។

កំនត់កូអរដោនេចំនុចរបត់ $I$ នៃខ្សែកោង $(C)$ ។

ឃ/សរសេរសមីការបន្ទាត់ $(T)$ ប៉ះនឹងខ្សែកោង $(C)$ ត្រង់ចំនុច $I$ ។

ង/ចូរសង់ក្រាប $(C)$ និងបន្ទាត់ $(T)$ ក្នុងតំរុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$

ឥឥឥ✳ឈឈឈ

# ឯកសារយោង

១-សៀវភៅគណិតវិទ្យាថ្នាក់ទី១២ (កំរិតមូលដ្ឋាន) របស់

ក្រសួងអប់រំ យុវជន និងកីឡា (បោះពុម្ពឆ្នាំ២០១១)

២-សៀវភៅគណិតវិទ្យាថ្នាក់ទី១២ (កំរិតខ្ពស់) របស់

ក្រសួងអប់រំ យុវជន និងកីឡា (បោះពុម្ពឆ្នាំ២០១១)

៣-Calculus single variable